

# សក្ខីកម្មរបស់ខ្ញុំ

## ប្រវត្តិជីវិតជនរងគ្រោះកម្ពុជាពីសម័យខ្មែរក្រហម

**អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា**
អគារលេខ ២និង៤ ផ្លូវឧកញ៉ាវាំង(១៩៥២) សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ
ប៉ុស្តិ៍ប្រៃសណីយ៍ប្រអប់សំបុត្រ ១១២៤ ភ្នំពេញ កម្ពុជា

| | |
|---|---|
| ទូរស័ព្ទ៖ | +855 (0) 23 63 66 992 |
| អ៊ីម៉ែល៖ | admin@tpocambodia.org |
| គេហទំព័រ៖ | www.tpocambodia.org |
| ហ្វេសប៊ុក៖ | www.facebook.com/tpocambodia |


**សក្ខីកម្មរបស់ខ្ញុំ**
ប្រវត្តិជីវិតជនរងគ្រោះកម្ពុជាពីសម័យខ្មែរក្រហម

**កែសំរួលដោយ៖**
ឃួន សារ៉ាត់
មុនី សុត្ថារា
អាណាលីស មីរតិន

សូមថ្លែងអំណរគុណដល់ GIZ (Deutsche Gesellschaft für Internationale Zusammenarbeit; German Society for International Cooperation) និង the Australian Department of Foreign Affairs and Trade (DFAT) តាមរយៈកម្មវិធីជំនួយផ្ទាល់ (Direct Aid Program) របស់ស្ថានទូតអូស្ត្រាលី។

ទស្សនៈសំដែងក្នុងសៀវភៅនេះ គឺជាទស្សនៈរបស់ជនរងគ្រោះ សិល្បៈករ រួមនិងអ្នកនិពន្ធប៉ុណ្ណោះ។

រក្សាសិទ្ធិ © 2015 ដោយអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា។ សិទ្ធិទាំងឡាយត្រូវបានរក្សា។ គ្មានផ្នែកណាមួយនៃការបោះពុម្ពនេះ អាចត្រូវគេផលិតសារជាថ្មី ឬប្រើប្រាស់ក្នុងទំរង់ណាមួយ ឬដោយមធ្យោបាយណាមួយ ដោយគ្មានការអនុញ្ញាតពីម្ចាស់ចេញផ្សាយ(ធីភីអូកម្ពុជា)បានឡើយ ទោះជាបច្ចេកវិទ្យាអេឡិចត្រូនិកក្ដី ឬមេកានិកក្ដី រួមទាំងការថតចម្លង ព្រមទាំងការកត់ត្រា។

**ក្របខាងក្រៅ និង រចនាបទសៀវភៅ**
គំនិតសិល្បៈ និងការរចនាទំព័រ © 2015 ដោយ ជឹម ចំរើន

**រូបភាពលំអនៅក្របខាងមុខ**
សិល្បៈកម្មដើម «ស្នៀមស្ងាត់» (ខ្មៅដៃនិងប្រព័ន្ធព័ត៌មានចំរុះ 2008) ដោយ អាន ហែម កន្និថា។ តាំងបង្ហាញលើកដំបូងក្នុងអំឡុងពេលតាំងពិព័រណ៍ស្តីពី «សិល្បៈនៃការរស់ជីវិត» ឆ្នាំ2008 រៀបចំដោយ the Konrad-Adenauer-Stiftung និង META HOUSE មជ្ឈមណ្ឌលវប្បធម៌ភ្នំពេញ ប្រទេសកម្ពុជា។ បានបោះពុម្ពឡើងវិញតាមការអនុញ្ញាតដ៏សប្បុរសពី អាន ហែម កន្និថា the Konrad-Adenauer-Stiftung និង META HOUSE ចេញពីការផ្សាយ «កាសែត Occasional Papers ស្តីពីការវិវត្តិនៃលទ្ធិប្រជាធិប្បតេយ្យ VOL 4 –សិល្បៈករនិយាយ – សិល្បៈនៃការរស់ជីវិត» © 2008 ដោយ the Konrad-Adenauer-Stiftung ។ សិល្បៈកម្មរូបភាព(ក្របខាងក្រៅ) និងសិល្បៈកម្ម (ទំព័រទី២) ដោយ Anders Jiras ។

**លំអរូបភាពខាងក្នុង**
សិល្បៈកម្មដើម © 2015 ដោយ ស៊ុំ រិទ្ធី
រូបថត © 2015 ដោយ ឃួន សារ៉ាត់
រាប់បញ្ចូលក្នុងការចេញផ្សាយនេះផងដែរ គឺការអនុញ្ញាតិដ៏សប្បុរសពី ស៊ុំ រិទ្ធី

ISBN: 978-99963-97-03-5

បោះពុម្ពនៅកម្ពុជា ដោយ រោងពុម្ព សាន់វេ ភ្នំពេញ

# សក្ខីកម្មរបស់ខ្ញុំ

## ប្រវត្តិជីវិតជនរងគ្រោះកម្ពុជាពីសម័យខ្មែរក្រហម

Australian Aid

កម្មវិធីសុខភាពផ្លូវចិត្ត
TPO
អង្គការចិត្តសង្គម អន្តរវប្បធម៌
Transcultural Psychosocial Organization
Community Mental Health Programme

giz

# សេចក្តីថ្លែងអំណរគុណ

ជាដំបូង យើងខ្ញុំសូមសំដែងការដឹងគុណយ៉ាងស្មោះអស់ពីដួងចិត្ត ដល់ជនរងគ្រោះដ៏ក្លាហានទាំង ១០ រូប ចំពោះការចែករំលែកប្រវត្តិជីវិតផ្ទាល់ខ្លួន ក្នុងសៀវភៅផ្សព្វផ្សាយនេះ។ ការធ្វើជាសាក្សីរបស់ពួកគាត់ គឺ ប្រកបដោយសេចក្តីក្លាហាន និងអំណាចមិនគួរឲ្យជឿ ហើយបើគ្មានពួកគាត់ សៀវភៅនេះនឹងមិនអាចបង្កើតបានដោយងាយឡើយ។ យើងសូមឧទ្ទិសឲ្យ ក្តីសង្ឃឹមនិងសុបិនដែលគាត់ប្រាថ្នា ដើម្បីការជាសះស្បើយ ការពិត យុត្តិធម៌និងការផ្សះផ្សាទាំងឡាយ ក្លាយជាការពិត។ សូមឲ្យអ្វីដែលបានកើតឡើងមិនអាចភ្លេចបាននិងមិនកើតមានសារជាថ្មីជារៀងរហូត។ សូមឲ្យព្រលឹងដូនតា ព្រមទាំងអ្នកស្លាប់ទៅជាទីស្រឡាញ់ជួបតែសន្តិភាព។

សូមថ្លែងអំណរគុណដល់លោក **ស៊ុំ រិទ្ធី** ជាវិចិត្រករនិងជាអតីតអ្នកទោសនៅគុកធំសម័យខ្មែរក្រហម ដែលបានធ្វើជាសាក្សីតាមវិធីសាស្ត្ររបស់គាត់ គឺការគូររូបដោយខ្មៅដៃនិងផាត់ពណ៌ដ៏ច្រើនរាប់មិនអស់ក្នុងអំឡុងច្រើនឆ្នាំកន្លងមកនេះ។ យើងសូមសំដែងការដឹងគុណចំពោះសក្ខីកម្មរបស់គាត់ ដែលបានដាក់បញ្ចូលក្នុងសៀវភៅនេះ ជារូបភាពជ្រើសរើសក្នុងចំណោមវិចិត្រកម្មរបស់គាត់រំលេចអំពីបទពិសោធន៍ប៉ះទង្គិចផ្លូវចិត្តផ្ទាល់របស់គាត់ក្នុងសម័យខ្មែរក្រហម។ យើងសូមឲ្យគាត់ជួបតែសេចក្តីល្អ ជាមួយការបន្តខិតខំប្រាប់រឿងរ៉ាវរបស់គាត់ ព្រមទាំងប្រឈមនិងការពិតជាក់ស្តែងនឹងភ្នែក។

ទន្ទឹមនេះ យើងសូមកោតសរសើរយ៉ាងខ្លាំងដល់ កាយវិការល្អរបស់វិចិត្រករ **ហែម អាន កន្និថា** ចំពោះការអនុញ្ញាតិឲ្យយើងចម្លងស្នាដៃគាត់ «សភាពស្ងៀមស្ងាត់» ដាក់លើក្របឯកសារផ្សព្វផ្សាយនេះ។ សូមអរគុណផងដែរ ដល់ **Nico Mesterharm** មកពីមេត្តាហោស៍នៅភ្នំពេញ និង the **Konrad-Adenauer-Stiftung** ចំពោះការយល់ព្រមឲ្យយើងចម្លងស្នាដៃនេះ ដែលបានដាក់បង្ហាញជាដំបូងក្នុងពិព័ណ៌ស្តីពី «សិល្បៈក្នុងការរក្សាជីវិត» ឆ្នាំ២០០៨ នៅមេត្តាហោស៍ ហើយមានអមជាមួយដោយ «ការរៀបរាប់របស់សិល្បករគំនូរកម្ពុជា – សិល្បៈក្នុងការរក្សាជីវិត» ផ្សព្វផ្សាយដោយ the Konrad-Adenauer-Stiftung ។

សូមអរគុណយ៉ាងខ្លាំងដល់ **សាន ស៊ីនួន** ចំពោះការបកប្រែពីភាសាខ្មែរទៅអង់គ្លេស និងដល់លោក **មុនី សុត្ថារា** ចំពោះការបកប្រែខ្លឹមសារពីភាសាអង់គ្លេសទៅភាសាខ្មែរ រួមនិងការចែករំលែកចំណេះដឹងទាំងភាសា និងទាំងប្រវត្តិរបស់គាត់ក្នុងសម័យខ្មែរក្រហមជាមួយនិងក្រុមផលិត។ សូមអរគុណផងដែរ ចំពោះសន្តានចិត្តនិងជំនាញរបស់លោក **ជឹម ចំរើន** ក្នុងការរៀបចំរចនាបទសៀវភៅនេះ ហើយនិងអ្នកស្រី **ឡុក មាស** និង **Dessa Somerside** ចំពោះការអានផ្ទៀងផ្ទាត់ឡើងវិញ។

យើងសូមថ្លែងអំណរគុណផងដែរដល់ **អ្នកព្យាបាល**របស់អង្គការធីភីអូ ទាំងអស់ ដែលធ្វើការប្រចាំថ្ងៃ គាំទ្រជនរងគ្រោះពីសម័យខ្មែរក្រហម នៅលើផ្លូវទៅកាន់ការជាសះស្បើយដ៏វែងហើយលំបាកនោះ។ ជាពិសេស យើងសូមអរគុណដល់អ្នកព្យាបាល ដែលបានដឹកនាំជនរងគ្រោះ( ពីចន្លោះខែ កុម្ភៈ ដល់ខែមិនា ឆ្នាំ២០១៤) ទាំង១០នាក់ក្នុងសៀវភៅនេះ ឆ្លងកាត់ដំណើរការរៀបរាប់ និងចងក្រងរឿងរ៉ាវជីវិតដ៏ឈឺចាប់ រួចជួយពួកគាត់ឲ្យយកឈ្នះបទពិសោធន៍ពីអតីតកាល ដែលមិនទាន់បានដោះស្រាយ រួចរំកិលផលវិបាកនៃរបួសផ្លូវចិត្តទៅមុខ។

ជាចុងក្រោយនេះ យើងសូមអរគុណដ៏ជ្រាលជ្រៅដល់ **GIZ** (Deutsche Gesellschaft für Internationale Zusammenarbeit; German Society for International Cooperation) និងស្ថានទូតអូស្ត្រាលី (តាមរយៈកម្មវិធីជំនួយផ្ទាល់របស់ Australian Department of Foreign Affairs and Trade) ចំពោះការឧបត្ថម្ភថវិការ ដល់ការផលិតនិងបោះពុម្ពសៀវភៅនេះ ក៏ដូចជាសកម្មភាពផ្សេងៗនៅអង្គការធីភីអូ ដែលជាផលប្រយោជន៍ដល់ប្រជាជនកម្ពុជា ជាពិសេស អ្នកបន្តរងផលប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរក្នុងសម័យខ្មែរក្រហម ក៏ដូចជាប្រជាជនកម្ពុជាផ្សេងទៀតកំពុងមានបញ្ហាផ្លូវចិត្តផ្សេងៗ។ សូមអរគុណចំពោះសណ្តានចិត្តរបស់ម្ចាស់ជំនួយទាំងនេះ។ ប្រជាជនកម្ពុជា ដូចជាជនរងគ្រោះទាំង១០នាក់ដែលបានផ្តល់សក្ខីកម្មក្នុងសៀវភៅនេះ កំពុងស្ថិតនៅលើផ្លូវទៅរកការជាសះស្បើយ ហើយអាចដើរតួជាផ្នែកមួយយ៉ាងសំខាន់ក្នុងដំណើរការបំបែកភាពស្ងៀមស្ងាត់ ប្រាប់ការពិត ស្វែងរកយុត្តិធម៌ និងការផ្សះផ្សានៅកម្ពុជា។

# មាតិកា


អំពីវិចិត្រករ 1

អារម្ភកថា ដោយវេជ្ជបណ្ឌិត ឈឹម សុធារ៉ា 3
នាយកប្រតិបត្តិ អង្គការជីភីអូកម្ពុជា

សេចក្តីផ្តើម 5

ហឿន សុខុម 10

អ៊ុន អឿន ហៅ ត្រេន 18

ដោត សុឃីន 25

អ៊ិន សារិ 33

មាស អួន 41

ប៊ុន សារឿន 48

ម៉ម សាង 55

ប៊ុត សារ៉េន 64

លី លន់ 72

ស៊ឹង វ៉ាន់ 84

យោបល់ និងព័ត៌មានត្រឡប់ 91

# អំពីវិចិត្រករ



ស៊ុំ រិទ្ធី និងរូបថតរបស់ឪពុករបស់គាត់

**ស៊ុំ រិទ្ធី** កើតនៅខេត្តកំពង់ចាម ហើយបច្ចុប្បន្នរស់នៅភ្នំពេញ។ ក្នុងសម័យខ្មែរក្រហម ត្រូវគេបង្ខំជម្លៀសពីកន្លែងមួយទៅកន្លែងមួយទៀត ដូចប្រជាជនកម្ពុជាជាច្រើនផ្សេងទៀតដែរ ដើម្បីធ្វើការងារធ្ងន់ៗហួសកម្លាំង។ គាត់ចាត់ទុកថាការប្រព្រឹត្តិរបស់ខ្មែរក្រហមមកលើគាត់ ពេលគាត់ជាប់ក្នុងពន្ធនាគារ គុកធំ ខេត្តសៀមរាប គឺជាព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្តយ៉ាងឃោរឃៅជាងគេបង្អស់ក្នុងរបបនោះ។ នៅក្នុងអំឡុងពេលនោះ កម្មាភិបាលខ្មែរក្រហមដែលបានគំរាមសម្លាប់គាត់ជាញឹកញាប់ បានធ្វើទារុណកម្មគាត់យ៉ាងធ្ងន់ធ្ងរ ហើយច្រើនលើកច្រើនសារ។ គាត់គឺជាអ្នកទោសម្នាក់ ក្នុងចំណោម២-៣នាក់ នៃអ្នកទោសកម្ពុជាជាច្រើននាក់ ដែលអាចគេចរួចពីការសម្លាប់ចោល ហើយក៏រស់ជីវិតពីរបបនោះ។ ផ្លូវទៅរកការជាសះស្បើយពេញលេញមានរយៈពេលយូរហើយជួបការលំបាក៖ «ក្រោយពីរបបនោះ ខ្ញុំគ្មានសល់អ្វីឡើយ ប៉ុន្តែមានការឈឺចាប់និងភាពបាក់ស្បាត លាយឡំជាមួយអារម្មណ៍ខឹងសម្បារ ដែលជាលទ្ធផលនៃអំពើទារុណកម្មយ៉ាងធ្ងន់ធ្ងរដែលខ្ញុំបានទទួល...។ ថ្វីត្បិតខ្ញុំបានរស់ ប៉ុន្តែ វាប៉ះទង្គិចខ្ញុំរាល់ពេលខ្ញុំនៅមានជីវិត»។ ក្រោយពីរបបនោះដួលរលំទៅ គាត់ប្តេជ្ញាស្វែងរកយុត្តិធម៌ ភ្លាមៗពេលគាត់មានឱកាស។ «ខ្ញុំនឹងដាក់ពាក្យប្តឹង ទៅតុលាការដើម្បីរកយុត្តិធម៌សំរាប់ខ្លួនខ្ញុំផង និងសំរាប់ជនរងគ្រោះដទៃទៀត» គាត់និយាយនៅពេលនោះ។ ឥឡូវនេះ គាត់ជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នៃសំណុំរឿង០០២ នៃអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) ហើយក៏បានឆ្លងកាត់ការព្យាបាលការប៉ះទង្គិចផ្លូវចិត្តពិសេសពីអង្គការធីភីអូកម្ពុជា ដែលផ្តល់ជូនជនរងគ្រោះពីសម័យខ្មែរក្រហមទាំងឡាយ។

លោក រិទ្ធី ប្រើវិចិត្រកម្មរបស់គាត់ជាមធ្យោបាយប្រឈមមុខជាមួយអតីតកាល និយាយប្រាប់ប្រវត្តិរបស់ខ្លួន និងទម្លាយឲ្យដឹងការពិត។ ការគូររូបដោយខ្មៅដៃ

និងរូបផាត់ពណ៌ក្នុងសៀវភៅនេះ – រួមនិងចំណងជើងដែលដាក់ជាប់ជាមួយ បង្ហាញ នូវបទពិសោធន៍ដែលគាត់បានឆ្លងកាត់ ក្នុងសម័យខ្មែរក្រហម និងការចងចាំដែលគាត់រក្សាទុកជាប់ខ្លួនសំរាប់ជីវិតចុងក្រោយរបស់គាត់។ គាត់សង្ឃឹមថា រូបទាំងនោះផ្តល់ការយល់ដឹង អំពីជីវិតក្នុងពន្ធនាគារក្នុងសម័យខ្មែរក្រហម ការព្យាយាមរស់របស់អ្នកទោស កាលនោះនិងបច្ចុប្បន្ន រួមនិងការយល់ដឹងជាងមុនអំពីអតីតកាលរបស់កម្ពុជា។


វិចិត្រករ ហៀម អាន កន្និដ្ឋា

**ហៀម អាន កន្និដ្ឋា** គឺជាវិចិត្រករជំនាន់ថ្មី ហើយបានទទួលសញ្ញាបត្រពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៅភ្នំពេញ។ នាងបានរួមចំណែកក្នុងក្រុមការតាំងបង្ហាញជាក្រុមច្រើនបែបនៅទីក្រុង ហើយបានបញ្ចប់ការសិក្សា ផ្នែកគរុសាស្រ្តនៅវិទ្យាស្ថានអប់រំ (ភ្នំពេញ)។ នៅឆ្នាំ២០០៧ នាងបានចូលរួមក្នុង «សិល្បៈនារី» ក្រុមសិល្បៈនារីមួយក្រុម ឧបត្ថម្ភថវិការដោយ«សិល្បៈករខ្មែរលើនដាសាផន»។ កន្និដ្ឋារៀបរាប់ថា ការគូររូបគឺជាវិធីបញ្ចេញអារម្មណ៍ដែលនាងមិនអាចនិយាយចេញជាពាក្យបាន។

វិចិត្រកម្មរបស់នាងមានចំណងជើងថា «ស្ងៀមស្ងាត់»(គូសដោយខ្មៅដៃ និងប្រព័ន្ធផ្សព្វផ្សាយចំរុះ ឆ្នាំ២០០៨) ត្រូវបានរំលេចលើក្របនៃសៀវភៅនេះ។ កន្និដ្ឋា និយាយថា៖ «ខ្ញុំធ្លាប់បានឮឪពុកម្តាយខ្ញុំនិយាយអំពីការឈឺចាប់របស់ពួកគាត់ក្នុងសម័យខ្មែរក្រហម។ ខ្ញុំអាចស្រមៃ និងយល់បានថា កាលសម័យនោះ ពួកគាត់នៅស្ងៀមមិននិយាយ វាប្រសើជាង»។

ដូច្នេះវិចិត្រកម្ម «ស្ងៀមស្ងាត់» សាកសមបំផុតក្នុងការបង្ហាញអំពី ភាពគ្មានលទ្ធភាពក្នុងការនិយាយ ការចងចាំ និងការប៉ះទង្គិចផ្លូវចិត្តដែលលាក់ទុកពីក្រោយជញ្ជាំងស្ងៀមស្ងាត់របស់ជនរងគ្រោះ ដែលព្យាយាមបំបែកភាពស្ងៀមស្ងាត់ ធ្វើជាសាក្សី រួចហើយស្វែងរកការពិត យុត្តិធម៌ និងការព្យាបាល។ នេះគឺជាអ្វីដែលមានក្នុងសក្ខីកម្មរបស់បុគ្គលគ្រប់ៗគ្នានៅក្នុងសៀវភៅ«សក្ខីកម្មរបស់ខ្ញុំ»នេះ ។

# អារម្ភកថា

ដោយ វេជ្ជបណ្ឌិត **ឈឹម សុធារ៉ា**
នាយកប្រតិបត្តិ អង្គការធីភីអូកម្ពុជា

មិត្តអ្នកអានជាទីមេត្រី!

សៀវភៅនេះគឺជាផ្នែកមួយនៃ កិច្ចការរបស់អង្គការធីភីអូកម្ពុជា ក្នុងការផ្ដល់ការគាំទ្រនិងព្យាបាលផ្លូវចិត្តដល់ជនរងគ្រោះពីសម័យខ្មែរក្រហម ហើយប្រាប់និងពន្យល់ដល់មនុស្សទូទៅ អំពីផលប៉ះពាល់ផ្លូវចិត្តនៃរបបនោះ កំពុងបន្តមាននៅឡើយ។

ការប្រព្រឹត្តិខុសរបស់អតីតកាលកំពុងធ្វើឲ្យបច្ចុប្បន្នកាលនៅរងរបួស នៅឡើយ។ បច្ចុប្បន្ននេះ ជនរងគ្រោះពីសម័យខ្មែរក្រហមជាច្រើនកំពុងឈឺចាប់នៅឡើយ។ ពួកគាត់បៀមទុកនូវស្លាកស្នាមរបួសផ្លូវចិត្ត អំពីការជួបប្រទះកាលពីអតីតកាលរបស់ខ្លួន – គឺជាស្លាកស្នាមដែលស្ដែងចេញដោយឯកឯងជាទំរង់នៃការបាក់ស្បាត និងរោគសញ្ញាផ្សេងៗទៀតនៃសភាពប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ។ ជនរងគ្រោះជាច្រើន កំពុងស្ថិតនៅក្នុងវិបត្តិនានានៃរបួសផ្លូវចិត្តដ៏ស៊ាំញ៉ាំហើយធ្ងន់ធ្ងរ។ ការព្យាបាលរបួសផ្លូវចិត្ត-សង្គមពីអតីតកាល មិនគ្រាន់តែពាក់ព័ន្ធតែនិងវិធីវេជ្ជសាស្ត្រប្រើថ្នាំដែលពឹងផ្អែកលើវេជ្ជបញ្ជា ប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវការការរួមផ្សំគ្នាមួយ រវាងវិធីសាស្ត្រផ្សេងៗទៀត មានវិធីមិនមែនវេជ្ជសាស្ត្រ វិធីក្នុងប្រព័ន្ធតុលាការនិងក្រៅប្រព័ន្ធតុលាការផ្សេងៗទៀត ដូចជា ការកាត់ទោស ការសំដែងការពិត ការទទួលស្គាល់កំហុសពីជនប្រព្រឹត្តិខុសទាំងឡាយ រួមនិងសំណងនានា ផងដែរ។ ការព្យាបាលជនរងគ្រោះតាមវិធីមិនមែនវេជ្ជសាស្ត្រ – ដែលមិនផ្ដោតទៅលើតែការប្រើថ្នាំតាមវេជ្ជបញ្ជានោះ – បានចូលរួមចំណែកជួសជុលឡើងវិញនូវសេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះ ពន្លឿនការជាសះស្បើយនិងផ្សះផ្សាគ្នា ទាំងកំរិតបុគ្គលនិងទាំងកំរិតសង្គម នៅកម្ពុជា។

ពេលនិយាយអំពីបទពិសោធន៍ជួបព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងររបស់ខ្លួន ជនរងគ្រោះពីសម័យខ្មែរក្រហមជាច្រើន មានការឈឺចាប់ហួសប្រមាណ

ហើយពោរពេញទៅដោយក្ដីអាម៉ាស រហូតដល់អាចនឹងគ្រោះថ្នាក់ផង។ ដូច្នេះហើយទើប ជនរងគ្រោះជាច្រើនបានបង្ខំចិត្តនៅស្ងាត់ស្ងៀម ហើយការធ្វើដូច្នេះគឺបានរួមយុបឃិតគ្នាលាក់បាំងដោយអចេតនា យ៉ាងទូលំទូលាយ និងយ៉ាងរឹងមាំ ក្រោយពេលជម្លោះនៅកម្ពុជា។ ភាពស្ងាត់ស្ងៀមនេះបានពន្យាឱកាសសះស្បើយរបួសផ្លូវចិត្តពីអតីតកាលរបស់ជនរងគ្រោះ ដែលការសះស្បើយនោះអាចកើតឡើងបាន ដោយគ្រាន់តែមានឱកាសរំកិលអតីតកាលប៉ុណ្ណោះ។

«សក្ខីកម្មរបស់ខ្ញុំ» បង្កលក្ខណៈឲ្យជនរងគ្រោះទាំងឡាយ ប្រាប់រឿងរ៉ាវរបស់ខ្លួនរួចបញ្ចេញអារម្មណ៍របស់ខ្លួន ដែលនាំទៅដល់ការជាសះស្បើយរបួសផ្លូវចិត្ត-សង្គមជាច្រើន។ វាអាចជួបការឈឺចាប់ពេលដំបូង ប៉ុន្តែវាបានប្រព្រឹត្តិទៅ ដោយមានការជួយគាំទ្រពីអ្នកព្យាបាលរបស់អង្គការធីភីអូ ដែលមានជំនាញផ្នែកប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ  នៅក្នុងមជ្ឈដ្ឋានដ៏មានសុវត្ថិភាពមួយ។ ទាំងនោះពិតជានាំទៅដល់អារម្មណ៍ធូរស្បើយសំរាប់ជនរងគ្រោះទាំងឡាយ។ ឥឡូវនេះពួកគាត់ចង់ចែករំលែកប្រវត្តិរឿងរបស់ពួកគាត់ដល់អ្នក«ជាអ្នកអាន» ក្នុងក្ដីសង្ឃឹមថា បានផលល្អៗ – រួមមាន ការពិត ការសះស្បើយនិងផ្សះផ្សា រួមទាំងមិនកើតឡើងទៀតនូវសោកនាដ្យកម្មដូចនេះ – ចេញពីសៀវភៅនេះ។

ខ្ញុំសូមកោតសរសើរអស់ពីដួងចិត្តដល់ជនរងគ្រោះដែលប្រាប់រឿងរ៉ាវរបស់ខ្លួនក្នុងសៀវភៅនេះ ចំពោះសេចក្ដីក្លាហានរបស់ពួកគាត់ រួមនិង សណ្ដានចិត្តសប្បុរស ក្នុងការចែករំលែកបទពិសោធន៍របស់ខ្លួន ដល់ជនកម្ពុជាជំនាន់ក្រោយ និងដល់ពិភពលោក។ ខ្ញុំសង្ឃឹមដោយស្មោះថា សកម្មភាពចែករំលែកដ៏ក្លាហានរបស់ពួកគាត់ និងជំរុញជនរងគ្រោះដ៏ទៃទៀតរំកិលខ្លួនទៅមុខ បន្តប្រាប់រឿងរ៉ាវដែលខ្លួនជួបប្រទះ រួចបានសះស្បើយផងដែរ។

ជាចុងក្រោយ ខ្ញុំសង្ឃឹមថា មិត្តអ្នកអានទាំងអស់ ទោះនៅកម្ពុជាឬនៅទីណាក៏ដោយ នឹងមើលឃើញថាសៀវភៅនេះ មានប្រយោជន៍ ជាទីចូលចិត្ត និងប្រកបដោយវិចារណញ្ញាណ។

ភ្នំពេញ ២០១៥

វេជ្ជបណ្ឌិត **ឈឹម សុធារ៉ា**

# សេចក្ដីផ្ដើម

ពេលនេះ ស្ទើរ៤ទសវត្សមកហើយក្រោយពីភាពហិនហោចមកដល់កម្ពុជា ដោយសារសម័យខ្មែរក្រហម ប្រជាជនកម្ពុជា នៅបន្តរងស្នាមរបួសផ្លូវចិត្ត-សង្គម ពីរបបឃោរឃៅជាងគេបង្អស់ ទាំងកំរិតបុគ្គលនិងកំរិតសង្គមជាតិទាំងមូល។

ក្នុងអំឡុងតែ ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ ១៩៧៥-៧៩ ប៉ុណ្ណោះ ប្រជាជនកម្ពុជាប្រមាណ២លាននាក់ ឬថា ប្រហែល ១/៤ នៃប្រជាជនសរុប បានស្លាប់ ដោយសារ ការប្រហារជីវិត ការធ្វើទារុណកម្ម ការបង្អត់អាហារ ការបង្ខំឲ្យធ្វើការហួសកម្លាំង ជំងឺ និង ការបណ្ដេតបណ្ដោយ។ អ្នកដែលបានរួចរស់ជីវិត ក៏បានរស់ក្រោមលក្ខណ្ឌដ៏ឃោរឃៅផងដែរ។ ខ្មែរក្រហមបានកំទេចដោយចេតនានូវរចនាសម្ព័ន្ធនៃជីវភាពសង្គមកម្ពុជា ដែលបានផ្ដោតយ៉ាងខ្លាំងទៅលើក្រុមគ្រួសារ សហគមន៍និងសាសនា ហើយបំផ្លាញអស់នូវហេដ្ឋារចនាសម្ព័ន្ធស៊ីវិលរបស់ប្រទេស រួមមាន ប្រព័ន្ធសុខាភិបាល អប់រំ និង ប្រព័ន្ធយុត្តិធម៌។ ការជ្រៀតចូលរបស់ប្រទេសវៀតណាមនៅឆ្នាំ ១៩៧៩ បានបញ្ចប់ភាពសាហាវឃោរឃៅរបស់របបនោះ ប៉ុន្តែពេលនោះ កម្ពុជាកំពុងស្ថិតក្នុងសភាពដាច់រហែក ទាំងរាងកាយ (សម្ភារៈ)និង ផ្លូវចិត្ត(ព្រលឹង) ហើយបានបាត់បង់ធនធានមនុស្សយ៉ាងច្រើនលើសលុប ស្មារតីប្រជាជនបានបាក់រាប។ ជនរងគ្រោះភាគច្រើនលើលលុបគ្មានសល់អ្វីក្រៅពី បទពិសោធន៍ប៉ះទង្គិចផ្លូវចិត្តនិងការឈឺចាប់ជាច្រើន រួមនិង ត្រូវនឹកឃើញមកវិញ ភាពភ័យរន្ធត់ ត្រូវប្រឈមនិងការលំបាករៀបចំកសាងជីវិតនិងប្រទេសឡើងវិញ ក្នុងបរិយាកាសមិនជឿទុកចិត្តគ្នា ស្ងៀមស្ងាត់និងភ័យខ្លាចប៉ុណ្ណោះ។ សូម្បីមកដល់សព្វថ្ងៃនេះ ពួកគាត់ជាច្រើន នៅមិនទាន់អាចចែករំលែកប្រវត្តិរបស់ខ្លួន រឿងរ៉ាវរបស់ខ្លួន បទពិសោធន៍របស់ខ្លួនក្នុងសម័យនោះជាមួយអ្នកផ្សេងទៀត បាននៅឡើយ។ បទឧក្រិដ្ឋជាច្រើនដែលបានប្រព្រឹត្តិមកលើពួកគាត់ក៏មិនទាន់បានចោទប្រកាន់ មនុស្សជាទីស្រឡាញ់របស់ពួកគាត់ក៏មិន

ទាន់ត្រូវគេទទួលស្គាល់ ឬ អតីតកាលទាំងនោះក៏មិនទាន់បានរំកិលទៅមុខនៅឡើយ។ របួសផ្លូវចិត្ត-សង្គមដ៏ធ្ងន់ធ្ងររបស់គាត់ ក៏មិនទាន់ត្រូវបានគេព្យាបាល។

ខ្មែរក្រហមបានបង្កឲ្យមានការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរកំរិតបុគ្គល និងសមូហភាព ហើយផលប៉ះពាល់ពីភាពភ័យ រន្ធត់ ភាពអយុត្តិធម៌និងភាពឃោរឃៅទាំងនោះ កំពុងបង្កើតភាពហិនហោចក្នុងសង្គមកម្ពុជាស្ទើរ៤០ឆ្នាំក្រោយមកនេះ នៅឡើយ។ ការខូចខាតផ្លូវចិត្ត-សង្គម បង្កឡើងដោយរបបនេះមកលើបុគ្គលនិងសង្គមទាំងមូល បាននិងកំពុងហិនហោចយ៉ាងធំធេង និងយូរអង្វែង។ យូរណាស់មកហើយ ធន្ទះព្យាបាលនិងស្តារសម្បទាឡើងវិញមានល្បឿនយឺតជាងគេក្នុងដំណើរការកសាងកម្ពុជាពីបាតក្រោមមកនេះ។

ដោយសារការជំរុញពីអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា(អវតក) ស្គាល់ថាជាសាលាក្តីខ្មែរក្រហមផងដែរ ចុងបញ្ចប់ធន្ទះដ៏លំបាកនោះកំពុងត្រឡប់មកវិញ។ អវតក បានផ្តល់ឱកាសពិសេសមួយដល់ជនរងគ្រោះ ដើម្បីស្វែងរកការពិតនិងយុត្តិធម៌។ ជាលើកទី១ហើយ ក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិមួយ បានដាក់បញ្ចូលជនរងគ្រោះនៃការកាប់សម្លាប់រង្គាល ទៅក្នុងដំណើរការជំនុំជំរះជាដើមបណ្តឹងរដ្ឋប្បវេណី ជាជាងជាសាក្សីធម្មតា ដែលបង្កលក្ខណៈឲ្យពួកគាត់ចូលរួមកាន់តែសកម្មក្នុងដំណើរការនៃសាលាក្តី ហើយមានអារម្មណ៍ថាគេផ្តល់អំណាចឲ្យ តាមរយៈបទពិសោធន៍នេះ។ អវតក ផ្តល់ឱកាសឲ្យជនរងគ្រោះ បានធូរស្បើយដោយផ្តល់ឲ្យពួកគាត់នូវលំហមួយ និយាយប្រាប់រឿងរ៉ាវរបស់ខ្លួន រួចទទួលបាន ការទទួលស្គាល់ខ្លះអំពីការរំលោភបំពានទាំងឡាយដែលពួកគាត់បានជួបប្រទះ។ នៅក្នុងបរិបទនេះហើយ ដែលអង្គការធីភីអូកម្ពុជាសហការជាមួយអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ និង អង្គភាពគាំពារជនរងគ្រោះនៃសាលាក្តីខ្មែរក្រហម(អវតក) ផ្តល់សេវាកម្មផ្លូវចិត្ត-សង្គមជាច្រើនដល់ជនរងគ្រោះពីសម័យខ្មែរក្រហមដែលជាដើមបណ្តឹងរដ្ឋប្បវេណីនៃអវតករួមមាន៖ ការគាំទ្រផ្លូវចិត្ត-សង្គមដល់ទីកន្លែង មុនពេល ក្នុងពេល និង ក្រោយពេល

ដំណើរការនៃសាលាក្តី ក៏ដូចជា ការព្យាបាល និង ប្រឹក្សាផ្លូវចិត្តជាបុគ្គល ផ្សេង ក្រៅពីសាលាក្តី ផងដែរ។ ធ្វើដូចនេះ យើងមានទិសដៅបំពេញបន្ថែម ដំណើរការ ជានិមិត្តរូបថ្នាក់ជាតិក្នុងការស្វែងរកយុត្តិធម៌ និងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសិទ្ធិមនុស្សក្នុងផ្លូវតុលាការ ជាមួយនឹងវិធីសាស្ត្រជាបុគ្គលដ៏ខ្ពង់ខ្ពស់ សំរាប់ជនរងគ្រោះ ដើម្បីប្រាប់រឿងរ៉ាវរបស់ខ្លួន ឆ្លុះបញ្ចាំងពីអតីតកាល រួច កសាងអត្តសញ្ញាណខ្លួនឡើងវិញ តាមរយៈការគិតគូរដល់សេចក្តីត្រូវការផ្លូវចិត្ត របស់គាត់ និង លើកកម្ពស់ការជាសះស្បើយរបស់ពួកគាត់។

សៀវភៅនេះមានប្រវត្តិជីវិតរបស់ជនរងគ្រោះចំនួន ១០នាក់ ដែលបានប្រាប់ អ្នកព្យាបាលនៅអង្គការធីភីអូ ក្នុងអំឡុងពេលព្យាបាល ថាគាត់ទាំងអស់គ្នាជា ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២/០១ នៅ អវតក។ ជាញឹកញាប់ នេះ ជាលើកទី១ហើយ ដែលពួកគាត់បានប្រាប់រឿងរ៉ាវរបស់ខ្លួនទៅអ្នកណាម្នាក់។ ការនិយាយប្រាប់ និងចងក្រងប្រវត្តិជីវិតឈឺចាប់របស់ខ្លួន ក្រោមការនាំផ្លូវរបស់ អ្នកជំនាញព្យាបាលណាម្នាក់ គឺជួយជនរងគ្រោះ ឲ្យប្រឈមមុខនឹងការជួប ប្រទះពីអតីតកាលដែលមិនទាន់បានដោះស្រាយ រួចរំកិលផលវិបាកនៃរបួសផ្លូវ ចិត្តទៅមុខ។ ជាលទ្ធផលត្រឡប់មកវិញ គឺរួមចំណែកដល់ការសះស្បើយរបស់ គាត់ នោះគឺអ្វីដែលគាត់បានរង់ចាំ ជាង៣ទសវត្សមកហើយ។ ជនរងគ្រោះបាន ជ្រើសរើសផងដែរឲ្យរឿងរ៉ាវរបស់គាត់ កើតចេញជាសក្ខីកម្មសំណេរ។ ការអាន សក្ខីកម្មរបស់ពួកគាត់ឮៗជាចំហ រួចប្រគល់ជូនគាត់ដោយព្រះសង្ឃនៅនឹងមូល ដ្ឋាន ក្នុងពិធីបុណ្យព្រះពុទ្ធសាសនាជាសាធារណៈណាមួយ នោះគឺជួយដល់ការ ទទួលស្គាល់ជាសាធារណៈនូវការឈឺចាប់របស់ពួកគាត់ ដកចេញស្លាកស្នាមមិន ល្អជាជនរងគ្រោះ រួចហើយ ជួសជុលសេចក្តីថ្លៃថ្នូររបស់ពួកគាត់ឡើងវិញ។ វា អនុញ្ញាតិផងដែរ ឲ្យពួកគាត់សំរួលការឈឺចាប់ដល់ព្រលឹងដូនតារបស់ខ្លួន រួច គោរពដល់វិញ្ញាណក្ខន្ធញាតិសណ្តានដែល បានស្លាប់ទៅ។ ជាក្តីប្រាថ្នារបស់ជន រងគ្រោះទាំង១០នាក់ ដែលផ្តល់សក្ខីកម្ម ក្នុងសៀវភៅនេះផងដែរថា ប្រវត្តិរឿង របស់គាត់ត្រូវគេប្រើជាកំណត់ត្រាប្រវត្តិសាស្ត្រ អំពីអ្វីដែលបានកើតឡើងក្នុង

សម័យខ្មែរក្រហម ហើយថា ជាឯកសារអប់រំដល់ក្មេងជំនាន់ក្រោយ ក្នុងក្តីសង្ឃឹមថា វានឹងមិនកើតមានទៀតឡើយ។ វាជាស្មារតីដែលថាពួកគាត់ទាំងអស់គ្នាស្ម័គ្រចិត្ត ឲ្យផ្សព្វផ្សាយរឿងរ៉ាវរបស់គាត់ក្នុងសៀវភៅនេះ។

ទិសដៅនៃសៀវភៅនេះគឺផ្តល់សម្លេងមួយដល់ជនរងគ្រោះពីសម័យខ្មែរក្រហម ហើយបំបែកវដ្តនៃភាពស្ងៀមស្ងាត់ចំពោះការឈឺចាប់របស់ពួកគាត់ ហើយបញ្ចប់ការព្យាយាមជាប្រចាំរបស់ពួកគាត់ ដើម្បីដោះស្រាយឲ្យអស់ចិត្តពីអតីតកាល។

ទស្សនៈដែលបានបញ្ចេញក្នុងសៀវភៅនេះ គឺបានមកពីបុគ្គលម្នាក់ៗ ហើយមិនឆ្លុះបញ្ចាំងដាច់ខាតនូវទស្សនៈ របស់អង្គការធីភីអូកម្ពុជា ឬ អង្គការផ្សេងទៀតដែលពាក់ព័ន្ធនិងគំពេងនេះឡើយ។ សក្ខីកម្មទាំងនេះ ត្រូវបានបកប្រែពីភាសាខ្មែរ  បានកែសំរួលដើម្បីអាចអានបាន រួចកាត់បង្រួញសម័យកាលមុនខ្មែរក្រហមឲ្យខ្លី ហើយបំបាត់ចោលសេចក្តីថ្លែងច្រំដែល។ ពេលធ្វើដូចនេះ យើងបានព្យាយាមរក្សាទុក លំដាប់នៃសាច់រឿងឲ្យនៅដូចដើម រួចបំពេញហេតុការណ៍ទាំងឡាយ ឆ្លុះបញ្ចាំងអំពីបទពិសោធន៍ជនរងគ្រោះ ដូចដែលពួកគេបានប្រាប់ទៅ អង្គការធីភីអូកម្ពុជា។ ឯកសារទំរង់ពេញលេញ(ទាំងមូល) មានជូនតាមការស្នើសុំពីអង្គការធីភីអូកម្ពុជា។

ពេញប្រវត្តិរឿងទាំង១០ អ្នកនឹងឃើញប្រវត្តិរឿងមួយផ្សេងទៀត – គឺ រឿងរបស់លោក ស៊ុំ រីទ្ធី ដែលគាត់បានប្រាប់តាមរយៈរូបគំនូរដោយខ្មៅដៃនិងគំនូរផាត់ពណ៌របស់គាត់ មាននៅក្នុងសៀវភៅនេះ។ រូបភាពបង្ហាញទាំងនេះ – (តែចំនួនខ្លះនៃគំនូរច្រើនទៀត ដែលគាត់បានផលិតជាច្រើនឆ្នាំកន្លងមកនេះ ជាមធ្យោបាយដោះស្រាយផ្លូវចិត្តជាមួយអតីតកាល ហើយឲ្យការពិតនោះចេញមក) – ប្រាប់រឿងរបស់គាត់។ ទោះបីជារូបទាំងនោះ រំលេច ការជួបប្រទះស្រដៀងគ្នាទៅនិងការជួបប្រទះ របស់ជនរងគ្រោះជាច្រើនផ្សេងទៀតក៏ដោយ រូបទាំងនោះមិនតំណាងជាក់លាក់ឲ្យសក្ខីកម្មសំណេរទាំង១០នោះទេ ប៉ុន្តែមានបំណងធ្វើជាសក្ខីកម្មបន្ថែម ចំណងជើងនានាក៏ដូចគ្នាដែរ ដែលរំលេចនូវ

បទពិសោធន៍ខ្លួនគាត់ផ្ទាល់។

«សក្ខីកម្មរបស់ខ្ញុំ» ត្រូវបានឧទ្ទិសដល់ជនរងគ្រោះប្រកបដោយភាពអត់ធន់ និងសេចក្ដីក្លាហានដ៏អស្ចារ្យ ដែលបានចែករំលែករឿងរ៉ាវរបស់ខ្លួនជាមួយយើង និងជាមួយអ្នក ភាគច្រើនគឺទម្លាយឲ្យដឹងនូវរឿងឈឺចាប់ជាងគេបង្អស់របស់ខ្លួន គឺបទពិសោធន៍រួមសង្វាស់។ វាត្រូវប្រើភាពខ្លាំងនិងសេចក្ដីក្លាហានយ៉ាងច្រើន ក្នុងការបញ្ចេញវាមក។ សំរាប់ពួកគាត់ នេះគឺជាការព្យាបាល ជាឯកសារប្រវត្តិសាស្ត្រ និង ជាការស្វែងរកយុត្តិធម៌។ ជាចុងក្រោយ វាគ្រាន់តែជាការបំបែកវប្បធម៌នៅស្ងាត់ស្ងៀម រំកិលអតីតកាល ដែលការសះស្បើយនិងផ្សះផ្សាអាចកើតមាន ហើយថា ប្រជាជននិងសហគមន៍អាចពិតជាផ្លាស់ទីទៅមុខ។

សូមថ្លែងអំណរគុណដល់ GIZ (Deutsche Gesellschaft für Internationale Zusammenarbeit; German Society for International Cooperation) និងស្ថានទូតអូស្ត្រាលី (តាមរយៈកម្មវិធីជំនួយផ្ទាល់របស់ Australian Department of Foreign Affairs and Trade) ដែលបានធ្វើឲ្យសៀវភៅនេះកើតមានឡើង។ សៀវភៅនេះបានបង្កើតឡើងក្នុងបរិបទនៃគំរោងយុត្តិធម៌ និងភាពធូរស្បើយសម្រាប់ជនរងគ្រោះពីសម័យខ្មែរក្រហម *(Justice and Relief for Survivors of the Khmer Rouge)* ដែលក្នុងពេលនោះ អង្គការធីភីអូកម្ពុជា ដោយមានកិច្ចសហការជិតស្និទ្ធិជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU) រួមជាមួយ អង្គភាពគាំពារជនរងគ្រោះ(VSS) នៃ អវតក(ECCC) បានផ្ដល់សេវាផ្លូវចិត្តចំរុះជូនជនរងគ្រោះពីសម័យខ្មែរក្រហម ដែលជាដើមបណ្ដឹងរដ្ឋប្បវេណីនៃអវតក។ គំរោងនេះ ឧបត្ថម្ភថវិការដោយ GIZ ស្ថានទូតអូស្ត្រាលី (តាមរយៈកម្មវិធីជំនួយផ្ទាល់របស់ Australian Department of Foreign Affairs and Trade) មូលនិធិស្វីស (Swiss Foundation) និង UNVFVT (United Nations Voluntary Fund for Victims of Torture) ។

# ហឿន សុខុម

## ភេទស្រី អាយុ ៤៨ឆ្នាំ ជាអ្នកលក់អង្ករនិងគ្រឿងបរិភោគ នៅខេត្តកំពង់ស្ពឺ

**សុខុម** កើតនៅភ្នំពេញ ជាកន្លែងនាងធ្លាប់រស់នៅយ៉ាងសប្បាយរីករាយជាមួយឪពុកនាង ដែលមានសក្តិជាអនុសេនីយឯកក្នុងរបប លន់ ណុល រីឯម្តាយនាងជាអ្នកលក់ដូរក្នុងផ្សារ ដូចគ្នានឹងប្អូនប្រុស ប្អូនស្រី និងជីដូនជីតានាងដែរ។ នៅឆ្នាំ១៩៧៥ ក្នុងការប្រយុទ្ធគ្នាគួរឲ្យរន្ធត់មួយ ខ្មែរក្រហមបានរុញច្រានគ្រួសារនោះចេញពីភ្នំពេញ រួចបង្ខំពួកគាត់ឲ្យធ្វើការនៅទីជនបទដើម្បីចាប់ផ្តើមជីវិតថ្មីមួយ។ អ្វីដែលនាងបានឃើញតាមផ្លូវហាក់ដូចជាមិនទាន់ប៉ះទង្គិចខ្លាំងគ្រប់គ្រាន់នៅឡើយទេ នាងនៅមានជួបប្រទះការប្រព្រឹត្តដ៏អាក្រក់ផ្សេងៗទៀត កាលនៅក្នុងកណ្តាប់ដៃខ្មែរក្រហម ទំរាំរស់ជីវិតទល់នឹងរឿងចម្លែកៗទាំងឡាយ។

# សក្ខីកម្មរបស់ខ្ញុំ

ពួកយើងបានធ្វើដំណើរអស់រយៈពេល ចំនួន១០ថ្ងៃ ១០យប់ ទើបទៅដល់ភូមិ។ ក្នុងដំណើរតាមផ្លូវ នាងខ្ញុំបានជួបនឹងរឿងរ៉ាវយ៉ាងច្រើនដ៏គួរអោយភ័យខ្លាចជាច្រើនលើកច្រើនសារ។ គ្រាន់តែចេញពីផ្ទះបានបន្តិចប៉ុណ្ណោះ នាងខ្ញុំបានឃើញពួកវាបាញ់សំលាប់បុរសម្នាក់នៅក្នុងឡាន រួចចាប់ប្រពន្ធមកខាងក្រៅឡានបាញ់សំលាប់ទាំងមានផ្ទៃពោះ។ ពួកវាទាញយកកូនតូចៗ – ស្រីមួយប្រុសមួយ – បោះទៅលើដោតនឹងជំពុះទុងកាំភ្លើង ហូរឈាមស្រែកយំ បន្ទាប់មកពួកវាចាក់ធ្លុសឆ្អៀល រហូតដល់ដាច់ខ្យល់ស្លាប់លែងយំ។

នៅតាមផ្លូវ ក្នុងហ្វូងមនុស្សដ៏ច្រើនក្នុងដំណើរបន្តដោយគ្មានគោលដៅនៃការភៀសជន្លៀសនោះពួកវាបានបង្ខំនិងវាយធ្វើបាបមនុស្សយ៉ាងសាហាវព្រៃផ្សៃបំផុត។ មនុស្សចាស់ៗ និងកូនក្មេង ឈឺដើរមិនរួច ពួកវាវាយធ្វើបាបនិងសំលាប់បន្ថែម ។ អ្នកខ្លះបានស្រែកសុំចំណីអាហារ និង សុំរទេះជិះ។ ខណៈនោះគ្មាននរណាម្នាក់ហ៊ានជួយ ឬ ហ៊ានផ្តល់ចំណីអាហារឲ្យឡើយ ត្បិតអី បើនរណាម្នាក់ហ៊ានឲ្យ ពួកវានឹងកញ្ឆក់ទាញមិនអោយឡើយ។ មានពេលខ្លះ ពួកវាបានវាយចាក់នឹងជំពុះទុងកាំភ្លើង រួចបាញ់ សំលាប់តែម្តង ដោយបន្សល់ទុកនូវមនុស្សស្លាប់ របួស និងសំរែកឈឺចាប់ ជាច្រើនពាសពេញតាមដងផ្លូវ។

ធ្វើដំណើរដូចគ្នានេះ ពួកយើងបានមកដល់កន្លែងមួយនាពេលយប់។ ពេលព្រលឹមឡើងភ្ញាក់ដឹងខ្លួន ពួកយើងភ្ញាក់ផ្អើលយ៉ាងខ្លាំង ត្បិតអី នៅជុំវិញខ្លួនយើងមានសុទ្ធតែសាកសពស្លាប់គរលើគ្នា នៅក្នុងបឹងកំផ្លោក ដែលពួកយើងដងទឹកយកមកដាំបាយ មានត្រាំឈាមនិងសាកសពអណ្តែតត្រៀបត្រា។ ពួកយើងមានការរន្ធត់យ៉ាងខ្លាំង។ ជាងនេះទៅទៀតនោះ យើងឃើញសត្វជ្រូកកំពុងដើរ

ស៊ីសាកសពខ្មោច ដែលស្អុយរលួយ ហើយសត្វឆ្កែកំពុងតែហែកទាញអូស សាកសពទៀតផង។

បន្ទាប់មកពួកយើងក៏បានធ្វើដំណើរបន្តទៅមុខទៀត ហើយបានមកដល់ភូមិមួយចំនួន។ រយៈពេលនៅទីនោះ ក្រុមគ្រួសារនាងខ្ញុំ ជួបការលំបាកខ្លាំងណាស់ គឺខ្វះខាតសព្វយ៉ាង គ្មានអ្វីហូបឡើយ។

នៅឆ្នាំ១៩៧៦ ពួកខ្មែរក្រហមចាប់ផ្តើមបែងចែកមនុស្សជាក្រុមៗ។ ក្មេងៗ ពួកវាប្រមូលចាត់ជាកងកុមារ រីឯមនុស្សធំៗ ពួកវាចាត់ជាកងចល័ត និងចាស់ៗ ពួកវាប្រមូលចាត់ជាកងសហករ។ ដោយឡែកខ្ញុំ ត្រូវពួកវាបញ្ជូនឲ្យមកនៅជាមួយប្រធានកងនារីឈ្មោះ សារិត នៅតំបន់ភូមិភាគបច្ចិម។ «មិត្តបងសារិត» បានអោយខ្ញុំជីកដីលើកទំនប់ប្រឡាយ ធ្វើការងារតាំងពីព្រលឹមទល់ព្រលប់។ ខ្ញុំមិនដែលបានហូបឆ្អែតទេ។ ខ្ញុំធ្លាក់ខ្លួនឈឺស្គមស្លេកស្លាំង។

មានថ្ងៃមួយតាសន ដែលនៅសហករជាមួយម្តាយខ្ញុំ បានមកដឹកដើមចេក រួចបានប្រាប់ខ្ញុំថា «សុខុម! ម៉េចមិនទៅមើលយាយតាឯងផង! ឥឡូវនេះយាយតាឯងឈឺខ្លាំងណាស់ ដាច់បាយដាច់ទឹកហើយ»។ ពេលនោះខ្ញុំបានសុំច្បាប់មិត្តបងសារិតដែរ តែមិត្តសារិតមិនឲ្យ ហើយនិយាយថា «មិត្តឯងពេទ្យឬអី! បានទៅមើលហ្នឹង មើលវាមិនជា នាំតែខាតការងារទេ»។ ដោយការបារម្ភពីយាយតា ខ្ញុំក៏បានលួចរត់ចេញមកមើលគាត់។ ពេលបាត់ខ្ញុំ «មិត្តនារីសារិត»ដឹងថាខ្ញុំលួចរត់ វាក៏អោយកងឈ្លប ៣នាក់ អាយុប្រហែល១៥ទៅ១៧ឆ្នាំ មកតាមចាប់ខ្ញុំនៅតាមផ្លូវ។ ពួកវាបានចាប់ខ្ញុំចង រួចវាយបណ្តើរខ្ញុំ អូសខ្ញុំត្រឡប់ត្រឡិន តាមអាចមន៍បំនាស់ដីស្រែទើបនឹងភ្ជួរហើយ។ ពួកវាចោទខ្ញុំថា«ខ្មាំង»ក្បត់អង្គការ ខ្ជិលគេចពីការងាររបស់អង្គការ។ ពួកវា បានចាប់ខ្ញុំចងជាប់នៅនឹងជើងគ្រែ កន្លែងពួកវាដេក។ វាបង្អត់បាយខ្ញុំ វាយខ្ញុំនឹងខ្សែតី ហើយចាក់ខ្ញុំនឹងជ្រលួញខ្សែតី។ ពួកវានិយាយថា «ជើងហ្នឹងពូកែរត់ហ្មេះ! អញវាយកុំអោយរត់ទៀត! បើរត់ទៀត អញ

វាយបំបាក់ជើងហើយ»។ ពេលនោះខ្ញុំភ័យខ្លាំងណាស់។ ខ្ញុំឈឺចាប់និងមានស្នាមកន្ទួលពាសពេញខ្លួន ព្រមទាំងមានរបួសកែងជើងទៀតផង។ ពួកវាបានដាក់ទណ្ឌកម្មខ្ញុំ ឲ្យរកជីរលេខ១។ ពួកវាអោយខ្ញុំបារលាមកដោយដៃផ្ទាល់មិនអោយយកអ្វីផ្សេងកើបឡើយ បើពុំធ្វើតាមវាទេ វានឹងវាយធ្វើបាបខ្ញុំ។

ថ្ងៃមួយ ពេលខ្ញុំធ្វើការអស់កំលាំងខ្លាំងផង ឃ្លានផង ខ្ញុំបានលាក់ខ្លួនក្នុងចំការដំឡូងមី។ ពេលតាមរកខ្ញុំឃើញនៅក្នុងចំការនោះ ពួកវាបានវាយ ទាត់ធាក់ទះកំផ្លៀងខ្ញុំ។ ពួកវាបានបណ្តើរខ្ញុំមកកាន់រោង ហើយប្រជុំសំរេចបញ្ជូនខ្ញុំទៅកាន់កន្លែងផ្សេង។ ពួកវាបានដាក់កំហិតអោយខ្ញុំជីកដី ១ថ្ងៃ ឲ្យបាន ១ម៉ែត្រគូប។ ខ្ញុំស្គមហេវហត់ អស់កំលាំងល្វិតល្វៃ ស្ទើរស្លាប់ ស្ទើររស់។ ខ្ញុំឃ្លានខ្លាំងណាស់។ មានពេលខ្លះខ្ញុំបានចាប់កន្ទ្រុបកន្ទូប បង្កួយ ថ្លែន ដុតពោលៗ លួចលាក់ស៊ី ទាំងភ័យខ្លាចពួកវាមកទាន់។ ការលើកទំនប់ជីកដីបានបញ្ចប់។ ពួកវាបានឲ្យខ្ញុំទៅស្ទូងស្រូវ ដាក់ក្នុងជួរពោតឲ្យត្រង់ដូចបន្ទាត់។ បើមិនត្រង់ពួកវាដើរដកចោល រួចឲ្យស្ទូងសារជាថ្មីនិងវាយក្រញ៉ាំដៃ។ ខ្ញុំបានជួបការលំបាកខ្លាំងណាស់។ ពួកវាវាយធ្វើបាបមិត្តនារីៗ ក្នុងកងចល័តខ្ញុំជារឿយៗ។ ដោយមើលឃើញដូច្នោះ ខ្ញុំបានខិតខំធ្វើការខ្លាំងជាងមុន។

នៅឆ្នាំ១៩៧៧ ខ្ញុំបានដំណឹងថា គេយកម្តាយខ្ញុំទៅរៀនសូត្រ។ ខ្ញុំគិតភ្លាមថាគេមុខជាយកម្តាយខ្ញុំទៅសំលាប់ហើយ។ ពេលនោះខ្ញុំក៏រត់ទៅមើលម្តាយខ្ញុំនៅឯផ្ទះ។ ពេលបានមកដល់ផ្ទះ ខ្ញុំបានជួបគាត់។ គាត់បានដាំបាយអោយខ្ញុំហូប។ គ្រាន់តែហូបបាយបាន ២ ទៅ៣ ស្លាបព្រាប៉ុណ្ណោះ ពួកកងឈ្លបបានមកដល់ ហើយចាប់ខ្ញុំចងបណ្តើរយកត្រឡប់ទៅកន្លែងវិញ។ មកដល់កន្លែងវិញ ពួកវាបានដាំបាយ មានសម្លម្ជូរសាច់ឲ្យនាងខ្ញុំហូបជាមួយនារីៗ ចំនួន១០នាក់ ផ្សេងទៀត។ ខ្ញុំត្រេកអរណាស់ ត្បិតអី ខ្ញុំមិនដែលបានបាយហូបឆ្ងាញ់បែបនេះទេ។ លុះគ្រាន់តែហូបបាយរួច ប្រហែលជានៅម៉ោង៨យប់ ពួកវាបានប្រើឲ្យទៅកាប់រណ្តៅ ហើយយកក្រម៉ាចងមុខពួកយើងទាំងអស់គ្នា ដឹកបណ្តើរ ចូលទៅក្នុងព្រៃ

តាមមាត់អូរមួយ។ ពេលនោះខ្ញុំគិតថា ពួកវាមិនយកពួកយើងទៅសម្លាប់ទេ ព្រោះពួកវាបានអោយយើងហូបឆ្អាញ់ហើយឆ្អែតទៀត។ ពេលមកដល់កន្លែងគោលដៅពួកវាបានស្រាយក្រម៉ាពីមុខរបស់ខ្ញុំ ហើយបំបែកពួកយើងឆ្ងាយៗពីគ្នា។ វាបានសំឡុតគំរាមខ្ញុំឲ្យកាប់រណ្តៅហើយប្រាប់កុំឲ្យសួរ។ វាបានអង្គុយមើលខ្ញុំកាប់ដី យ៉ាងកាចសាហាវ។ គ្រាន់តែខ្ញុំកាប់រណ្តៅរួច វាស្ទុះមកវាយខ្ញុំនឹងស្ទ័យកាំភ្លើង នៅត្រង់ក្បាលជង្គងទាំងពីរ ធ្វើឲ្យខ្ញុំដួលគ្រឹបទៅដី រួចវាស្ទុះមកវាយបន្ថែមត្រង់ញ៉ឹងក និងត្រង់បោះដៃផុតទៀត។ ពេលនោះខ្ញុំគិតថាខ្លួនខ្ញុំស្លាប់ហើយ។ ខ្ញុំភ័យខ្លាចយ៉ាងខ្លាំង ខ្ញុំបាននឹកគុណដល់ព្រលឹងដូនតា អារុកអារក្សអ្នកតា ម្ចាស់ព្រៃព្រឹក្សា សូមឲ្យមកជួយខ្ញុំផង។ ពេលខ្ញុំដឹងខ្លួនវិញស្រាប់តែខ្ញុំស្ថិតនៅក្នុងផ្ទះអ្នកស្រុកម្នាក់ដែលបានជួយសង្គ្រោះជីវិតខ្ញុំ។ គាត់បានរៀបរាប់ប្រាប់ខ្ញុំថា នៅពេលគាត់កំពុងបង់សំណាញ់នៅតាមអូរ យកត្រីដាក់ក្នុងសហករគាត់ឮសំលេងស្រែកឲ្យជួយ។ ពេលនោះគាត់ក៏ដើរមករកសម្លេង ហើយឃើញខ្ញុំនៅមានដង្ហើមនៅឡើយ។ គាត់ក៏បានយកខ្ញុំមកផ្ទះគាត់ បញ្ចុកថ្នាំនិងទឹកបបរ។ ខ្ញុំសន្លប់អស់រយៈពេល១យប់១ថ្ងៃ។ នាងខ្ញុំបានរស់នៅជាមួយឪពុកចិញ្ចឹមរហូតដល់ថ្ងៃរំដោះ ដោយសារលាក់ប្រវត្តិរបស់ខ្លួនខ្ញុំ និងម្យ៉ាងទៀត ដោយសារពួកវាយល់ថា រូបខ្ញុំស្លាប់ទៅហើយ ទើបពួកវាលែងតាមរកនាងខ្ញុំទៀត។

ឆ្នាំ១៩៧៨ មានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំងរវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម។ ក្នុងការប្រយុទ្ធគ្នាយ៉ាងសាហាវនោះ មានមនុស្សរបួសស្លាប់ដោយការបាញ់សំដៅមកភូមិ ដែលមានហ្វូងប្រជាជនរស់នៅ។ ពេលនោះខ្ញុំក៏នៅទីនោះដែរ។ ខ្ញុំភ័យញ័រខ្លួន ព្រោះខ្ញុំស្ថិតនៅក្នុងសមរភូមិប្រយុទ្ធគ្នា។ ខ្ញុំភ័យស្លន់ស្លោរត់ឆ្វេឆ្វាគេចពីគ្រាប់កាំភ្លើងផង រកច្រកចេញពីកងទ័ពផង។ គ្រាប់កាំភ្លើងបានបាញ់រះឆ្លងពីលើក្បាលខ្ញុំ។ ខ្ញុំភ័យព្រលឹងនៅចុងសក់។ ខ្ញុំមិននឹកស្មានថា ខ្ញុំសំណាងបានរស់ម្តងហើយម្តងទៀតនោះទេ។ ខ្ញុំបានរត់កាត់គ្រាប់កាំភ្លើង ទៅរកក្រុមគ្រួសារទាំងគ្មានស្គាល់នរណាម្នាក់សោះ។ ក្នុងដំណើរតាមផ្លូវ

ខ្ញុំបានជួបសាកសពនិងមនុស្សរបួសហូរឈាមពាសពេញផ្លូវ។

បន្ទាប់ពីបានជួបជុំគ្រួសារវិញ ពួកយើងបានវិលត្រឡប់មករស់នៅខេត្តកំពង់ស្ពឺរហូតមក។

ទោះបីជារបបកម្ពុជាប្រជាធិបតេយ្យរបស់ប៉ុលពតបានកន្លងទៅជាង៣០ឆ្នាំហើយក្តី តែបទពិសោធន៍ជីវិតដ៏សែនឈឺចាប់របស់ខ្ញុំ នៅតែដក់ជាប់ក្នុងការចងចាំរបស់ខ្ញុំជានិច្ច។ ខ្ញុំនៅតែមានអារម្មណ៍ភ័យខ្លាច ហើយឈឺចាប់នឹងអ្វីដែលខ្ញុំបានឆ្លងកាត់ បានឃើញ ដោយផ្ទាល់ភ្នែក ជាពិសេសទង្វើរដ៏យង់ឃ្នងរបស់ពួកប៉ុលពត ដែលបានធ្វើបាបប្រជាជនស្លូតត្រង់ រួមនិងសាច់ញាតិរបស់ខ្ញុំដែលស្លាប់ទៅដោយគ្មានកំហុសអ្វីសោះ។

នាងខ្ញុំបានដាក់ពាក្យបណ្តឹងទៅសាលាក្តីខ្មែរក្រហមក្នុងឆ្នាំ ២០០៥ ក្នុងសំណុំរឿង ០០២ ដើម្បីយុត្តិធម៌ សម្រាប់ខ្លួនឯងផង និងសំរាប់សាច់ញាត្តិដែលស្លាប់ទៅផង។ នាងខ្ញុំចង់បានសំណងជារួមខ្លះ ដូចជា មន្ទីរពេទ្យសម្រាប់ព្យាបាលជម្ងឺផ្លូវចិត្ត សាងសង់ជាសារមន្ទីរ ដើម្បីដាក់ឯកសាររឿងរ៉ាវនាងខ្ញុំរួចសរសេរឈ្មោះអ្នកដែលបាត់បង់ជីវិតទៅក្នុងសម័យខ្មែរក្រហម។

នាងខ្ញុំសូមឧទ្ទិសសក្ខីកម្មដែលនាងខ្ញុំបានបង្កើតឡើងនេះដល់វិញ្ញាណក្ខ័ន្ធអ្នកស្លាប់ទៅ ដូចមានរាយនាមខាងក្រោម៖

- ស្វាមីឈ្មោះ ឆាវ ឆាយ ស្លាប់ដោយសារជំងឺ
- កូនប្រុសឈ្មោះ ឆាយ ឆន ស្លាប់ដោយសារជំងឺ
- កូនស្រីឈ្មោះ ឆាយ សុខា ស្លាប់ដោយសារជំងឺ
- អ្នកមីងឈ្មោះ ធុច ឃឿន ស្លាប់ដោយសារសម័យខ្មែរក្រហម
- អ្នកមីងឈ្មោះ ធុច យ៉ន ស្លាប់ដោយសារសម័យខ្មែរក្រហម
- លោក យាយ ដា ស្លាប់ដោយសារសម័យខ្មែរក្រហម
- លោក ពូ ជា ស្លាប់ដោយសារសម័យខ្មែរក្រហម
- លោក តា ធុច ស្លាប់ដោយសារសម័យខ្មែរក្រហម

អ្នកផ្តល់សក្ខីកម្ម៖ ហឿន សុខុម
អ្នកផ្តល់ប្រឹក្សា៖ ម៉ែន សុខន
ភ្នំពេញ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤



ការផលិតជីមានលាយលាមកមនុស្ស គឺជាកិច្ចការមួយក្នុងចំណោមកិច្ចការជាច្រើនទៀតដែលខ្មែរក្រហមបានបង្ខំមកលើប្រជាជន។ «ទាហានខ្មែរក្រហមបង្ខំខ្ញុំឲ្យធ្វើការជាទម្ងន់ ហើយនិងផលិតជី។ ជីនោះធ្វើពី ផេះ ឆ្អឹង និងលាមកមនុស្ស។ ក្នុងគំនូរនេះ អ្នកឃើញថា មេគុកបង្ខំខ្ញុំឲ្យស៊ីជីនោះរួចឲ្យប្រាប់វាថាមានរសជាតិដូចម្ដេច។ ខ្ញុំបាននិយាយថា វាមានរសជាតិល្អ» លោក ស៊ុំ រិទ្ធី ប្រាប់ថាដូច្នេះ។

# អ៊ុន អឿន

## ឈ្មោះហៅក្រៅ «ត្រេន» អាយុ ៦៣ ឆ្នាំ រៀបការរួច កសិករ នៅខេត្តកំពង់ស្ពឺ

**អឿន** ជាកូនម្នាក់ក្នុងចំណោម៨នាក់ នៃគ្រួសារកសិករមួយ មានអនុស្សាវរីយ៍រីករាយជាច្រើនក្នុងទស្សវត្សទី៦០។ ចាប់តាំងពីឆ្នាំ ១៩៧០ មក លទ្ធិកុម្មុយនិស្តបានរីកសាយភាយទូទាំងប្រទេសកម្ពុជា ហើយក៏បានមកដល់ភូមិរបស់គាត់។ ទាំងបុរសទាំងស្ត្រី ក្នុងភូមិត្រូវគេបង្ខំឲ្យទទួលយកលទ្ធិនោះ ហើយធ្វើការងារតាមតួនាទីដែលគេបង្កើតឲ្យ ដោយគ្មានឲ្យប្រកែកឡើយ។ ក្នុងទំនៀមទម្លាប់ខ្មែរ ឪពុកម្តាយគាត់ បានរៀបចំអាពាហ៍ពិពាហ៍មួយឲ្យគាត់ ហើយគាត់ត្រូវទៅរស់នៅក្នុងគ្រួសារខាងប្រពន្ធគាត់។ នៅឆ្នាំ ១៩៧៣ និង ១៩៧៤ តាមចាត់តាំងឲ្យធ្វើដោយខ្មែរក្រហម គាត់បានធ្វើការជាប្រធានក្រុមទទួលខុសត្រូវប្រជាជនមូលដ្ឋាន ចំនួន១០គ្រួសារ ជាអ្វីដែលគាត់មិនចង់ឡើយ ប៉ុន្តែមិនអាចប្រកែកបាន។ បើកាលនោះគាត់បានប្រកែក គាត់ទំនងជាត្រូវចោទថា គាត់ជាបណ្តាញរបស់ខ្មាំង និងមិនគោរពតាមអង្គការ។ អ្វីៗបានត្រឡប់ក្លាមៗ ទៅជាអាក្រក់ ចាប់តាំងពីឆ្នាំ១៩៧៥ នោះរហូតមក។

# សក្ខីកម្មរបស់ខ្ញុំ

ឆ្នាំ ១៩៧៥ ខ្ញុំបានឮដំណឹងថា ពួកខ្មែរក្រហមបានជម្លៀសឪពុកម្តាយនិងប្អូនខ្ញុំឲ្យចេញពីភូមិកំណើត។ ពួកគេបានចាត់ទុកក្រុមគ្រួសារខ្ញុំជា ប្រជាជនថ្មី ឬជាពួក១៧មេសា គឺពួកគេបានបែងចែកនិន្នាការដាច់ដោយឡែកពីគេ ដោយសារខ្ញុំមិនមែនជាប្រជាជនមូលដ្ឋាន ហើយក៏មិនមាន កំណើតនៅទីនោះដូចប្រពន្ធខ្ញុំ។ ចំណែកឯការងារជាមេក្រុម ក៏បានត្រូវបញ្ចប់ចាប់ពីថ្ងៃនោះមកដែរ។ ពេលនោះហើយដែលជួយឲ្យខ្ញុំកាន់តែយល់នូវអ្វីដែលកំពុងកើតឡើងនាពេលនោះ ខ្ញុំបានលួចសង្កេត ហើយកត់ចំណាំក្នុងចិត្តនូវរាល់សកម្មភាព និងទង្វើរបស់ពួកខ្មែរក្រហមចាប់ពីពេលនោះមក។ មនុស្សទាំងអស់ (គេនិងខ្ញុំ)ម្នាក់ៗ ហាក់គ្មានជំហរ គ្មានភាពជាមនុស្សផ្ទាល់ខ្លួនទាល់តែសោះ។ យើងបានបាត់បង់ភាពម្ចាស់ការសំរាប់ខ្លួនឯង។ យើងមិនអាចធ្វើអ្វីបានក្រៅពីការគោរពតាមរបៀបចាត់តាំង ឬការបញ្ជារបស់បក្សខ្មែរក្រហមឡើយ។ គេបានចាត់ឲ្យខ្ញុំទៅធ្វើស្រែ ដក-ស្ទូង-ភ្ជួរ-រាស់ ដូចបុរសឯទៀតដែរ។ ថ្ងៃណាក៏ដូចជាថ្ងៃណាដែរ ពួកគេគិតតែប្រាប់ឲ្យមនុស្សទាំងអស់ ធ្វើឲ្យបានតាមផែនការរបស់ពួកគេកំណត់ឲ្យ ឬគេហៅថា៖ «អង្គការបានលើកទិសឲ្យ»។ ដើម្បីរស់ជីវិតនិងអាចគេចផុតពីការសម្លាប់ យើងត្រូវតែជ្រមុជក្បាលធ្វើការ។

ឆ្នាំ១៩៧៦ ពួកគេបញ្ជាឲ្យខ្ញុំនិងបុរសជាច្រើននាក់ ទៅធ្វើការនៅសមរភូមិគឺការងារលើកទំនប់-ជីកប្រឡាយ។ ម្នាក់ៗត្រូវធ្វើឲ្យបានគ្រប់ផែនការដែលអង្គការបានដាក់ទិសឲ្យ។ បើមិនដូចច្នោះ គេនឹងបង្អត់អាហារមិនឲ្យយើងហូបទេ ឬក៏ត្រូវគេចោទថាជាខ្មាំងប្រតិកិរិយា ពួកសក្តិភូមិ ឬ ជាអ្នកយកការណ៍របស់«ក្រុមសេអ៊ីអា អាមេរិកកាំង»មិនខានឡើយ។ ការងារនឿយហត់គ្មានពេលសំរាក។

ខ្ញុំអាចធ្វើបានគ្រប់យ៉ាង ទោះជានៅក្រោមកំដៅថ្ងៃហួតហែង ឬ ក្រោមដំណក់ទឹកភ្លៀងជោគជាំយ៉ាងណាក៏ដោយ ខ្ញុំសុំតែម៉្យាង«កុំឲ្យគេសម្លាប់»តែប៉ុណ្ណោះ។

ខ្ញុំកាន់តែមើលឃើញ ការប្រព្រឹត្តបែបអមនុស្សធម៌ និងទង្វើដ៏សាហាវរបស់ពួកខ្មែរក្រហមច្បាស់ឡើងៗ។ ឥឡូវនេះ ធ្វើឲ្យខ្ញុំផ្ដើមនឹកគិតអំពីតម្លៃមនុស្សជាតិ ថាតើអាចទ្រាំបានដល់ពេលណា?។ ខ្ញុំមិនហ៊ានតបតទៅគេវិញទេ ប៉ុន្តែខ្ញុំក៏ចង់មានសេរីភាពជាមនុស្សផងដែរ។

ឆ្នាំ១៩៧៧ ការងារផ្អែកទៅលើកសិកម្មប្រើមនុស្សដូចជាគ្រឿងយន្ត។ កាន់តែគិតគឺកាន់តែភ័យខ្លាចនិង ព្រួយបារម្ភចំពោះការប្រព្រឹត្តរបស់ពួកខ្មែរក្រហម តើពួកគេជាមេឃាតករឬ?

មានអ្នកជំងឺជាច្រើន ឈឺដោយសារបាក់កម្លាំងព្រោះ អត់អាហារ អ្នកខ្លះមានជងឺគ្រុនចាញ់-គ្រុនក្ដៅនិងជំងឺផ្សេងៗ។ បើមើលទៅមន្ទីពេទ្យវិញ ទើបដឹងថាជាពេទ្យអត់គ្រូពេទ្យជំនាញ។ អត់មានថ្នាំព្យាបាលនិងគ្មានការយកចិត្តទុកដាក់ចំពោះអ្នកជំងឺ។ ខ្ញុំតែងបន់ស្រន់កុំឲ្យខ្ញុំឈឺ។

នៅឯនាយភូមិ ស្នូរសម្លេងរគាំងរោរ៍ព្រទ្រហឹង ជាសញ្ញាថាដល់ម៉ោងហូបបាយថ្ងៃត្រង់ហើយ។ យើងហូបបបររាវៗជាមួយគ្រាប់អំបិល។ ជួនមានសំណាងបានពងទាស្ងោរ១គ្រាប់ ពុះជា៨ចំណែកសំរាប់មនុស្ស៨នាក់។ ខ្ញុំមានអារម្មណ៍ស្រេកឃ្លានណាស់។ គំនិតចង់ផ្អែត វាបានប្រទាញគ្នាចុះឡើង ជាមួយបំរាមដាច់ខាតរបស់ចុងភៅរោងបាយ ធ្វើឲ្យស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន។

ភាពវងគ្រោះជាអ្នកទោសរបស់អង្គការខ្មែរក្រហម និង នៅជារៀងរហូតមក។ ឥឡូវនេះបានជិត៣ឆ្នាំហើយ។ វាពិតជាមានការពិបាកខ្លាំងណាស់ រស់ដូចស្លាប់ ។ បើដេកបានមួយយប់ គឺយើងរស់បានមួយថ្ងៃ។ ការងារកាន់តែច្រើននិងមានលក្ខណៈធ្ងន់ធ្ងរ ហួសពីកម្លាំងដែលអាចធ្វើបាន។ អាហារកាន់តែខ្សត់ ខ្វះខាតគ្រប់ពេលវេលា។ បើមានក៏ពួកគេមិនឲ្យយើងហូបដែរ។ ម្នាក់ៗរស់ក្នុងស្ថានភាព

ភ័យខ្លាចគ្រប់វិនាទី។ ការកាត់ផ្តាច់មនោសញ្ចេតនា រវាងក្រុមគ្រួសាររយៈពេល ៣ឆ្នាំ មកហើយ យើងគ្មានព័ត៌មាន គ្មានសិទ្ធិសេរីភាពនិងគ្មានអ្វីៗទាំងអស់។

ឆ្នាំ១៩៧៨(ដើមឆ្នាំ) ពួកគេបានចាត់តាំងឲ្យខ្ញុំទៅឃ្វាលគោចំនួន១២០ ក្បាល ។ នៅពេលរសៀលនាថ្ងៃមួយ ខ្ញុំបានបាត់គោចំនួន២ក្បាល។ លុះត្រឡប់ទៅភូមិវិញ ខ្ញុំបានទទួលការស្តីបន្ទោស និងដាក់កំហិតពីអង្គការ ឲ្យខ្ញុំទៅរកគោឲ្យខាងតែឃើញ។ បើពុំនោះទេគេនឹងដាក់ទោសវិន័យខ្ញុំ។ គេចោទថា ខ្ញុំជាខ្សែរយៈខ្មាំង រួមផ្សំគំនិតចង់បង្ករឲ្យមានបញ្ហាដល់អង្គការ។ គេថាខ្ញុំជាមនុស្សខ្ជិល មានសតិអារម្មណ៍ចង់ក្បត់នឹងអង្គការ។ ១ខែក្រោយមកគោបាត់នោះបានរកឃើញវិញ។ ពួកគេបានលើកលែងកំហុសឲ្យខ្ញុំ ប៉ុន្តែគេមិនឲ្យខ្ញុំនៅភូមិទេ។ គេចាត់ឲ្យខ្ញុំទៅធ្វើការជីកប្រឡាយ-លើកទំនប់ ឆ្ងាយពីប្រពន្ធកូន។

ឆ្នាំ១៩៧៩ ប្រជានជនថ្មី-ចាស់លួចខ្សឹបខ្សៀវគ្នា អំពីស្ថានភាពរបស់ប្រទេសជាតិ។ នេះហើយជាការរង់ចាំរបស់ប្រជាជនកម្ពុជាគ្រប់រូប ដែលជាជនរងគ្រោះក្នុងរបបដ៏សែនអាក្រក់នេះ(ខ្មែរក្រហម)។ ទិដ្ឋិភាពក្នុងពេលនោះច្របូកច្របល់ណាស់។ មនុស្សម្នាស្រីប្រុស ទៅមកដោយទឹកមុខសប្បាយរីករាយ។ ខ្ញុំត្រេកអរណាស់។ ខ្ញុំរត់រហូតទៅដល់ភូមិដែលប្រពន្ធកូនកំពុងរស់នៅ។ ប្រមូលបានរទេះចាស់មួយនិងគោស្គមៗពីរក្បាល ផ្ទុកប្រពន្ធនិងកូនបរចេញទៅជាមួយគេឯងដែរ។ ការសម្រេចចិត្តនិងជាបំណងរបស់ខ្ញុំ គឺទៅរកពុក-ម៉ែ-និងប្អូនៗ នៅឯស្រុកកំណើតរបស់ខ្ញុំវិញ។ ១ថ្ងៃបន្ទាប់មក បានទៅដល់ស្រុកកំណើត។ ដំណឹងដែលរន្ធត់ស្រក់ទឹកភ្នែកគឺ ម៉ែនិងប្អូនៗ៦នាក់ បានស្លាប់នៅក្នុងរបបរបស់ខ្មែរក្រហមអស់ហើយ។ វាជាការស្លាប់ដ៏អាក្រក់បំផុតក្នុងលោកនេះ។ ពួកខ្មែរក្រហមបានបង្អត់អាហារ ធ្វើឲ្យពួកគាត់ឈឺបាក់កម្លាំង ដាច់ពោះស្លាប់។

ទោះជាជាង៣៥ឆ្នាំមកហើយក្តី អ្វីដែលជារូបភាពឈឺចាប់ ទុក្ខសោក អំពីការព្រាត់ប្រាស់ក្រុមគ្រួសារ នៅតែដក់ជាប់ក្នុងអារម្មណ៍ខ្ញុំជានិច្ច។

ដើម្បីបន្ធូរការឈឺចាប់ទាំងនេះ ខ្ញុំបាទ អ៊ុន អឿន បានដាក់ពាក្យបណ្ដឹង ទៅសាលាក្ដីខ្មែរក្រហម (អវតក) សុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២ រួចមានការទទួលស្គាល់ពីមេធាវី និងពីស្ថាប័នអង្គការមិនមែនរដ្ឋាភិបាល ហើយអាជ្ញាធរមូលដ្ឋានក៏បានជួយគាំទ្រដល់ខ្ញុំបាទជាជនរងគ្រោះ និងជាជនរួចរស់ជីវិតពីការសម្លាប់របស់ពួកខ្មែរក្រហម។

ខ្ញុំសូមអរគុណ! ដ៏ជ្រាលជ្រៅចំពោះអង្គការឌីភីអូ និងស្ថាប័នអង្គការទាំងអស់ដែលបានជួយគាំទ្រខ្ញុំ។ ខ្ញុំសូមអរគុណដល់ សាលាក្ដី(អវតក) ដែលបានខិតខំធ្វើការងារ ក្នុងតួនាទីរបស់ខ្លួនបានយ៉ាងសកម្ម។ សំណូមពរចុងក្រោយរបស់ខ្ញុំបាទ មានដូចជា៖

- សូមតុលាការ ជួយពន្លឿនពេលវេលាកាត់ក្ដីឲ្យបានឆាប់រហ័ស (ជនត្រូវចោទកាន់តែចាស់ៗហើយ)
- ស្នើឲ្យសាងសង់ជាសាលាសំណាក់មួយខ្នង នៅកន្លែងស្តូបអនុស្សាវរីយ៍ (វាលពិឃាត ជើងឯក) ទុកជាទីគោរពបូជា និងជាកន្លែងសំរាប់ជួបជុំជនរងគ្រោះដោយរបបខ្មែរក្រហម។

ខ្ញុំសូមឧទ្ទិសដល់ វិញ្ញាណក្ខន្ធលោកឪពុកអ្នកម្ដាយ បងប្អូនប្រុសស្រី មានឈ្មោះដូចខាងក្រោម៖

- អ្នកម៉ែ អឹម ណាន
- លោកពុក អ៊ុន ឯក
- កូនប្រុស អ៊ុន ហាក់
- ប្អូនស្រី អ៊ុន នឿង
- ប្អូនស្រី អ៊ុន សឹម
- ប្អូនស្រី អ៊ុន លឹម និងប្អូនស្រី ២នាក់ទៀតដែលខ្ញុំមិនចាំឈ្មោះ

សូមឲ្យព្រលឹងប្រជាជនខ្មែរឯទៀត ដែលបានស្លាប់ក្នុងសម័យខ្មែរក្រហម មកទទួលនូវកុសលផលទាននេះយកទៅកាន់សុគតិភព និងប្រាថ្នាកុំឲ្យខ្ញុំអភ័ព្វដូចជាតិនេះទៀត រួចសូមបែរក្រោយឲ្យពរជ័យ មកដល់កូនចៅដែលកំពុងតែរស់នៅ ឲ្យបានសេចក្ដីសុខអាយុយឺនយូរ មានទ្រព្យ មានយស ជាអង្វែងទៅ។

អ្នកផ្ដល់សក្ខីកម្ម៖ អ៊ុន អឿន
អ្នកផ្ដល់ប្រឹក្សា៖ ឆាយ ម៉ារីជែត
ភ្នំពេញ ថ្ងៃទី០៦ កុម្ភៈ ឆ្នាំ ២០១៤



នៅក្នុងគំនូរដោយខ្មៅដៃនិងគំនូរផាត់ពណ៌របស់គាត់ លោក ស៊ុំ រិទ្ធី បានរំលេចមកវិញនូវរូបភាពនានានៃជីវភាពក្នុងពន្ធនាគារក្នុងសម័យខ្មែរក្រហម មានដូចជា៖ «នេះអ្នកឃើញកម្មាភិបាលខ្មែរក្រហម បណ្តើរអ្នកទោសឆ្ពោះទៅវគ្គជម្មឃុត្តិ ដើម្បីសួរចម្លើយ អ្នកទោស៨នាក់ពីរជងក្នុង១ថ្ងៃ»។

# ដោត សុខគីន

## អាយុ ៥៩ឆ្នាំ ជាកសិករ មានប្តី និង កូនស្រីចំនួន៣នាក់ រស់នៅខេត្តកំពង់ស្ពឺ។

**សុខគីន** គឺជាកូនពៅគួរឲ្យស្រឡាញ់ នៃគ្រួសារកសិករក្រីក្រមួយ ដែលមានកូន ១០នាក់។ ឪពុកនាងបានចងកសម្លាប់ខ្លួនពេលនាងនៅកុមារនៅឡើយ ដោយសារគាត់ជួបការលំបាកក្នុងជីវិតធ្ងន់ធ្ងរ គឺមានបន្ទុកចិញ្ចឹមកូន១០នាក់ រួមនិងស្ថានភាពសេដ្ឋកិច្ចគ្រួសារជួបការលំបាកខ្លាំង ក្រោយពីប្រពន្ធគាត់ធ្លាក់ខ្លួនឈឺធ្ងន់មក។ ក្នុងឆ្នាំ ១៩៧០ បងប្អូនរបស់សុខគីនបានរៀបការរួចបែកចេញទៅអស់ នៅសល់តែនាងរស់នៅផ្ទះជាមួយម្តាយ។ ឆ្នាំ១៩៧២ ខ្មែរក្រហមបានចាប់ខ្លួនបងប្រុសទី១របស់នាង រួចសម្លាប់គាត់ទៅ។ សំណាងអាក្រក់ដូចគ្នាបានមកដល់ បងប្រុសទី៤របស់នាងក៏ត្រូវបានខ្មែរក្រហមសម្លាប់។ បន្ទាប់មក ម្តាយក្មេករបស់បងប្រុសនាង បងថ្លៃស្រី និងក្មួយស្រីរបស់នាង ត្រូវខ្មែរក្រហមកៀរជម្លៀសយកទៅខេត្តពោធិ៍សាត់ រួចក៏សម្លាប់ពួកគាត់នៅទីនោះទៅ។ ហេតុការណ៍ទាំងនោះ បានកើតឡើងមុនពេលពួកខ្មែរក្រហមវាយលុកចូលមកដល់ភូមិដែលសុខគីនរស់នៅនាឆ្នាំ១៩៧៥។

# សក្ខីកម្មរបស់ខ្ញុំ

ក្នុងឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានចូលលុកលុយពេញក្នុងភូមិ ដោយបាញ់រះ ហើយបណ្ដេញ ប្រជាជនឲ្យចាកចេញពីផ្ទះសម្បែង ទ្រព្យសម្បត្តិ គោ ក្របី ជាដើម។ គ្រួសារខ្ញុំបានធ្វើដំណើរពីភូមិមួយ ទៅភូមិមួយ។ គេបង្ខំខ្ញុំឲ្យទៅជីក ប្រឡាយ ជីកទំនប់ ធ្វើការរួមជាមួយអ្នកភូមិផ្សេងៗទៀត។ គេចែកអង្ករតាមផ្ទះ (៥នាក់បាន៣-៥ស្លាបព្រាតែប៉ុណ្ណោះ)។ ដូច្នេះហើយ ពួកខ្ញុំត្រូវហូបសន្សំសំចៃ គឺដាំជាបបររាវៗ។ ពេលនោះ ពួកយើងលំបាកវេទនាណាស់ រាងកាយហើម ឈឺ គ្រុនញាក់ រង្គោះសក់ ហើយនិង រាគរូសផងដែរ។

នៅឆ្នាំ១៩៧៦ គេជម្លៀសពួកខ្ញុំ – ដើរអស់រយៈពេល១០យប់ – ទៅខេត្តតាកែវ។ នៅតំបន់នោះមានសុទ្ធតែប្រជាជនខ្មែរកម្ពុជាក្រោមជាច្រើននាក់រស់នៅ។ ខ្ញុំបានស្នាក់នៅទីនោះជាមួយម្ដាយខ្ញុំ បានត្រឹមតែមួយយប់ប៉ុណ្ណោះ ក៏ត្រូវគេបំបែកចេញពីម្ដាយជាទីស្រលាញ់ និងពីបងប្អូនរបស់ខ្ញុំរហូតដល់ថ្ងៃរំដោះ។ គេបានបញ្ជូនខ្ញុំទៅកងចល័ត ធ្វើការនៅតាមការដ្ឋានពីតំបន់មួយទៅតំបន់មួយគ្មានឈប់ឈរ។ ពួកខ្មែរក្រហម បង្ខំអោយខ្ញុំជីកប្រឡាយ ៣ម៉ែត្រគូបក្នុងមួយថ្ងៃអោយរួច បើមិនរួចទេ គេមិនឲ្យបបរហូបឡើយ។ ពួកវាបុកខ្ញុំនឹងចំពុះទុង រហូតដល់រលាត់ស្បែក ជួនកាល វាយខ្ញុំនឹងស្នូកកាំភ្លើង ពេលតំរង់ជួរបើកបបរមិនបានត្រង់ជួរម្ដងៗ។ ពួកវាសាហាវព្រៃផ្សៃខ្លាំងណាស់។ ឯការហូបចុកវិញក៏មិនគ្រប់គ្រាន់ដែរ គឺមានតែបបរលាយត្រកួន ឬលាយព្រលិត ជារៀងរាល់ថ្ងៃ។ ពួកវាអោយខ្ញុំធ្វើការធ្ងន់ គឺឲ្យខ្ញុំគាស់គល់ឈើ កាប់ឆ្ការព្រៃ ដាំដំឡូង និងដកដំឡូង។

នៅឆ្នាំ១៩៧៧។ មេកងស្រី២នាក់ គឺមិត្តមុំ និងរិទ្ធិ បានមកប្រាប់ខ្ញុំនិងមិត្តនារីៗផ្សេងទៀតថា «ស្អែកយើងនឹងមានការប្រជុំប្ដេជ្ញា នៅម៉ោង៧ល្ងាច នៅរោងបបរ»។ លុះស្អែកឡើងពួកគេបានអោយសំពត់ខ្មៅ អាវខ្មៅ និងក្រមាក្រហមថ្មីមួយ សំរាប់ខ្ញុំដើម្បីពាក់នៅថ្ងៃនោះ។ នៅពេលព្រលប់មានឡានឃ្លុប (អាតោចិន) មួយគ្រឿងមកទទួលខ្ញុំនិងមិត្តនារី៦នាក់ទៀត។ បានពាក់កណ្ដាលផ្លូវក្បែរព្រៃចេក ខ្ញុំបានលួចរត់ចុះពីលើឡានចូលលាក់ខ្លួន ពួនក្នុងព្រៃចេកនោះអស់មួយយប់។ ខ្ញុំភ័យខ្លាចពួកខ្មែរក្រហមតាមទាន់ហើយចាប់យកទៅវៃចោលផងខ្លាចខ្មោចផង រាងកាយខ្ញុំឡើងញ័រចំប្រប់។ ពេលព្រឹកឡើងមានអ្នកស្រុកបានឃើញខ្ញុំ ពេលដែលពួកគាត់ចេញទៅធ្វើការ។ មានអ៊ំស្រីចិត្តល្អម្នាក់ បាននាំខ្ញុំទៅផ្ទះគាត់។ ពួកគាត់មើលថែខ្ញុំបានប្រហែល១ខែប៉ុណ្ណោះ ស្រាប់តែបែកការណ៍ដោយសារប្រធានភូមិនោះបានរាយការណ៍ប្រាប់មេកងនារី។ ពួកគេបានចាប់ខ្ញុំ។ រួចដាក់គុកខ្ញុំអស់ជិត១ខែ។ វាសួរចម្លើយបង្ខំអោយខ្ញុំរៀបការនិងបង្ខំឲ្យធ្វើការធ្ងន់ៗ។ ខ្ញុំមានអារម្មណ៍ថាពួកវាប្រាកដជាសម្លាប់ខ្ញុំហើយ។ ដោយការភ័យខ្លាចខ្ញុំបានយល់ព្រមរៀបគ្រួសារម្ដងទៀតដើម្បីរស់។ បន្ទាប់ពីយល់ព្រមជាមួយពួកវាហើយ មេកងនារីបានសួរខ្ញុំថា «មិត្តឯងមានឈាមរដូវឬទេ?»។ ដោយសារអាហារមិនគ្រប់គ្រាន់ និងរាងកាយស្គមស្គាំងផងនោះ ខ្ញុំពុំដែលមានឈាមរដូវអីម្ដងណាទេ។ ភ្លាមនោះផ្នែកសង្គមកិច្ចបានកាច់គ្រាប់កាំភ្លើងត្រាំជាមួយស្រាសយកមកអោយខ្ញុំនិងមិត្តនារីដទៃទៀតផឹក។ ដោយសារសារធាតុស្រានិងជាតិរំសេវ បានធ្វើឲ្យរាងកាយខ្ញុំឡើងក្ដៅ ប្រកាច់នោលពេញដី សន្លប់ក៏មានដែរ។ ប៉ុន្តែទោះបីជា ផឹកស្រាលាយគ្រាប់កាំភ្លើងយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែគ្មានរដូវដដែល។ ទន្ទឹមនឹងនោះដែរ ទោះមានរដូវឬគ្មានក៏មិនអាចគេចផុតឡើយ។ នៅល្ងាចនោះ គេបានរៀបចំរួចជាស្រេច។ នៅឯរោងបបរ មានចែកជាពីរជួរ ម្ខាងប្រុសនិងម្ខាងទៀតស្រី មានសរុបទាំងអស់៧គូ ឲ្យអង្គុយទល់មុខគ្នា មានចេកមួយស្និត ខ្នុរទុំ និងផ្លែស្វាយ។ ខ្ញុំត្រូវប្ដេជ្ញាចិត្តជាមួយ«មិត្តគុណ» ដែលខ្ញុំពុំដែល

ស្គាល់ពីមុនមកសោះ។ ខ្ញុំមានអារម្មណ៍ភ័យខ្លាច គ្មានតំលៃ បាត់បង់កត្តិយស គ្មានការទទួលដឹងឮពីមេបា ចាស់ទុំឡើយ។ ខ្ញុំបែកញើសពេញខ្លួន ញ័រដៃជើង មិនអាចធ្វើអ្វីបាន ក្រៅតែពីធ្វើតាមអ្វី ដែលគេប្រាប់ឲ្យធ្វើប៉ុណ្ណោះ។ បន្ទាប់ពីហូបបបររួចហើយ ពួកវាបានចែកផ្ទះខ្ទមឲ្យម្នាក់មួយៗ សំរាប់ស្នាក់នៅ។ យប់នោះខ្ញុំពុំបានព្រមជាមួយប្តីដែលប្តេជ្ញានោះទេ ព្រោះតែខ្ញុំមិនបានស្រលាញ់ គាត់ផង ហើយក៏មិនដឹងថាគួរធ្វើបែបណាផងនោះ។ ខ្ញុំបានរើុះ ប្រតាយប្រតប់គ្នាជាមួយគាត់រាល់យប់។ ខ្ញុំមានអារម្មណ៍ ខឹង ឈឺចាប់ ញ័រពេញខ្លួន មិនចង់ឲ្យមនុស្សប្រុសមកប៉ះ ឬនៅក្បែរខ្លួនខ្ញុំឡើយ។ ខ្ញុំធ្លាប់គិតចង់សំលាប់ខ្លួនផងដែរ។ ដោយភាពមិនចុះសំរុងគ្នានេះ ហើយត្រូវឈ្លបដឹង ពួកឈ្លបបានចាប់ខ្ញុំ នាំយកទៅកសាងចំនួន៤លើក។ ក្នុងមួយលើកៗ គេគំរាមកំហែងបង្ខំឲ្យខ្ញុំយល់ព្រមជាមួយប្តី តែខ្ញុំនៅតែមិនអាចទទួលយកគាត់បាន។ ខ្ញុំសុខចិត្តអោយគេសំលាប់ប្រសើរជាង។ ចុងក្រោយ ប្តីខ្ញុំបានរាយការណ៍ដល់ថ្នាក់លើ ហើយពេលនោះគេបញ្ជូនខ្ញុំទៅ ដើម្បីធ្វើទារុណកម្មឲ្យធ្ងន់ជាងមុន។ ពួកវាបានវាយធ្វើបាបខ្ញុំនឹងខ្សែតី ដំបងបង្ខំអោយខ្ញុំមូរជើងខោដល់ត្រឹមភ្លៅ រួចឲ្យខ្ញុំលូនរត់តាមភ្លឺស្រែ ហើយគ្នាវាតាមបាញ់ពីក្រោយប្រផិតៗខ្លួនខ្ញុំ។ ខ្ញុំបានទទួលរងទុក្ខវេទនានៅទីនោះអស់រយៈពេល៣ខែ។ វាពិបាកប្រៀបមិនបានស្មើនឹងសត្វជាតុផង។ ពួកវាសាហាវព្រៃផ្សៃយ៉ង់ឃ្នង គ្មានអ្វីប្រៀបផ្ទឹមបាន។ ខ្ញុំតែងគិតថា «ខ្ញុំបានស្លាប់ហើយ»។ ភាពភ័យខ្លាច តក់ស្លុត ញ័ររន្ធត់ មាននៅគ្រប់ដង្ហើមចេញចូល។

នៅឆ្នាំ១៩៧៨ ខ្លួនខ្ញុំត្រូវបានគេចាប់ បញ្ជូនទៅដាក់គុកធំ។ គេដាក់ខ្នោះខ្ញុំត្រង់កជើងទាំងសងខាង អង្គុយជាជួរៗ ប្រមាណជាង ៣០នាក់ (ប្រុសនិងស្រីដាច់ដោយឡែកពីគ្នា)។ ម្នាក់ៗសុទ្ធតែមានពាក់ត្រឡោកនិងស្លាបព្រា១ដាប់កសំរាប់ហូបបបរពេលគេចែកអោយ។ មិនតែប៉ុណ្ណោះពួកវាបានកោរសក់ខ្ញុំឲ្យដូចសញ្ញាជើងក្អែក ហើយពួកវាសើចចំអកឡកឡឺយជាល្បែងលេងសប្បាយ។ ខ្ញុំមានអារម្មណ៍អស់សង្ឃឹមយ៉ាងខ្លាំងហើយគិតថាគ្មានឱកាសរស់តទៅទៀតទេ។

ពេលគេដោះលែងពួកយើង គឺគេឲ្យធ្វើការគាស់គល់នៅតាមព្រៃភ្នំ ក្រោមការគ្រប់គ្រងពីកងឈ្លបខ្មែរក្រហម ដែលមានអាយុមិនលើសពី១៥ឆ្នាំផង។ ពួកវាវៃទាត់ជាក់ក្បាល និងដងខ្លួនខ្ញុំ តាមតែអំពើចិត្ត ជាមួយពាក្យប្រមាថ សំឡុតគំរាមគំហែងថាយកទៅសំលាប់ចោលយ៉ាងងាយៗ។ ពេលយប់ឡើង ខ្ញុំនិងអ្នកដទៃទៀត ត្រូវមុជទឹកជាមួយមនុស្សកើតឃ្លង់ លាយឡំគ្នាក្នុងត្រពាំងទឹកតូចមួយហៅថា«ត្រពាំងឃ្លង់»។ ខ្ញុំមានអារម្មណ៍ខ្លាចឆ្លងជំងឺផង និងខ្ពើមផង ប៉ុន្តែខ្ញុំត្រូវតែមុជក្នុងត្រពាំងនោះដដែល ព្រោះពុំមានទឹកនៅកន្លែងណាផ្សេងទៀតទេ។ ចំណែកនៅក្នុងគុកវិញ ខ្ញុំបានឃើញមនុស្សជាច្រើននាក់ ស្លាប់យ៉ាងអណោចអធម៌ជាទីបំផុត ប្រៀបដូចជាឋាននរក។ មានអ្នកខ្លះចងកក្នុងបង្គន់ អ្នកខ្លះខាំអណ្តាត ដោយសារមិនអាចទ្រាំទ្រនឹងការឈឺចាប់ អត់ឃ្លាន ទាំងនោះបាន។ រីឯអ្នកខ្លះទៀត ដេកស្លាប់ដោយមិនដឹងខ្លួនទាំងជាប់ខ្នោះជើងក៏មានដែរ។ ខ្ញុំមានអារម្មណ៍ថា ខ្លួនឯងនឹងស្លាប់ដូចជាពួកគេមិនខានឡើយ។

ក្នុងឆ្នាំ១៩៧៩ ប្រហែលជាម៉ោង៩ព្រឹក កងទ័ពរំដោះខ្មែរនិងកងទ័ពវៀតណាម បានចូលមកដល់រួចបាញ់សំលាប់ពួកខ្មែរក្រហម ហើយជួយដោះខ្នោះចេញពីជើងពួកខ្ញុំ រួចប្រាប់ឲ្យពួកខ្ញុំរត់ទៅឲ្យឆ្ងាយ។ ពេលនោះខ្ញុំមានអារម្មណ៍ស្រឡាំងកាំង មិនទុកចិត្តថាពួកគេនឹងជួយសង្គ្រោះពួកខ្ញុំមែន ឬក៏ចង់នាំពួកខ្ញុំទៅកន្លែងណាផ្សេងទៀតទេដឹង? ខ្ញុំភ័យផង អរផង ក៏ចេះតែដើរជាមួយគេជាមួយឯង។ មួយខែក្រោយមក ខ្ញុំបានជួបអ្នកជិតខាងម្នាក់ គឺ«បងអ៊ិន» គាត់បានប្រាប់ខ្ញុំថា គាត់បានជួបម្តាយខ្ញុំ ហើយគាត់អាចជូនខ្ញុំទៅរកម្តាយខ្ញុំបាន។ ពួកយើងបានជួបម្តាយជាទីស្រលាញ់ បងប្រុសទី៥ បងថ្លៃ ព្រមទាំងក្មួយស្រីដែលបែកគ្នាអស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ ។

ទោះបីខ្មែរក្រហមបានដួលរលំទៅហើយក៏ដោយ ក៏ស្ថានភាពនៅមិនទាន់ស្ងប់ស្ងាត់នៅឡើយទេ។ ខ្ញុំក៏ដូចជាអ្នកភូមិផ្សេងទៀត បានធ្វើដំណើរទៅរកស្បៀងអាហារ។  ពួកយើងបានទទួលដំណឹងថាពួកខ្មែរក្រហមបានចាប់អ្នកភូមិ

ធ្វើចំណាប់ខ្មាំង ក្នុងនោះក៏មានក្រុមគ្រួសារខ្ញុំផងដែរ។ ខ្ញុំភ័យតក់ស្លុតយ៉ាងខ្លាំង ព្រោះគិតថា នឹងបែកពីម្ដាយម្ដងទៀតហើយ។ សំណាងល្អកងទ័ពខ្មែររំដោះជាតិបានទៅជួយបាញ់តបតនឹងពួកខ្មែរក្រហមសង្គ្រោះអ្នកភូមិមកវិញបាន។

នៅឆ្នាំ១៩៨៤ ខ្ញុំបានរៀបការជាមួយបុរសម្នាក់ ដែលជាអតីតទាហ៊ាន ទៅតាមប្រពៃណីខ្មែរត្រឹមត្រូវ ទោះបីជាមិនបានអធឹកអធមយ៉ាងក្ដី ប៉ុន្តែពួកយើងអាចរស់នៅជាមួយគ្នាប្រកបដោយសុភមង្គល។

អ្វីដែលខ្មែរក្រហមបានបន្សល់ទុកដល់គ្រួសារខ្ញុំ និងខ្ញុំ គឺមានតែការបែកបាក់បងប្អូនសាច់ញាត្តិ និងមានរបួសផ្លូវកាយ-ចិត្ត ដូចជា ចុកក្នុងទ្រូង មានជំងឺបេះដូង មានស្លាកស្នាមជាំជុំៗលើខ្នង ឈឺទ្រុឌទ្រោមពេញរាងកាយ និងអារម្មណ៍ភ័យខ្លាច រន្ធត់ ហាក់ដូចជាហេតុការណ៍នោះ កើតឡើងម្ដងទៀត។

នៅថ្ងៃអនាគតខាងមុខ ខ្ញុំសង្ឃឹមថា ខ្ញុំអាចរស់នៅជួបជុំកូនចៅ ហើយកូនៗអាចមើលថែទាំខ្ញុំ ពេលខ្ញុំចាស់ជរា។ ឯក្រុមគ្រួសារ មានជីវភាពធូរធារសមរម្យ និងរស់នៅប្រកបដោយសុភមង្គល។

ជាចុងក្រោយខ្ញុំសូម សំណូមពរដល់សាលាក្ដីខ្មែរក្រហមឲ្យជួយរកយុត្តិធម៌ដល់ជនរងគ្រោះដូចជាពួកខ្ញុំហើយសូមឲ្យតុលាការ ដំណើរការកាត់ទោសអោយបានឆាប់រហ័ស ព្រោះជនជាប់ចោទក៏ចាស់ៗណាស់ហើយ។ ខ្ញុំចង់ឃើញពួកគាត់ព្រមសារភាព និងទទួលស្គាល់ពីបទឧក្រិដ្ឋ ដែលពួកគេបានប្រព្រឹត្តប្រាកដមែន។ លើសពីនេះទៀតសូមឲ្យមានសាងសង់ជាមន្ទីរពេទ្យបង្អែកសំរាប់ជួយដល់ជនរងគ្រោះ ដែលជាដើមបណ្ដឹងដោយមិនចាំបាច់ចំណាយថវិការ រាល់ការពិនិត្យនិងព្យាបាលជំងឺទាំងផ្លូវកាយនិងចិត្ត។ សូមឲ្យមានជាស្តូបនៅតាមខេត្តនីមួយៗ សំរាប់ជាទីសក្ការៈបូជានៅពេលមានពិធីបុណ្យម្ដងៗ។

នាងខ្ញុំសូមឧទ្ទិសកុសល ជូនទៅដល់បងប្អូននិងសាច់ញាតិដែលបាន ស្លាប់ដូចមានរាយនាម ខាងក្រោម៖

- លោកឪពុក ដោត វ៉ែន (ចងកសំលាប់ខ្លួន)
- បងប្រុសទី១ ដោត ឈុំ (គេចាប់យកទៅសំលាប់ចោល)
- បងប្រុសទី២ ដោត ធន (ឡានបុក)
- បងប្រុសទី៣ ដោត ឈិន (មានជំងឺ)
- បងប្រុសទី៤ ដោត គ្រីម (ពួកខ្មែរក្រហមចាប់អារក)
- បងថ្លៃស្រី អ៊ឹម (អត់អាហារ)
- ក្មួយស្រី កាំពីង ដុស (ពុលគ្រាប់ស្លែង)
- ម្តាយមីងថ្លៃ អ៊ឹម (អត់អាហារ)
- ជីដូនមួយ ដោត សុន(អត់អាហារ)
- ជីដូនមួយ ដោត ស៊ុន (អត់អាហារ)
- ជីដូនមួយ ដោត គីម (អត់អាហារ)
- ព្រមទាំងសាច់ញាតិដទៃទៀត ដែលមិនបានរាប់ឈ្មោះអស់

សូមអោយព្រលឹងវិញ្ញាណក្ខ័ន្ធពួកគាត់ ទៅកាន់ សុគតិភព កុំបីឃ្លាងឃ្លាតឡើយ។

អ្នកផ្តល់សក្ខីកម្ម៖ ដោត សុខគីន
អ្នកផ្តល់ប្រឹក្សា៖ កញ្ញា ស្រ៊ា រដ្ឋា
ភ្នំពេញ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៤



រូបគំនូរនេះបង្ហាញរូប លោក ស៊ុំ រិទ្ធី ស្ថិតនៅក្នុងបន្ទប់ឃុំឃាំងរបស់ខ្លួន កាលខ្មែរក្រហមដាក់គាត់ជាអ្នកទោស៖ «ពេលចាប់ដំបូង គេដាក់ខ្ញុំនៅក្នុងបន្ទប់នោះ២៤ម៉ោង។ កម្មាភិបាលខ្មែរក្រហមទុកផើងមួយក្នុងបន្ទប់ខ្ញុំសំរាប់នោម»

# អ៊ិន សារិ

## អាយុ ៥០ឆ្នាំ រស់នៅខេត្តតាកែវ

**អ៊ិន សារិ** បានចូលរៀនក្នុងសាលាតែ២សប្តាហ៍ប៉ុណ្ណោះ កាលនៅឆ្នាំ១៩៧២ ជាពេលដែលខ្មែរក្រហមប្រយុទ្ធគ្នាជាមួយក្រុមដឹកនាំរដ្ឋាភិបាល ធ្វើឲ្យគាត់ប្រឈមនឹងគ្រោះថ្នាក់យ៉ាងខ្លាំងពេលទៅសាលារៀន។ ២-៣ ឆ្នាំបន្ទាប់មកទៀត គាត់ជួបការភ័យខ្លាច បារម្ភក្រែងឃ្លាតព្រាត់ពីឪពុកម្តាយបងប្អូន ដោយសារភាពវឹកវរនិងសង្គ្រាម។ បងប្រុសគាត់ម្នាក់ ត្រូវខ្មែរក្រហមចាប់ខ្លួន រួចសម្លាប់ មិនយូរប៉ុន្មានបន្ទាប់ពីពួកគេបានឡើងកាន់អំណាចនៅឆ្នាំ១៩៧៥។ នៅជាកុមារនៅឡើយ សារិ បានឆ្លងកាត់ការបង្ខំឲ្យធ្វើការធ្ងន់ មានជម្ងឺ ជួបនូវភាពអត់ឃ្លានរួមនិងការបាត់បង់សមាជិកគ្រួសាររបស់ខ្លួនស្ទើរតែអស់។

# សក្ខីកម្មរបស់ខ្ញុំ

ខ្មែរក្រហម បានជម្លៀសអ្នកភូមិទាំងអស់ចេញពីផ្ទះ។ គ្មានអ្នកណាម្នាក់ហ៊ានតវ៉ា ឬប្រឆាំងជាមួយពួកទាហ៊ានខ្មែរក្រហមនោះបានឡើយ។ អ្នកប្រឆាំងនឹងការជម្លៀសនេះត្រូវតែស្លាប់។ ប្រាំថ្ងៃក្រោយមក កម្មាភិបាលខ្មែរក្រហម បានកោះហៅប្រជាជន ដែលរង់ចាំតែសេចក្ដីស្លាប់នោះ ទៅប្រជុំជីវភាព ដើម្បីរកចំណាប់ខ្មាំងនិងអ្នកចូលដៃជាមួយ សេ អ៊ី អា (CIA)។ នៅពេលខ្ញុំត្រឡប់មកពីឃ្វាលគោនៅឯស្រែវិញ ប្រហែលជាម៉ោង១០ព្រឹក ស្រាប់តែបងស្រីរបស់ខ្ញុំនិយាយរៀបរាប់ប្រាប់ ដោយមានទឹកភ្នែកហូរចេញមកទាំងអារម្មណ៍ក្តុកក្តួលប្រាប់ខ្ញុំថាៈ«ពួកកម្មាភិបាលខ្មែរក្រហម បានមកដល់ផ្ទះ រួចចាប់ចងលោកឪពុករួមជាមួយអ្នកទោស១០នាក់ទៀតយកទៅសម្លាប់ហើយ»។ ក្រោយពេលគេចាប់លោកឪពុកបាត់ទៅ ខ្ញុំឃើញពួកឈ្លប ចាប់អ្នកភូមិចង បណ្ដើរជាជួរៗ។ ម្នាក់ៗមានទឹកមុខស្លេកស្លាំង មិនហ៊ានមាត់ក (ប្រហែល ២០ ទៅ៣០នាក់)។ ខ្ញុំបានគិតនៅក្នុងចិត្តថា«គ្មានអ្នកណាម្នាក់មានសង្ឃឹម ឬ មានជីវិតបានវិលត្រលប់មកផ្ទះឡើយ»។ ខ្ញុំភ័យខ្លាំងណាស់ គ្មានព្រលឹងនៅក្នុងខ្លួនទាល់តែសោះនៅពេលនោះ ហើយក៏មិនដឹងថា គេចាប់អ្នកណាទៀតយកទៅសម្លាប់នោះទេ។ នៅវេលាម៉ោងប្រហែលជា៥ល្ងាច អ្នកម្ដាយ បាននាំបងស្រី និងប្អូនៗរបស់ខ្ញុំទាំងអស់មានគ្នា៥នាក់ លួចរត់ចាកចេញ។

បន្ទាប់ពីរស់នៅទីនោះបាន១០ថ្ងៃ មានឈ្លបម្នាក់មកប្រាប់គ្រួសារខ្ញុំ «ឥឡូវនេះ ប្រធានភូមិប្រាប ឲ្យមិត្តត្រឡប់ទៅវិញ! ហើយអង្គការបក្សនឹងរកមូលហេតុនៃការស្លាប់របស់លោកឪពុក!» ឮដូច្នោះ អ្នកម្ដាយរបស់ខ្ញុំបដិសេធមិនត្រឡប់ទៅវិញនោះឡើយ ព្រោះគាត់យល់ច្បាស់ថា ប្រាកដជាត្រូវស្លាប់មិនខាន។

ក្រោយមកពួកកម្មាភិបាលភូមិត្រពាំងសាឡាង បានយកឡានមកដឹកអ្នកម្ដាយ បងៗ និងប្អូន ទាំងពីររបស់ខ្ញុំ ដោយប្រាប់ថាទៅតែ៥ថ្ងៃប៉ុណ្ណោះ ដើម្បីទៅរកមូលហេតុដែលលោកឪពុកបានស្លាប់ រួចហើយអង្គការនឹងជូនត្រឡប់មកភូមិវិញ។ ពេលនោះ ខ្ញុំបានប្រាប់អ្នកម៉ែថា បើទៅតែប្រាំថ្ងៃមែន ខ្ញុំមិនចង់ទៅនោះទេ ខ្ញុំស៊ូទ្រាំចាំនៅផ្ទះ ដើម្បីបានមើលគោផង។ លុះដល់ថ្ងៃកំណត់ ដែលអ្នកម្ដាយ បងៗ និងប្អូនទាំងពីរ ត្រូវវិលមកភូមិវិញ ស្រាប់តែមិនឃើញពួកគាត់ត្រឡប់មកវិញនោះឡើយ សូម្បីតែដំណឹងក៏គ្មានផង។ ខ្ញុំសន្និដ្ឋានក្នុងចិត្តថា ប្រហែលជាពួកគាត់ស្លាប់ហើយមើលទៅ ទើបមិនឃើញវិលវិញ។

នៅចុងឆ្នាំ ១៩៧៥ ខ្ញុំរស់នៅជាមួយបងប្រុសទី១ របស់ខ្ញុំនិងប្រពន្ធគាត់។ រស់នៅជាមួយសាច់ថ្លៃ គេធ្វើបាប ស្ដីបន្ទោសខ្ញុំ។

នៅដើមឆ្នាំ ១៩៧៦ បងប្រុសទី៤ បានមកយកខ្ញុំឲ្យទៅរស់នៅជាមួយគាត់។ អង្គការបានដាក់ទិសឲ្យខ្ញុំទៅនៅក្នុងជួរកងចល័តកុមារ។ ចំណែកបងប្រុស ចូលទៅកងចល័តយុវជន។ នៅពេលនោះ ផ្ទះសម្បែងរបស់ខ្ញុំ ត្រូវគេរុះរើនិងឆេះខ្ទេចខ្ទី ហើយគោមួយនឹមរបស់ខ្ញុំ អង្គការបក្សកុម្មុនិស្តបានចាត់ទុកជារបស់រួមទាំងអស់ គឺគ្មានអ្វីជាកម្មសិទ្ធឯកជនទៀតនោះឡើយ។ គ្រានោះអង្គការបានដាក់ទិសឲ្យខ្ញុំដើបពីព្រលឹម ទៅដឹកប្រឡាយជាមួយកុមារដទៃទៀត។ ក្រុមកុមារមានគ្នា ១២នាក់  គឺ៥នាក់ជាអ្នកកាប់ដី ៧នាក់ទៀតជាអ្នករែកឬអ្នកចាក់ដីដើម្បីលើកជាទំនប់ធ្វើប្រឡាយទឹក ដែលមានកំពស់២ម៉ែត្រ ទទឹង២ម៉ែត្រ និងបណ្ដោយប្រហែល៥០០ម៉ែត្រ និង មានអ្នកដឹកទាំងអស់នៅទីនោះ ប្រហែល ២០០នាក់ (សុទ្ធសឹងតែជាកងកុមារតូច)។ រាល់ល្ងាចម៉ោង៦ អង្គការបក្សបានហៅក្រុមកុមារទៅប្រជុំជីវភាព ដោយឲ្យកុមារម្នាក់ៗទិទៀន តៗ គ្នា ដូចជាថា«មិត្តនេះខ្ជិល!គិតតែពីលេង! និងលួចចាប់ក្ដាម! មិនប្រឹងប្រែងធ្វើការដែលអង្គការបានដាក់ទិសឲ្យធ្វើ! ជាដើម»។ ពេលនោះ ខ្ញុំពិតជាមិនយល់សោះ ពួកយើងខិតខំដឹកប្រឡាយ ទាំងយប់ ទាំងថ្ងៃ អាហារហូបមិនគ្រប់ មិនដែល

ប្រកែកតវ៉ា រួចហើយ នៅតែមិនពេញចិត្តរបស់អង្គការបក្សទៀត។ អង្គការបក្ស កំណត់ឲ្យតែអង្ករ៣កំប៉ុងគត់ សម្រាប់កុមារ១២នាក់ ហូបចំនួន២ពេលប៉ុណ្ណោះ។ ខ្ញុំនិងកុមារក្នុងក្រុមហូបទាំងវេទនា ហើយគ្មានអនាម័យសោះ។ គេដាំបបរ សម្ល ស្លោរត្រកួន និងព្រលិត ទាំងមិនបានលាងសំអាត។ នៅក្នុងទឹកសម្លមានឫស បន្លែ ពេលខ្លះហូបចំលាមកគោនិងដីគ្រួស ហើយគ្មានរសជាតិសោះ។ ដើម្បីជីវិត រស់ ខ្ញុំខំហូបដោយមិនត្អូញត្អែរអ្វីឡើយ។

នៅឆ្នាំ១៩៧៨ អង្គការកុម្មុយនីស្តខ្មែរក្រហម បានដាក់ផែនការឲ្យខ្ញុំជីក ប្រឡាយ នៅកន្លែងផ្សេងទៀត នៅជុំវិញភូមិភាគនិរតី។ ពេលនោះហើយ ដែល ខ្ញុំឋិតក្រោមការតាមដានឃ្លាំមើលការងារទាំងយប់ទាំងថ្ងៃ ធ្វើការរកពេលសម្រាក គ្មាន។ ឯការហូបចុកវិញក៏មិនគ្រប់គ្រាន់ ខ្ញុំទ្រាំមិនបានជាមួយការងារយ៉ាងធ្ងន់ និងប្រើហួសកម្លាំងក្នុងវ័យជាកុមារ។ ពេលនោះខ្ញុំធ្លាក់ខ្លួនឈឺធ្ងន់ ហើយកើតជំងឺ ហើមខ្លួន។ រាងកាយខ្ញុំហើមមានចេញទឹក ម្រាមជើងរបស់ខ្ញុំដំបៅរលួយ និងជ្រុះ ក្រចកអស់ ។ បើទោះជាខ្ញុំឈឺ ក៏នៅតែទៅធ្វើការ ទាំងដៃជើងហើមពេលនោះ។ ២ ខែក្រោយមក ខ្ញុំជាពីជំងឺហើមនេះ។ ស្រាប់តែខ្ញុំមានជម្ងឺគ្រុនក្តៅខ្លាំង គ្មាន កម្លាំងកំហែង ធីងជោងវិលមុខ ហើយមិនអាចទៅជីក ប្រឡាយ ធ្វើស្រែវិញបាន ឡើយ។ មេក្រុមស្រែកដាក់ខ្ញុំ «អង្គការជីកស្មៅត្រូវជីកឲ្យអស់ពីឫស! និងមិនទុក ឲ្យរស់ឡើយ»។ បើមិត្តឯងទៅធ្វើការមិនរួច មានតែប្តូរឲ្យទៅកន្លែងថ្មី (មន្ទីរឈ្លប ជាកន្លែងរង់ចាំស្លាប់)។ ពេលនោះខ្ញុំខ្លាចណាស់ ភ័យញ័រសាច់អស់ហើយ។ បន្តិចក្រោយមក យើងបានមកដល់មន្ទីរឈ្លប ដែលជាកន្លែងឃុំឃាំងមនុស្ស មានទោស ដូចជា កុមារក្បត់អង្គការ កុមារលួចមាន់ លួចដូង ឬ ដំឡូង ជាដើម។ ខ្ញុំនិងកុមារទាំងអស់រស់ក្នុងមន្ទីរឃុំឃាំងនោះ មានទឹកមុខស្រងូតស្រងាត់ គ្មាន កំលាំង ក្រៀមក្រំ មិនហ៊ាននិយាយស្តីអ្វី នោះឡើយ ព្រោះរង់ចាំតែគេចាប់យក ទៅសម្លាប់តែប៉ុណ្ណោះ។ មានមិត្តម្នាក់នៅក្នុងក្រុមយុទ្ធជនរបស់បងប្រុសទី៤ បានមកខ្សឹបប្រាប់ខ្ញុំថា៖ «បងប្រុសទី៤ធ្វើការងារធ្ងន់ហួសកំលាំង គ្មានអាហារ

ហូបគ្រប់គ្រាន់ គាត់បានស្លាប់ទៅហើយ។

ថ្ងៃទី ០៧ ខែមករា ឆ្នាំ ១៩៧៩ ។ ប្រទេសជាតិបានរំដោះចេញពីកណ្តាប់ដៃគ្រប់គ្រងដោយ របបប្រល័យពូជសាសន៍ខ្មែរក្រហមដោយសារកងទ័ពវៀតណាម។ ខ្ញុំបានមកដល់ភូមិកំណើតវិញ។ នៅពេលនោះមានតែលោកយាយ បងប្អូនជីដូនមួយ និងម្តាយមីងរបស់ខ្ញុំប៉ុណ្ណោះ ដែលបានរស់រានជីវិត ហើយនៅរួមរស់ជាមួយគ្នាក្នុងស្រុកភូមិរហូតដល់សព្វថ្ងៃ។ កាលនោះ បងប្អូនជីដូនមួយរបស់ខ្ញុំប្រាប់ថា អ្នកម្តាយ បងស្រី និងប្អូនៗរបស់ខ្ញុំ ត្រូវពួកខ្មែរក្រហមសម្លាប់ ហើយអ្នកភូមិដែលទៅជាមួយនោះ មានជំងឺគ្រុនចាញ់ ដេកឈឺស្លាប់។ ពេលដែលឮថាលោកឪពុកអ្នកម្តាយនិងបងប្អូនបានស្លាប់ទាំងអស់ដូច្នោះ ខ្ញុំគ្មានក្តីសង្ឃឹមនៅក្នុងជីវិតលើង មិនចង់រស់នៅម្នាក់ឯងទៀតសោះឡើយ។ ចំណែកឯផ្ទះសម្បែងក៏បានឆេះខ្ទេចខ្ទីអស់។ ខ្ញុំគ្មានទីពឹងទៀតឡើយសម្រាប់ជីវិតរបស់ខ្ញុំនាពេលនោះ។ ខ្ញុំមានសល់តែយាយខាងម្តាយតែម្នាក់គត់ដែលនៅរស់ ហើយគាត់គ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាខ្ញុំរហូតមក។

ការទទួលរងទារុណកម្ម រួមនិងការបាត់បង់លោកឪពុកអ្នកម្តាយបងប្អូនរបស់ខ្ញុំទាំងអស់សល់តែរូបខ្ញុំតែម្នាក់គត់ជាមួយនិងសោកនាដកម្មមិនអាចបំភ្លេចបាននេះហើយដែលបានរំខានដល់ផ្លូវចិត្តរបស់ខ្ញុំមកដល់បច្ចុប្បន្ននេះ។

ខ្ញុំបានសម្រេចចិត្តរៀបចំសំណុំឯកសារជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២/០១ ទៅកាន់តុលាការសាលាក្តីខ្មែរក្រហម (ហៅថាអវតក) ដើម្បីជួយរកយុត្តិធម៌និងពន្លឿនក្នុងការកាត់ទោសដល់មេដឹកនាំខ្មែរក្រហមទាំងអស់នោះឲ្យបានឆាប់។

ជាចុងក្រោយនេះ សម្រាប់រូបខ្ញុំផ្ទាល់ ប្រាថ្នាសុំអង្គការធីភីអូ ក៏ដូចជាអង្គការអន្តរជាតិផ្សេងទៀត មេត្តាជួយដល់រូបខ្ញុំ និងជនរងគ្រោះដទៃទៀត ឲ្យបានទទួលសេវាព្យាបាលជំងឺដោយឥតគិតថ្លៃ និងសូមជួយផ្នែកគាំទ្រផ្លូវចិត្ត ឬឲ្យ

មានសេវាព្យាបាលនៅតាមបណ្ដាស្រុកនីមួយៗ ជាពិសេស ឲ្យមាននៅក្នុងស្រុកអង្គរជ័យ ខេត្តកំពតនេះ។ ម្យ៉ាងវិញទៀតខ្ញុំសង្ឃឹមថា ក្មេងជំនាន់ក្រោយនឹងបានទទួលដឹងឮនូវរឿងរ៉ាវទាំងអស់នេះ។ ខ្ញុំមានបំណងទុកតម្កល់ឯកសារនេះ ជាប្រវត្តិសាស្ត្រសំរាប់មនុស្សជំនាន់ក្រោយបានសិក្សារៀនសូត្រ រួចហើយចៀសឲ្យឆ្ងាយពីការដឹកនាំដ៏អាក្រក់បំផុតនេះ។ ខ្ញុំប្រាថ្នាជួបលោកឳពុកអ្នកម្ដាយ និងបងប្អូនរបស់ខ្ញុំគ្រប់ៗជាតិ។

ខ្ញុំសូមឧទ្ទិសដល់៖

- លោកលោកឪពុក ឡៀប សែប អ្នកម្តាយ ទូច នេន
- បងប្រុសទី១ អ៊ិន យឹម. អ៊ិន យន
- បងស្រីអ៊ិន អ៊ាប
- បងប្រុសទី៤ អ៊ិន យេន
- បងប្រុសទី៥ អ៊ិន រើន
- ប្អូនស្រីឈ្មោះ អ៊ិន អួន និង អ៊ិន អង
- អ៊ុំប្រុសខាងម្តាយឈ្មោះ ទូច យូរ
- បងជីដូនមួយ តែម យឿង និង តែម មឿន
- ពូឈ្មោះ ទូច យ៉ង់ និង ទូច យ៉ាត
- ពូខាងឪពុក ឡៀប អេង
- បងប្រុសឈ្មោះសិទ្ធ សើ និង សិទ្ធ សៀប
- លោកយាយ ហេង
- និងលោកពូ ទូច យស ដែលស្លាប់នៅឆ្នាំ ១៩៨៤

អ្នកផ្តល់សក្ខីកម្ម៖ លោក អ៊ិន សារិ

អ្នកប្រឹក្សាផ្លូវចិត្ត៖ លោក ប៊ុន លឹមហ្សួរ

ភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤



កុមារ មិនត្រូវបានបន្ធូរបន្ថយឬទុកជីវិតឡើយ ក្នុងសម័យខ្មែរក្រហម។ ស៊ុំ រិទ្ធី រំឭក ៖ «នេះគឺនៅក្រៅពន្ធនាគារ, គឺពេលកម្មាភិបាលខ្មែរក្រហមកំពុងវាយកុមារដែលកំពុងយំរកម្ដាយវា។ កុមារនេះបានស្លាប់ ៣ ថ្ងៃក្រោយមក។ គឹម ស្រី និង មុត រឿន ដែលត្រូវជាឪពុកម្ដាយរបស់កុមារនោះ បានជាប់ពន្ធនាគារទាំងអស់គ្នា»

# មាស អ៊ិន់

## អាយុ ៥៥ ឆ្នាំ រៀបការរួចមានកូន ៥នាក់
## ខេត្ត ព្រៃវែង

**អ៊ិន់** បានធំដឹងក្តីនៅជនបទនៃប្រទេសកម្ពុជា ជាមួយនិងបងប្អូនប្រុសស្រី ៧នាក់។ អ្នកស្រី បានបាត់បង់ឪពុកម្តាយដោយសារជម្ងឺមុនពេលខ្មែរក្រហមឡើងកាន់អំណាច។ នៅជាកុមារម្នាក់ ក្នុងដើមទស្សវត្ស ទី៧០ នាង អ៊ិន់ បានដឹងថា អ្វីៗបានប្រែទៅជាអាក្រក់ក្នុងប្រទេសកម្ពុជា នៅពេលដែលបងប្រុសគាត់ ២នាក់ បានស្ម័គ្រចិត្តចូលបំរើក្នុងក្រុមខ្មែរក្រហមដើម្បីប្រឆាំងនឹងរបបលន់ ណុល។ ប្រធានសហករ ដែលបានបង្កើតឡើងក្នុងតំបន់នាងអ៊ិន់រស់នៅទាំងអស់ បានចាប់ផ្តើមកែន យកកុមារទៅធ្វើការងារធ្ងន់ៗ។ មិនយូរប៉ុន្មានក៏ដល់វេណនាង។ នាង អ៊ិន់ បានឃ្លាតចេញពីក្រុមគ្រួសារ រួចត្រូវផ្លាស់ទី ពីការដ្ឋានមួយទៅការដ្ឋានមួយទៀត ដែលនៅទីនោះ នាងបានរងនូវការងារធ្ងន់ៗ ការបំភិតបំភ័យ ការអត់ឃ្លាននិងជម្ងឺ បានឃើញអំពើទារុណកម្មនិងការកាប់សម្លាប់ និងបានរស់នៅក្នុងសេចក្តីភ័យខ្លាចក្នុងជីវិតរបស់នាង។

# សក្ខីកម្មរបស់ខ្ញុំ

កន្លែងដែលខ្ញុំធ្វើការ នោះ គឺជាកន្លែងដែលសំបូរមីននិងគ្រាប់បែកមិនទាន់ផ្ទុះ ដោយសារគេបានដាក់សំរាប់ការពារទប់ទល់សត្រូវ។ ពេលដើរឆ្លងកាត់ម្តងៗ ខ្ញុំមានអារម្មណ៍ភ័យរន្ធត់ និងខ្លាចស្លាប់ខ្លាំងណាស់។ តែខ្ញុំត្រូវតែដើរឆ្លង បើមិនដូច្នេះទេ គេនឹងចោទខ្ញុំថាជាជនក្បត់។ ថ្ងៃមួយក្នុងរដូវវស្សា ប្រហែលម៉ោង ១២ ថ្ងៃត្រង់ ខ្ញុំបានឃើញបុរស៣នាក់ បានជាន់មីននៅទីនោះ។ បុរសម្នាក់ដែលមានឈ្មោះថា យ៉ុង អាយុប្រហែល២៥ឆ្នាំបានស្លាប់ និងបុរស២នាក់ទៀត ទទួលរងរបួសយ៉ាងធ្ងន់។ មុនហេតុការណ៍ផ្ទុះនោះ ខ្ញុំបានដើរពីក្រោយពួកគាត់ផងដែរ ប៉ុន្តែសំណាងល្អ ខ្ញុំបានដើរបាំងនឹងដើមត្នោតមួយដែលបំណែកគ្រាប់មីនបានផ្លាតត្រូវចំ។

២ខែក្រោយមក ខ្ញុំមានជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរណាស់។ ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យមកសំរាកនៅមន្ទីរពេទ្យ ១៧មេសា ក្បែរស្ទឹងមានជ័យ។ ក្នុងអំឡុងពេលស្នាក់នៅក្នុងពេទ្យនោះ ខ្ញុំបានឃើញគេធ្វើទារុណកម្មអ្នកជំងឺ ដែលឈឺធ្ងន់ធ្ងរមកពីតំបន់ឆ្ងាយ។ ថ្ងៃមួយប្រហែលជាម៉ោង ៥ល្ងាច មានពេទ្យស្រីម្នាក់អាយុប្រហែលជា២០ឆ្នាំ បានយកទឹកធម្មតា(មិនមែនថ្នាំពេទ្យ) ទៅចាក់ចូលសរសៃយាយជាអ្នកជំងឺម្នាក់ឈ្មោះ ម៉េន អាយុ៥៨ឆ្នាំ ឲ្យគាត់ស្លាប់ក្នុងមន្ទីពេទ្យនោះតែម្តង។ ឃើញដូចនេះខ្ញុំភ័យខ្លាចខ្លាំងណាស់ហើយមានអារម្មណ៍អស់សង្ឃឹមទៀតផង។ ខ្ញុំបានគិតថា ថ្ងៃណាមួយខ្ញុំនឹងត្រូវគេសំលាប់ដូចគាត់ជាមិនខាន។

១៩៧៦ ខ្មែរក្រហមបានចាត់តាំងឲ្យខ្ញុំធ្វើកាងារនៅក្នុងរោងពុម្ពកាសែតមួយក្នុងទីក្រុងភ្នំពេញ។ ខ្ញុំនឹកបងប្អូនខ្ញុំណាស់ មិនដឹងថាពួកគេ នៅទីណាឡើយ។ ពេលខ្លះខ្ញុំត្រូវធ្វើការទាំងយប់ទាំងថ្ងៃមិនសូវមានពេលសម្រាកឡើយ។ ហើយ

ក្នុងមួយថ្ងៃត្រូវហូបតែនំប៉ុង ឬបាយមួយដុំប៉ុណ្ណោះ។

ចូលដល់ ១៩៧៧ មានថ្ងៃមួយប្រហែលម៉ោង៨ព្រឹក ខ្ញុំនិងអ្នកធ្វើការជាមួយគ្នា ២នាក់ទៀតបានទៅបេះបន្លែនៅក្បែរគុកទួលស្លែង។ ពួកខ្ញុំបានលួចមើលតាមប្រហោងរបង បានឃើញខ្មែរក្រហមធ្វើទារុណកម្ម លើអ្នកទោសបុរសម្នាក់អាយុប្រហែល៣០ឆ្នាំ។ ពួកខ្មែរក្រហមបានលើកស្ទូចបុរសនោះទំលាក់ទៅក្នុងអាងទឹកចុះឡើងៗ ហើយបុរសនោះបានស្រែកយំឲ្យគេជួយយ៉ាងឮៗ។ មួយសន្ទុះក្រោយមកបុរសនោះបានសន្លប់បាត់ស្មារតីទៅ។ ឃើញដូច្នេះ ខ្ញុំនិងមិត្តភក្តិភ័យរន្ធត់ខ្លាំងណាស់ ញ័រអស់ពេញខ្លួនប្រាណ ព្រោះបានដឹងថារបបនេះចាប់ផ្តើមសំលាប់មនុស្សហើយ។ ខ្ញុំមិនដែលហ៊ាននិយាយរឿងរ៉ាវនេះប្រាប់អ្នកណាផ្សេងទៀតទេ ព្រោះខ្លាចគេយកទៅសំលាប់ចោល។ពួកខ្ញុំមិនដែលហ៊ានទៅជិតគុកនោះម្តងទៀតឡើយ។ ១០ថ្ងៃ ក្រោយមកមានការប្រជុំស្រាវជ្រាវលើប្រវត្តិរូបរបស់អ្នកមកពីភូមិភាគបូព៌ា។ គេបានប្រាប់ថា អ្នកមកពីភូមិភាគបូព៌ាទាំងអស់នឹងត្រូវយកទៅសំលាប់ចោល ព្រោះលោក សោ ភឹម ដែលជាអ្នកគ្រប់គ្រងតំបន់នោះបានក្បត់នឹងបដិវត្តន៍។ ឮដូច្នេះ ខ្ញុំរឹតតែភ័យខ្លាចខ្លាំងណាស់ថែមទៀត ព្រោះខ្ញុំក៏ជាអ្នកមកពីតំបន់បូព៌ាម្នាក់ដែរ ដូច្នេះខ្ញុំក៏ជាមុខសញ្ញារបស់ពួកគេដែរ។ សំណាងល្អ ក្រោយមកមានមិត្តភក្តិខ្ញុំម្នាក់បានជួយកែប្រវត្តិរូបរបស់ខ្ញុំ ថាជាអ្នកមកពីតំបន់បច្ចឹមវិញ។

១៩៧៨ខ្មែរក្រហមបានចាប់ផ្តើមកៀរពួកខ្ញុំឲ្យចេញពីទីក្រុងភ្នំពេញទៅភូមិភាគបច្ចឹមក្នុងខេត្តពោធិ៍សាត់។ ខ្ញុំត្រូវគេបង្ខំឲ្យធ្វើដំណើរដោយជើងទទេ អស់រយៈពេលកន្លះខែ។ ខ្ញុំឈឺសព្វរាងកាយ ហើមជើង ព្រមទាំងគ្មានបាយទឹកហូបទេ។ ពេលធ្វើដំណើរតាមផ្លូវ ខ្ញុំបានជួបការប្រយុទ្ធគ្នា រវាងកងទ័ពវៀតណាមនិងពួកខ្មែរក្រហម រួមមានបាញ់គ្នាដោយកាំភ្លើងដៃនិងទំលាក់គ្រាប់ពីលើយន្តហោះផងដែរ។ ពេលកំពុងរត់នោះ ខ្ញុំបានឃើញក្មេងស្រីពិការជើងម្នាក់ ដ៏គួរអោយអាណិតខ្លាំងណាស់។ ក្មេងស្រីនោះ មិនអាចរត់ទៅណារួចឡើយ ហើយបាន

ដេកស្លាប់នៅទីនោះទៅ។ មួយសន្ទុះក្រោយមក ខ្ញុំឃើញបុរសចំណាស់ម្នាក់ត្រូវគ្រាប់ស្លាប់នៅនឹងកន្លែងនោះម្នាក់ទៀត ។

ក្នុងពេលនោះ ខ្ញុំមានអារម្មណ៍រន្ធត់ វេទនាក្នុងចិត្តនឹងអស់សង្ឃឹមខ្លាំងណាស់។ រំលងបានប៉ុន្មានថ្ងៃ ខ្ញុំបានធ្វើដំណើរមកដល់កន្លែងចំណតរទេះភ្លើងមួយ។ ពេលនោះម៉ោងប្រហែល ១១ ព្រឹក ខ្ញុំបានឃើញទាហ៊ានរបួសយ៉ាងច្រើននៅលើរទេះភ្លើងនោះ មានអ្នកខ្លះដាច់ដៃ ខ្លះដាច់ជើង រលួយសាច់ ដេកស្លាប់គលើគ្នា គ្មានអ្នកណាមើលថែទាំអ្នកណាឡើយ។ ពួកទាហ៊ានទាំងនោះបានស្រែកយំសុំឲ្យគេជួយយ៉ាងអាណោចអាធ័ម។ ព្រឹត្តិការណ៍នោះបានធ្វើឲ្យខ្ញុំមានអារម្មណ៍ក្តុកក្តួលយ៉ាងខ្លាំងណាស់ ហើយនឹកគិតទៅដល់បងប្រុសរបស់ខ្ញុំទាំង៣នាក់ ដែលកំពុងតែធ្វើជាទាហ៊ាន មិនដឹងជាវាសនារបស់ពួកគាត់ទៅជាយ៉ាងណាឡើយ។

ក្រោយពេលថ្ងៃរំដោះ ៧ មករា ១៩៧៩ ខ្ញុំបានធ្វើដំណើរអស់រយះពេល ១៥ថ្ងៃ ពីខេត្តពោធិ៍សាត់ ទើបដល់ស្រុកកំណើតក្នុងខេត្តព្រៃវែង។ ពេលមកដល់ស្រុកកំណើត ខ្ញុំបានឃើញគេជួបជុំសាច់ញាតិ តែផ្ទះរបស់ខ្ញុំវិញ គ្មានបងប្អូនណាម្នាក់សោះ មានតែផ្ទះ តែគ្មានមនុស្សរស់នៅ។ ប៉ុន្មានថ្ងៃក្រោយមក មានអ្នកជិតខាងឈ្មោះមីង ស៊ីម បានមកប្រាប់ខ្ញុំថា បងប្អូនខ្ញុំ ៥នាក់ និងក្មួយប្រុសខ្ញុំម្នាក់ទៀត ត្រូវបានគេយកទៅសំលាប់នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ក្នុងសហករបាក់ចិញ្ចៀនបាត់ទៅហើយ។ រីឯបងប្រុសម្នាក់ទៀតក៏ត្រូវបានគេយកទៅសម្លាប់ក្នុងខេត្តព្រៃវែង តាំងពីឆ្នាំ១៩៧៦ម្លេះ។ ចំណែកបងប្អូនដែលនៅសល់ មិនដឹងជារស់ ឬស្លាប់ឡើយ។ ខ្ញុំបានគិតថា ជីវិតគ្មានន័យទៀតឡើយ ព្រោះខ្ញុំបានក្លាយជាមនុស្សកំព្រារស់នៅម្នាក់ឯង តែលតោលគ្មានទីពឹង គ្មានឪពុកម្តាយនិងបងប្អូនសាច់ញាតិ ព្រមទាំងបានគិតថាចង់សំលាប់ខ្លួនផងដែរ។

ចុងឆ្នាំ ១៩៧៩ ខ្ញុំត្រូវគេជ្រើសរើសឲ្យទៅធ្វើការនៅមន្ទីរឃុំ រៀនធ្វើជាពេទ្យ ហើយដើរព្យាបាលគេតាមភូមិជារៀងរាល់ថ្ងៃតែម្នាក់ឯង។ យប់មួយប្រហែល

ម៉ោង ១ កណ្ដាលអាធ្រាត មានទាហ៊ានខ្មែរក្រហមមួយក្រុមបានចូលមកក្នុងភូមិនឹងព័ទ្ធបាញ់មន្ទីឃុំ ជាកន្លែងដែលខ្ញុំកំពុងដេកក្នុងយប់នោះ។ ពួកវាបានបាញ់ចំខ្ញុំចំនួន ៤គ្រាប់ ត្រង់ស្មានិងជើង ហើយឈាមបានហូរយ៉ាងច្រើនស្រោចពេញលើរាងកាយរបស់ខ្ញុំ។ ពេលនោះ ខ្ញុំភ័យរន្ធត់ខ្លាំងណាស់រហូតសន្លប់បាត់ស្មារតី លុះព្រឹកឡើងអ្នកភូមិក៏បានសែងខ្ញុំយកមកព្យាបាលនៅមន្ទីរពេទ្យក្នុងទីរួមខេត្តព្រៃវែង។ ខ្ញុំបានស្នាក់នៅមន្ទីរពេទ្យនោះអស់រយៈពេល២ខែ ទាំងមិនអាចធ្វើអ្វីបានឡើយ ហើយក៏មិនមានអ្នកណាមកមើលសួរសុខទុក្ខផងដែរ។ ខ្ញុំអាណិតខ្លួនឯង មានអារម្មណ៍ឯកោណាស់ ព្រោះគិតថាខ្លួនដេកឈឺតែគ្មានសាច់ញាតិនៅមើលថែទាំដូចគេ ហើយចេះតែមានអារម្មណ៍ ភ័យរន្ធត់ចាប់តាំងពីពេលនោះមក។ ប៉ុន្តែសំណាងល្អក្នុងអំឡុងពេលនោះ មានបុរសជាទាហ៊ានម្នាក់ដែលនៅយាមទីនោះតែងតែជួយយកអាសារខ្ញុំរហូតបានជាសះស្បើយ។ ឆ្នាំ១៩៨០ ខ្ញុំនិងបុរសនោះក៏បានរៀបការជាមួយគ្នា ហើយគាត់ជាប្ដីរបស់ខ្ញុំសព្វថ្ងៃនេះឯង។

ឆ្នាំ២០០៦ ខ្ញុំបានសម្រេចចិត្ត ដាក់ពាក្យបណ្ដឹងទៅសាលាក្ដីខ្មែរក្រហម។ ខ្ញុំចង់សុំឲ្យតុលាការជួយទាមទារកយុត្តិធម៌ឲ្យបានឆាប់ដល់ជនរងគ្រោះ។ ខ្ញុំរំពឹងទុកថា នឹងទទួលបាននូវយុត្តិធម៌ ហើយយុត្តិធម៌ ចំពោះខ្ញុំគឺចង់ឲ្យតុលាការស្វែងរកកាពិតពីមេដឹកនាំខ្មែរក្រហម ជាកាពិតដែលពួកគាត់ហ៊ានទទួលស្គាល់ ហើយសារភាពថាពិតជាបានធ្វើអំពើអាក្រក់លើប្រជាជន រួមនិងមូលហេតុនៃការសំលាប់មនុស្ស។ លើសពី នេះ ខ្ញុំចង់ឃើញតុលាការដាក់ទោសជនជាប់ចោទឲ្យសមនឹងទោសកំហុសរបស់ពួកគេដែលបានធ្វើបាបប្រជាពលរដ្ឋ ហើយខ្ញុំចង់ទាមទាឲ្យមានជាសំណងដល់ជនរងគ្រោះ។ សំណងរបស់ខ្ញុំគឺជាការផ្សះផ្សាផ្លូវចិត្តដើម្បីឲ្យអារម្មណ៍បានធូរស្បើយ និងសំណងសមូហភាព ដូចជា ស្តូប ឬចេតីយ៍សម្រាប់ដាក់ធាតុ របស់ជនរងគ្រោះដែលបានស្លាប់ទៅ និងដើម្បីរំលឹកដល់វិញ្ញាណខ័ន្ធឲ្យពួកគេបានស្ងប់ចិត្ត។

ចំពោះសក្ខីកម្មនេះ ខ្ញុំសុំឧទ្ទិសដល់វិញ្ញាណខ័ន្ធសាច់ញ្ញាតិខ្ញុំ ដែលបានបាត់បង់ជីវិតទៅ រួមមានឪពុកម្តាយរបស់ខ្ញុំ និងបងប្អូនដែលមានឈ្មោះដូចខាងក្រោម៖

- លោកឪពុក មាស
- អ្នកម្តាយ សួន
- បងប្រុស មឿន
- បងប្រុស សឿន
- បងប្រុស ញ៉ៀន
- បងប្រុស អ៊ី
- ប្អូនស្រី អុន
- ប្អូនស្រី អាង
- ប្អូនស្រី អាត
- ប្អូនប្រុស សាត
- ព្រមទាំងសាច់ញាតិដទៃទៀត។

អ្នកផ្តល់សក្ខីកម្ម៖ មាស អ៊ិន់
អ្នកផ្តល់ប្រឹក្សា៖ ផាន់ រដ្ឋា
ភ្នំពេញ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៤



ខ្មែរក្រហម បានធ្វើទារុណកម្មអ្នកទោសរបស់ខ្លួនយ៉ាងឃោរឃៅ។ ក្នុងរូបគំនូរដោយខ្មៅដៃនេះ ស៊ុំ រិទ្ធី បង្ហាញអំពីរបៀបដែលខ្មែរក្រហមបានចាប់ស្ត្រីមេកងម្នាក់ពីឃុំជ័យក្រាំង រួចយកមកសួរចម្លើយ។ សូម្បីមានផ្ទៃពោះ ខ្មែរក្រហមបានធ្វើទារុណកម្មនាងយ៉ាងធ្ងន់ធ្ងររួចសម្លាប់នៅក្បែរប្តីរបស់នាង ព្រោះត្រូវគេចោទថាជា«សត្រូវរបស់អង្គការ»។

# ប៊ុន សារឿន

## ភេទប្រុស អាយុ ៥៥ ឆ្នាំ រៀបការរួច ជាកសិករ
## រស់នៅ ខេត្ត តាកែវ

**សារឿន** កើតចេញពីគ្រួសារកសិករមួយ ដែលកំពុងរស់នៅសុខដុមរមនា និងជីវិតរីករាយ មុនពេលខ្មែរក្រហមកាន់កាប់អំណាច។ សាច់ញាតិប្រុសៗខ្លះ បានបួសជាសង្ឃ។ ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមប្រមូលក្រុមគ្រួសារគាត់ ហើយក៏បញ្ជូនពួកគេទៅការដ្ឋានការងារ ដូចក្រុមគ្រួសារអ្នកឯទៀតដែរ។ បន្តិចម្តងៗ គ្រួសាររបស់សារឿន ត្រូវខ្មែរក្រហមបំបែកពង្រាត់ឲ្យរស់នៅផ្សេងៗគ្នា ពាសពេញប្រទេស។ សមាជិកគ្រួសារគាត់ជាច្រើន បានស្លាប់ដោយដៃខ្មែរក្រហម។ ៥នាក់ក្នុងចំណោមអ្នកទាំងនោះ ត្រូវបានសម្លាប់ក្នុងថ្ងៃដូចគ្នា អំឡុងពេលចាប់ផ្តើមរបបនេះដំបូង។ ប្រវត្តិរបស់គាត់ គឺជា ប្រវត្តិមួយនៃការបាត់បង់ដ៏ធំធេង ទាំងមិនដឹងថាមានអ្វីកើតឡើងចំពោះមនុស្សជាទីស្រឡាញ់ជាច្រើននាក់ ហើយរស់នៅក្នុងក្តីភ័យខ្លាចនិងរន្ធត់ជាប់ជាប្រចាំ។

# សក្ខីកម្មរបស់ខ្ញុំ

ថ្ងៃមួយ ខ្ញុំបានឃើញពួកខ្មែរក្រហមចងឪពុកខ្ញុំ បងថ្លៃខ្ញុំ ពូខ្ញុំ និងអ៊ុំខ្ញុំ២នាក់ ព្រមទាំងប្រជាជនដទៃទៀត ហើយបណ្តើរពួកគាត់យកចេញទៅទុកក្នុង«មន្ទីរក្រាំងតាចាន់»។ ពេលឃើញហេតុការណ៍នេះ ខ្ញុំមានអារម្មណ៍ថាខឹងយ៉ាងខ្លាំង មានអារម្មណ៍អស់សង្ឃឹម ភិតភ័យ និងតក់ស្លុតឥតឧបមា។ ខ្ញុំបានឃើញឪពុកខ្ញុំកំពុងរែកទឹក ជាមួយនិងមនុស្សម្នាដទៃទៀតដែលកំពុងជីករណ្តៅ ហើយពួកខ្មែរក្រហមជាច្រើននាក់ ប្រដាប់ដោយកាំភ្លើងជាប់នឹងខ្លួន កំពុងឈរយាមកាមនៅក្បែរកន្លែងធ្វើការយ៉ាងតឹងរឹង និងម៉ត់ចត់បំផុត។ យប់ឡើង ខ្ញុំបានឮសម្រែកមនុស្សទ្រហោរយំ និង ស្រែកហៅឲ្យគេជួយ ដោយសារពួកខ្មែរក្រហមកំពុងវាយធ្វើបាប។ ចាប់តាំងពីថ្ងៃនោះមក ខ្ញុំលែងបានដឹងអំពីដំណឹងរបស់ពួកគាត់ ព្រមទាំងឪពុក បងថ្លៃ ពូ និងអ៊ុំៗខ្ញុំទៀតហើយ។

ក្រោយមកបន្តិច ក្រុមគ្រួសារខ្ញុំ និងគ្រួសារដទៃទៀត ត្រូវពួកខ្មែរក្រហមបំបែកទៅកន្លែងផ្សេងៗគ្នា។ ខ្ញុំក៏បានបែកពីបងប្រុស បងស្រី និងកូនៗរបស់គាត់ដែរ។ ខ្ញុំមិនមានដំណឹងរបស់ពួកគាត់រហូតចប់របបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩។

នៅឆ្នាំ១៩៧៦ មុនមកដល់កោះញ៉ែងបន្តិច ខ្ញុំបានឃើញពួកខ្មែរក្រហម ចាប់ផ្សឹកលោកបង និងលោកពូខ្ញុំ /អ្នកផ្សេងទៀត/ពីព្រះសង្ឃមកជាគ្រហស្ថ ហើយបញ្ជូនពួកគាត់ឡើងឡាន«ហ្សេអឹមសេ»។ ខ្ញុំមិនបានដឹងថាគេបញ្ជូនពួកគាត់ទៅកន្លែងណានោះទេ។  ក្រោយមក មានគេមកប្រាប់ខ្ញុំថា បងប្រុសខ្ញុំបានស្លាប់ដោយសារជំងឺ។ ខ្ញុំមិនដឹងថាគាត់ទៅកន្លែងណា ឬគេសម្លាប់គាត់នៅទីណានោះទេ។ ខ្ញុំមានអារម្មណ៍កាន់តែពិបាកចិត្តព្រោះបាត់បង់ឪពុក បាត់បង់បងប្រុស ហើយនិងអ៊ុំពូទៀត។ វាធ្វើឲ្យខ្ញុំមានអារម្មណ៍កាន់តែភ័យខ្លាច តក់ស្លុត ក្តុកក្តួល

និងតែងតែគិតថា មិនដឹងថ្ងៃណា គេមកយកខ្ញុំទៅទៀតនោះទេ ព្រោះនៅសល់តែ២នាក់ម្តាយនិងកូន។

ខ្ញុំនិងម្តាយ តែងបែកគ្នាទៅធ្វើការតែរៀងៗខ្លួន។ ព្រឹកចេញ ល្ងាចចូល។ ជារៀងរាល់ល្ងាច តែងមានពួកឈ្លបពួននៅចាំក្រោមផ្ទះរបស់ខ្ញុំ ហើយលបចាំស្តាប់មើល ក្រែងខ្ញុំឬម្តាយលួចហូបអី ជជែកឬនិយាយគ្នាពីរឿងអ្វីមិនល្អ ឬទិតៀនដល់អង្គការ នឹងអាលពួកវា ពាំនាំយកទៅរាយការណ៍ដល់ថ្នាក់លើ។ ម្តាយខ្ញុំ និងខ្ញុំ តែងតែរស់នៅដោយភាពភ័យខ្លាចជាប់ក្នុងខ្លួនជានិច្ច។ ពួកគេប្រើខ្ញុំឲ្យទៅកាប់ដើមកន្ទ្រាំងខែត្រ ដើម្បីធ្វើជីរដាក់ស្រែ។ ទោះបីការងារពិបាកនឿយហត់យ៉ាងណា ក៏ខ្ញុំមិនហ៊ានរអ៊ូរទាំ ឬត្អូញត្អែរឡើយ។ ពេលធ្វើការ ខ្ញុំមិនដែលហ៊ានអង្គុយក្បែរមនុស្សម្នាច្រើននោះទេ។ ហើយខ្ញុំក៏មិនហ៊ានសូម្បីជជែកឬសួរនាំគ្នានោះដែរ ព្រោះខ្ញុំតែងមានអារម្មណ៍ភ័យខ្លាចចំពោះការសង្ស័យការចោទប្រកាន់របស់ពួកខ្មែរក្រហមមកលើរូបខ្ញុំ ដែលអាចនាំឲ្យមានការរាយការណ៍ ឬការទិតៀនមិនល្អពីខ្ញុំទៅដល់ថ្នាក់លើ។ ខ្ញុំតែងតែអង្គុយបែកពីគេពីឯងអង្គុយដាច់ៗពីគ្នា ប្រសិនបើមានឬគ្មានកំហុស ដែលពួកវាមើលឃើញ ពួកវានឹងហៅទៅប្រជុំ ធ្វើការទិតៀនភ្លាម ឬចាប់យកទៅកសាង ឬរៀនសូត្រតែម្តង។ ដូច្នេះខ្ញុំតែងមានអារម្មណ៍ភ័យខ្លាច និងតក់ស្លុតជាប់ជានិច្ច ហើយតែងគិតថា មិនដឹងពេលណាដល់វេណខ្លួនឯងនោះទេ។

ជារៀងរាល់ថ្ងៃ ខ្ញុំបានឃើញទាហានខ្មែរក្រហមមានស្ពាយកាំភ្លើង បណ្តើរអ្នកមានកំហុសជាខ្សែៗ ពីមុខផង ពីក្រោយផង ឲ្យដើរចេញពីភូមិ។ អ្នកខ្លះមានការុងឥវ៉ាន់ ខ្លះមានបង្វេចខោអាវ និងខ្លះទៀតមានរបស់របរជាប់ខ្លួនបន្តិចបន្តួចតាមតែអាចយួរតាមខ្លួនរួច។ រាល់អ្នកទាំងអស់ដែលទៅហើយនោះ ខ្ញុំមិនដែលបានឃើញអ្នកទាំងនោះបានត្រលប់មកវិញនោះទេ គឺមានតែចេញទៅបាត់ពីក្នុង

ភូមិរហូត។ ពេលមើលឃើញហេតុការណ៍បែបនេះ ខ្ញុំមានអារម្មណ៍ភ័យខ្លាចជាប់ក្នុងខ្លួនជានិច្ចជារៀងរាល់ថ្ងៃ ហើយគិតក្នុងចិត្តថា «មិនដឹងជាពេលណាដល់វេនខ្ញុំទេ!»។ ខ្ញុំគិតតែពីប្រឹងប្រែងខិតខំធ្វើការ មិនហ៊ានត្អូញត្អែរឬឈប់សំរាកឡើយ បើទោះបីជាមានជំងឺក៏ដោយ។ បើសិនជាឈប់ពេលមានជំងឺ គេនឹងទិតៀនយើងថាយើងខ្ជិលច្រអូស និងមានពុតត្បុត។ ដូច្នេះ ខ្ញុំតែងប្រឹងធ្វើការទាំងឈឺទាំងជា។

ក្នុងឆ្នាំ១៩៧៩ ពេលកំពុងធ្វើការខ្ញុំបានឮសំលេងគ្រាប់កាំភ្លើង។ ខ្ញុំបានរត់ត្រលប់ក្រោយ ដើម្បីទៅរកម្តាយខ្ញុំ ដែលខ្ញុំបានដឹងថាគាត់ក៏ធ្វើការនៅកន្លែងក្បែរខ្ញុំនេះដែរ។ ពេលទៅជួបម្តាយខ្ញុំ ពួកខ្ញុំក៏រត់បន្តទៅមុខទៀត។ ពេលទៅដល់ទីនោះ គេបានរើសរុះផ្ទះខ្ញុំអស់រលីង គ្មានសល់អ្វីសោះ។ ម្តាយ និងកូន នាំគ្នាកាប់ស្លឹកត្នោត ស្លឹកដូង និងដើមឫស្សីក្បែរៗផ្ទះនោះ យកមកធ្វើកូនខ្ទមសម្រាប់ជ្រកកោន។ ថ្ងៃមួយ នៅក្នុងភូមិ ម្តាយខ្ញុំនិងខ្ញុំ បានជួបជាមួយបងស្រីនិងកូនៗរបស់គាត់ ដែលបានបែកគ្នាតាំងពីស្រុកបែកថ្មីៗ។ ក្រោយមកបន្តិចខ្ញុំក៏បានជួប «គ្រូរ៉ន»។ គាត់បានប្រាប់ពួកខ្ញុំថាគាត់បានឃើញពួកខ្មែរក្រហមធ្វើទារុណកម្ម និងសម្លាប់បងប្រុសខ្ញុំឈ្មោះ«ណួន»នៅក្នុងគុកទួលស្លែង។ គាត់បានឃើញហេតុការណ៍ ដោយសារតែគាត់ក៏ជាអ្នកទោសក្នុងគុកនោះដែរ ប៉ុន្តែគាត់បានរួចខ្លួនពីការសំលាប់របស់ពួកខ្មែរក្រហម ដោយមានគេមករំដោះទាន់ពេល [សម្រាប់គាត់]។

ខ្ញុំបានដាក់ពាក្យបណ្តឹងទៅសាលាក្តីខ្មែរក្រហមតាមរយៈលោកស្រីមេធាវី ជេត វណ្ណលី ដើម្បីស្វែងរកយុត្តិធម៌ដល់រូបខ្ញុំ ក្រុមគ្រួសាររបស់ខ្ញុំ អ្នកស្លាប់ទាំងអស់ និងជនរងគ្រោះដទៃទៀតក្នុងប្រទេសកម្ពុជាទាំងមូល។ ខ្ញុំចង់បានធូរស្បើយពីអារម្មណ៍ជឺតដាម និងចង់មានការគាំទ្រផ្លូវចិត្តពីសាលាក្តីខ្មែរក្រហម ជាពិសេសពីស្ថាប័នពាក់ព័ន្ធនានា។ ខ្ញុំចង់ឲ្យមានការកសាងកន្លែងណាមួយនៅទីសាធារណៈ ដើម្បីទុកជាកន្លែងគោរពបូជា និងរំលឹកទៅអ្នកដែលបានស្លាប់បាត់បង់ជីវិតក្នុងសម័យខ្មែរក្រហម។ ខ្ញុំចង់ឲ្យមានការចងក្រងជាសៀវភៅ ឬជា

ឯកសារនានា ដើម្បីទុកឲ្យក្មេងជំនាន់ក្រោយបានមើល បានឃើញ បានស្គាល់ និងបានដឹងឮ អំពីប្រវត្តិសាស្ត្រនិងពីសម័យដ៏ឃោរឃៅ ដ៏កំសត់វេទនារបស់មនុស្សជំនាន់ដើមនេះថា«វាពិតជាកើតមានប្រាកដមែន»។ ខ្ញុំចង់ឃើញ និងចង់ឲ្យអ្នកប្រព្រឹត្តទាំងនោះ ទទួលកំហុសរបស់ខ្លួនចំពោះមុខសាធារណៈជន។ ខ្ញុំចង់ឲ្យដំណើរការកាត់ទោស របស់សាលាក្តីខ្មែរក្រហម ប្រព្រឹត្តទៅឲ្យបានឆាប់រហ័ស ព្រោះពួកគាត់កាន់តែចាស់ៗអស់ហើយ បើនៅយូរ គាត់មុខជាស្លាប់ទៅអស់ដោយគ្មានអ្វីកាត់ទោស ឬមិនបានទទួលទោសកំហុសជាមិនខាន។

ជាចុងក្រោយ ខ្ញុំសូមអរគុណដល់អង្គការធីភីអូ ដែលបានកោះហៅខ្ញុំ និងផ្តល់ឱកាសឲ្យខ្ញុំ បានមកចូលរួមក្នុងកម្មវិធីព្យាបាលតាមបែបសក្ខីកម្មនេះ ព្រោះវាពិតជាបានជួយដល់ខ្ញុំឲ្យធូរស្បើយពីអារម្មណ៍ផ្លូវចិត្តរបស់ខ្ញុំ ដែលបន្សល់ពីសម័យខ្មែរក្រហម។ ខ្ញុំមានអារម្មណ៍សប្បាយរីករាយណាស់ ដែលបានចូលរួមជាមួយអង្គការធីភីអូ ហើយបានជួប និងស្គាល់មនុស្សម្នាផ្សេងៗទៀតជាច្រើន ដែលពួកគាត់គឺជាជនរងគ្រោះ និងជាដើមបណ្តឹងដូចជារូបខ្ញុំដែរ។ ខ្ញុំចាប់ផ្តើមមានអារម្មណ៍ធូរស្រាលនិងល្អប្រសើរជាងមុន ព្រោះខ្ញុំបានចែករំលែកអារម្មណ៍របស់ខ្ញុំ និងទទួលបានការគាំទ្រពីបុគ្គលិករបស់អង្គការ។ ខ្ញុំសូមអរគុណ។

ខ្ញុំមានសមាជិកគ្រួសារជាច្រើននាក់ ដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងសម័យខ្មែរក្រហម រួមនិងក្រោយសម័យខ្មែរក្រហម ដូចមានរាយឈ្មោះខាងក្រោម៖

- លោកឪពុក ប៊ុននាង ស្លាប់ក្នុងឆ្នាំ១៩៧៥ (៥នាក់គាត់ខាងក្រោម គឺចាប់និងនាំយកទៅក្នុងថ្ងៃតែមួយ)
- លោកអ៊ុំប្រុស អេង ស្លាប់ក្នុងឆ្នាំ១៩៧៥
- លោកអ៊ុំប្រុស ម៉ម ស្លាប់ក្នុងឆ្នាំ១៩៧៥
- បងថ្លៃប្រុស អ៊ុក ស្លាប់ក្នុងឆ្នាំ១៩៧៥
- លោកពូ វុន ស្លាប់ក្នុងឆ្នាំ១៩៧៥
- បងប្រុស នីម ស្លាប់ក្នុងឆ្នាំ១៩៧៦-១៩៧៧ (គាត់ ត្រូវចាប់និងនាំយកទៅព្រមគ្នាជាមួយពូណុប)
- លោកពូ ណាប់ ស្លាប់ក្នុងឆ្នាំ១៩៧៦-១៩៧៧
- លោកតា ប៊ុន ស្លាប់ក្នុងឆ្នាំ១៩៧៧
- បងប្រុស ណូន (មិនច្បាស់ឆ្នាំ)
- លោកយាយ ផាន់ (មិនច្បាស់ឆ្នាំ)
- កូនប្រុស នាងរិន (២០១០)
- ម្តាយក្មេក លី បឿន (២០១០)

អ្នកផ្តល់សក្ខីកម្ម៖ ប៊ុន សារឿន
អ្នកផ្តល់ប្រឹក្សា៖ ស៊ុន សូលីដា
ភ្នំពេញ ថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៤



រូបគំនូរមួយនេះ បង្ហាញអំពី បទពិសោធន៍ឈឺចាប់និង ការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរជាងគេបង្អស់មួយរបស់ ស៊ុំ រិទ្ធី ក្នុងអំឡុងពេលនៃរបបខ្មែរក្រហម៖ «កម្មាភិបាល ខ្មែរក្រហមបានចាប់ខ្លួនខ្ញុំនិងបងថ្លៃប្រុសទាំងកណ្ដាល អាធ្រាត។ ពេលចាប់ខ្លួននោះ គេវាយដំយើងត្រង់ក្បាល ហូតដល់ហូរឈាម។ បងថ្លៃប្រុសខ្ញុំឈ្មោះ ពៅ មាន បានជាប់ពន្ធនាគារនោះរយៈពេល៧ថ្ងៃ មុនពេលគេ សម្លាប់គាត់»។

# ម៉ម សាង

អាយុ ៥៣ ឆ្នាំ ជាស្ត្រីមេផ្ទះ មានកូនចំនួន ៤នាក់ រស់នៅ ខេត្តកំពង់ស្ពឺ។

**សាង** មានបងប្រុស២នាក់និងបងស្រី១នាក់។ កាលពីក្មេងពួកគេមានកុមារភាពដ៏រីករាយមួយក្នុងខេត្តកំពង់ស្ពឺ។ ឪពុកម្តាយពួកគេជាកសិករឧស្សាហ៍ព្យាយាម ដែលអ្នកក្នុងភូមិគោរពហើយស្រឡាញ់គាត់យ៉ាងខ្លាំង។ ក្រោយពីការទម្លាក់សម្តេចព្រះនរោត្តមសីហនុ នាឆ្នាំ១៩៧០មក ជីវិតសន្តិភាពរបស់ពួកគេ បានបែកខ្ញែកអស់ ដោយសារសង្គ្រាមស៊ីវិលបន្ទាប់ពីនោះមក។ ការរស់នៅពួកគេបានក្លាយជាអ្នករត់គេចពីគ្រាប់បែកនិងគ្រាប់កាំភ្លើង យកលេណដ្ឋានឬព្រៃធ្វើជាជំរក និងរស់នៅក្នុងក្តីភ័យខ្លាច។ ក្រុមគ្រួសារទាំងមូលបានសំរេចចិត្តជាចុងក្រោយ គេចចាកចេញពីទឹកដីកំណើតរបស់ខ្លួន មករស់នៅក្នុងជំរុំភៀសសឹក និងទីសុវត្ថិភាព ក្នុងមូលដ្ឋានទ័ពច្បារមនរបស់រដ្ឋការ លន់ណុល។ បន្ទាប់មកដល់ថ្ងៃ១៧ មេសា១៩៧៥ ខ្មែរក្រហមបានឈ្នះរដ្ឋាភិបាល រួចដណ្តើមកាន់កាប់ប្រទេសទាំងស្រុង យកទាំងមូលដ្ឋានទ័ពដែលសាងកំពុងរស់នៅផងដែរ។ ខ្មែរក្រហមបានដេញសាង និងក្រុមគ្រួសារចេញ រួចបានបញ្ជូនតាមបញ្ជារបស់គេ ឲ្យទៅរស់នៅកន្លែងថ្មីមួយនៅជនបទ។

# សក្ខីកម្មរបស់ខ្ញុំ

ក្រុមគ្រួសារខ្ញុំ បានធ្វើដំណើរដោយជើង អស់រយៈពេលប្រហែលជា១៥ថ្ងៃ ទើបទៅដល់ស្រុកកំណើត។ ពេលទៅដល់ស្រុកកំណើតភ្លាមនោះ អ្វីៗប្រែប្រួលអស់។ ផ្ទះរបស់ខ្ញុំត្រូវគេរុះរើយកទៅធ្វើជាមន្ទីរពេទ្យ ធ្វើជាសហករតូចៗ និងរៀបចំជារោងសម្រាប់ហូបបាយរួមគ្នានសល់ឡើយ។ ខ្ញុំសម្គាល់ឃើញថា អង្គការបក្សខ្មែរក្រហមបានចាត់ទុកប្រជាជននៅក្នុងភូមិដែលខ្ញុំស្គាល់ទាំងប៉ុន្មាន ជាប្រជាជនចាស់នៅក្នុងភូមិ។ អ្នកស្រុកភូមិខ្ញុំ បានប្ដូរសំលៀកបំពាក់ពីធម្មតា ទៅជាសំលៀកបំពាក់ពណ៌ខ្មៅទាំងអស់ រួចក៏លែងមានអ្វីជាកម្មសិទ្ធឯកជនទៀតដែរ។ ចំណែកឯខ្ញុំ លោកឪពុកអ្នកម្ដាយ និងបងៗ ពួកគេបានចាត់ទុកជាប្រជាជន១៧មេសា(ឬហៅប្រជាជនថ្មី)។ ពួកខ្មែរក្រហម បានឲ្យក្រុមគ្រួសារខ្ញុំសម្រាកនៅក្នុងភូមិកំណើតជាបណ្ដោះអាសន្នសិន។ ៥ថ្ងៃក្រោយមក ពួកគេបានឲ្យខ្ញុំយកខោអាវជ្រលក់ក្នុងភក់ ត្រាំក្នុងទឹកផ្លែម៉ាក្លឿរ ដើម្បីឲ្យប្រែទៅជាពណ៌ខ្មៅទាំងអស់។ បន្ទាប់មក ពួកគេបានបានដាក់ផែនការយ៉ាងតឹងតែង បង្ខំឲ្យប្រជាជនទាំងអស់ ទៅដកស្ទូង ដកសំណាបនៅឯស្រែ។ ចំណែកលោកឪពុកខ្ញុំ ពួកកម្មាភិបាលឲ្យគាត់ទៅធ្វើការនៅផ្នែកកសិកម្ម រីឯម្ដាយខ្ញុំ គេឲ្យទៅមើលថែទាំក្មេងតូចៗនៅក្នុងភូមិ។ ពួកខ្មែរក្រហម បានប្រាប់អ្នកភូមិថា «ត្រូវខិតខំប្រឹងប្រែងធ្វើការដែលអង្គការបក្សបានកំណត់!កុំខ្ជិលច្រអូសឲ្យសោះ! បើមិនដូច្នោះទេ នឹងត្រូវយកទៅរស់នៅដីថ្មី ឬស្រុកលើជាមិនខានឡើយ»(មានន័យថា យកទៅសម្លាប់)។ ចាប់តាំងពីពេលនោះមក ខ្ញុំនិងអ្នកភូមិទាំងអស់ ព្រួយបារម្ភ ភិតភ័យ តក់ស្លុត គ្រប់ៗគ្នា។ ដើម្បីរក្សាជីវិតរស់ អ្វីក៏យើងអាចធ្វើបានដែរ ឲ្យតែអង្គការបក្សបញ្ជា។ ដើម្បីជីវិតរស់តទៅមុខទៀត គ្រប់គ្នាបានខិតខំធ្វើយ៉ាងណាឲ្យសម្រេចបានតាមផែនការរបស់អង្គការបក្ស។ ស្ថានភាពនៅក្នុងភូមិជួបការ

លំបាកខ្លាំង និងស្ថិតនៅក្រោមការសង្កេតឃ្លាំមើលយ៉ាងតឹងតែងពីពួកខ្មែរក្រហម។ ភាពភ័យខ្លាចនេះ បានរំខានដល់ផ្លូវចិត្តប្រជាជនគ្រប់រូប មិនថាចាស់ ឬក្មេងឡើយ។ ជារឿយៗ ខ្ញុំតែងតែប្រទះឃើញពួកខ្មែរក្រហមចាប់ប្រជាជនថ្មី ចងបែបស្លាបសេកបណ្តើរជាច្រើននាក់ឲ្យទៅរស់នៅភូមិថ្មី ឬទៅនៅលើដីថ្មី....

ខែមិថុនាឆ្នាំ ១៩៧៦ ពួកឈ្លបរបស់ខ្មែរក្រហម បានរៀបចំផែនការបញ្ជូនយើងឲ្យទៅនៅកន្លែងថ្មីមួយទៀត។ គេបំបែកបងប្អូននិងឪពុកម្តាយខ្ញុំឲ្យរស់នៅឆ្ងាយពីគ្នា។ ភាពខ្មៅងងឹតនៅក្នុងភូមិពោរពេញទៅដោយភាពភ័យខ្លាច សេចក្តីស្លាប់នឹងមកដល់ប្រជាជនគ្រប់ៗគ្នា បើនរណាមិនគោរពតាមគោលការណ៍របស់អង្គការបក្សទេនោះ។ ការគាបសង្កត់គ្រប់បែបយ៉ាង គ្រប់រូបភាព ពីអង្គការបក្សខ្មែរក្រហមគ្មានអ្នកណាម្នាក់ហ៊ានឬអាចតវ៉ាទាមទារអ្វីនោះបានឡើយ។ ពួកខ្មែរក្រហមបានបែងចែក ក្រុមគ្រួសារខ្ញុំ ឲ្យទៅធ្វើការតាមកងចល័ត និងតាមសហករណ៍នានាតាមដែលអង្គការចាត់តាំង។ គ្រប់គ្នាត្រូវតែអនុវត្តន៍ឲ្យទាល់តែបាន ដោយគ្មានល័ក្ខខណ្ឌ។ គេឲ្យទៅធ្វើការនៅឆ្ងាយពីលោកឪពុកអ្នកម្តាយនិងបងៗរបស់ខ្ញុំ។ ខ្ញុំត្រូវដើរដោយជើង ប្រហែលជាង៣០គីឡូម៉ែត្រទើបទៅដល់ភូមិដែលត្រូវធ្វើការ។ នៅទីនោះគេហៅថាភូមិកំពង់អំពិល។ ពួកខ្មែរក្រហមបានដាក់ផែនការយ៉ាងតឹងរឹងបំផុតឲ្យប្រជាជនទាំងអស់ខំប្រឹងជីកប្រឡាយលើកទំនប់។ ទំនប់នោះមានប្រវែងប្រហែល១០គីឡូម៉ែត្រ និងមានជំរៅប្រហែលជា៥ម៉ែត្រ។ ពីមួយថ្ងៃទៅមួយថ្ងៃរស់នៅពឹងផ្អែកលើបុណ្យវាសនាតែប៉ុណ្ណោះ។ ដេកក៏មិនលក់ ខ្លាចផង ភ័យផង។ ខ្ញុំចង់ដឹងអំពីលោកឪពុកអ្នកម្តាយណាស់។ តើលោកទាំងពីរសុខ ឬទុក្ខយ៉ាងណា? ខ្ញុំនឹករលឹកដល់រូបលោក និងបងៗណាស់នៅពេលនោះ។ នៅឆ្នាំ១៩៧៧ ពួកខ្មែរក្រហមបានបង្ខំខ្ញុំឲ្យទៅជីកប្រឡាយនៅតំបន់០១ ស្ថិតនៅស្រុកកំណើតរបស់ខ្ញុំ។ ខ្ញុំនឹកលោកឪពុកអ្នកម្តាយ និងបងៗ យ៉ាងខ្លាំង។ ខ្ញុំបានសុំច្បាប់ពីប្រធានមិត្តនារីទៅសួរសុខទុក្ខលោកឪពុកអ្នកម្តាយនិងបងៗ។ ពេលទៅដល់ ខ្ញុំឃើញលោកឪពុកអ្នកម្តាយ និង

បងស្រីម្នាក់ៗមានទឹកមុខស្រងូតស្រងាត់ណាស់។ គាត់បានរៀបរាប់ប្រាប់ខ្ញុំទាំងទឹកមុខក្រៀមក្រំ និងសម្ដីអួលអាក់ដើមកថា «វេលាម៉ោងប្រហែលជា៦ល្ងាច បងប្រុសទី២របស់កូនត្រូវពួកខ្មែរក្រហមចាប់ចងបែបស្លាបសេក រួចបណ្ដើរចេញទៅសម្លាប់នៅភូមិត្រពាំងទូក ទាំងគ្មានកំហុសបន្តិចសោះ»។

ប្រហែលជា២ខែក្រោយមក នៅក្នុងឆ្នាំ១៩៧៨ ពួកវាបានមកតាមចាប់យកបងប្រុសទី៣ នៅចំពោះមុខម្ដាយរបស់ខ្ញុំ រួចចងបណ្ដើរយកចេញទៅ ។ ខ្ញុំបានឮថា ពួកវាបានវះពោះ និងពុះទ្រូងយកថ្លើមគាត់ស៊ី។ សូម្បីតែសំលៀកបំពាក់ដែលនៅជាប់នឹងខ្លួនប្រាណគាត់ ក៏ពួកវាមិនទុកឲ្យមានឡើយ។

លោកឪពុកខ្ញុំ ឈឺចាប់ខ្លោចផ្សាណាស់។ គាត់នឹកស្រណោះកូនប្រុសទាំងពីរដែលពួកខ្មែរក្រហមបានចាប់យកទៅសម្លាប់យ៉ាងអាណោចអាធ័ម យ៉ាងឃោរឃៅយង់ឃ្នងជាទីបំផុត។ ការខឹងចិត្ត តូចចិត្តមានជាប់នៅក្នុងដួងចិត្ត ការអត់អាហារ ការបង្ខំឲ្យធ្វើការហួសកំលាំងទាំងពិការដៃ ធ្វើឲ្យគាត់ឈឺស្លាប់ក្នុងសភាពគ្មានថ្នាំសង្កូវព្យាបាលសោះ។

ការងារដែលខ្ញុំធ្វើ លំបាកខ្លាំងណាស់ សូម្បីការហូបចុកក៏មិនគ្រប់គ្រាន់។ ពួកខ្មែរក្រហមបានកំណត់ឲ្យត្រឹមតែបបរ១ខ្ទះប៉ុណ្ណោះ សម្រាប់មនុស្សយ៉ាងតិច ១០០នាក់នៅក្នុងសហករមួយ។ ការស៊ូទ្រាំមិនបានប៉ុន្មានផង ខ្ញុំធ្លាក់ខ្លួនឈឺគ្មានកំលាំងកំហែងរហូតដល់ធ្វើការលែងកើត ទើបខ្ញុំសុំប្រធានមិត្តនារីសម្រាកព្យាបាលជម្ងឺ។ ប្រធានមិត្តនារីបានយល់ព្រម។ ចិត្តខ្ញុំពោរពេញទៅដោយភាពភ័យខ្លាច តក់ស្លុត និងមិនហ៊ានសម្រាកបានយូរនោះឡើយ។ សម្រាកបានប្រហែលជា២ម៉ោងប៉ុណ្ណោះ ខ្ញុំក៏ស្ទុះស្ទារទៅធ្វើការធម្មតាវិញ ទាំងសភាពមិនទាន់បានធូរស្បើយនៅឡើយនោះទេ។

នៅដើមឆ្នាំ១៩៧៩ ពួកកងទ័ពវៀតណាមបានវាយលុកចូលក្នុងប្រទេសធ្វើឲ្យទាហ៊ានខ្មែរក្រហមស្លាប់ និងរបួសស្ទើរតែនៅទូទាំងប្រទេស។ នៅថ្ងៃទី០៧

ខែមករា ១៩៧៩ កងទ័ពវៀតណាមដណ្ដើមបានជ័យជំនះទាំងស្រុងពីកណ្ដាប់ដៃអង្គការបក្សកុម្មុនិស្តដែលហៅថា «ខ្មែរក្រហម»។

នៅឆ្នាំ១៩៧៩ដដែលនេះក៏គឺជាឱកាសដ៏ល្អសម្រាប់ប្រជាជនរាប់ពាន់រាប់ម៉ឺននាក់រត់គេចខ្លួន ដើម្បីរស់រានជីវិតឡើងវិញ ។ ពេលនោះបានប្រទះឃើញម្ដាយនិងបងស្រី។ យើងបាននាំគ្នាធ្វើដំណើរសំដៅឆ្ពោះទៅរកព្រំដែនថៃជាមួយគ្នា។ ខ្ញុំជួបការភ័យខ្លាចម្ដងទៀត ហើយនៅពេលនោះ ដោយសារនៅតាមបណ្ដោយដងផ្លូវ តាមវាល តាមព្រៃភ្នំ ខ្ញុំបានប្រទះឃើញសុទ្ធតែសាកសព្វពាសពេញព្រៃមានទាំងមនុស្សនិងទាហ៊ានដេកស្លាប់ត្រៀបត្រាតាមដងផ្លូវ។ ខ្ញុំ អ្នកម្ដាយ និងបងស្រីច្បង មានសំលៀកបំពាក់តែ១សំរាប់គត់ ផុយរលេះរលួយជាប់នៅនឹងខ្លួន។ សំលៀកបំពាក់សើម ក្បាលសុទ្ធតែចៃ រមាស់ពេញទាំងខ្លួន ដើរឆ្លងកាត់អូរ ស្ទឹង ព្រៃ។ ពួកយើងអត់មានបាយហូប។ រួចបន្តដំណើរទាំងយប់ទាំងថ្ងៃឆ្លងកាត់កំពូលភ្នំឆ្ពោះទៅរកប្រទេសថៃ។ គ្រប់គ្នាដេកអង្គុយឱបក្បាលជង្គង់។

នៅឆ្នាំ១៩៨០ ខ្ញុំ អ្នកម្ដាយ និងបងស្រីច្បងបានមករស់នៅជុំរុំកៀសខ្លួនមួយ។ ពួកយើងរស់នៅទីនោះហែល២ឆ្នាំ។ ពួកខ្មែរក្រហមនៅតាមជ្រលងភ្នំនៅតែបន្តផ្លោងគ្រាប់ដាក់ជុំរុំជារៀងរាល់ថ្ងៃ។ ប្រជាជនជាច្រើននៅទីនោះខ្លាចមិនហ៊ានដើរហើរទៅទីណាឡើយ។ កាលនោះដែរ ស្ដេចថៃបានប្រកាសឲ្យដឹកជម្លៀសប្រជាជនទៅនៅជុំរុំមួយទៀត។ ក្រោយមកពួកខ្ញុំបានធ្វើដំណើរទៅរស់នៅជុំរុំផ្សេងមួយទៀត។ អ្នកម្ដាយ និងបងស្រីបានវិលត្រឡប់ទៅស្រុកកំណើតវិញ។ កាលនោះ ខ្ញុំមិនចង់ត្រឡប់ទៅវិញឡើយ ព្រោះខ្លាចសង្គ្រាមកើតឡើងម្ដងទៀត។ ខ្ញុំតាមបងស្រី និងអ្នកម្ដាយទាំងបង្ខំចិត្ត ត្រឡប់មកមាតុប្រទេសវិញនៅឆ្នាំ១៩៨១។ មកដល់«ជុំរុំ អូរស្មាច់» ជាប់ព្រំប្រទល់ដែនប្រទេសថៃ។ ពេលនោះខ្ញុំបានរៀបការ។ ដោយសារទាហ៊ានវៀតណាម ផ្លោងចូលជុំរុំអូរស្មាច់យ៉ាងខ្លាំងនាពេលនោះ ខ្ញុំនិងប្ដីនៅស៊ូទ្រាំមិនបាន ក៏នាំគ្នាគេចខ្លួនបន្តទៅរស់នៅ«ជុំរុំដាវិដ» នៅឆ្នាំ១៩៨២ ក្រុមគ្រួសារខ្ញុំបានរស់នៅជុំរុំ«សាយប៊ី» អស់រយៈ

ពេលជិត១០ឆ្នាំ។ រហូតមកដល់ឆ្នាំ១៩៩១ អ្នកម្តាយបងស្រីខ្ញុំនិងប្តីគាត់បានធ្វើមាតុភូមិនិវត្តន៍មកប្រទេសវិញដោយសុវត្ថិភាព ។

ឆ្នាំ១៩៩៨ សុខភាពម្តាយរបស់ខ្ញុំកាន់តែទ្រុឌទ្រោមទៅៗ។ ម្តាយខ្ញុំបានស្លាប់ចោលខ្ញុំ។ ខ្ញុំមាននៅសល់តែបងស្រីម្នាក់គត់ ។ ក្រោយពីរបបខ្មែរក្រហមបានផុតទៅ ខ្ញុំមានបញ្ហាផ្លូវចិត្ត និងមានការប្រែប្រួលនៅលើរាងកាយយ៉ាងច្រើនចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០២ ។ នៅឆ្នាំ២០០៣ បងស្រីច្បងខ្ញុំ បានស្លាប់ចោលខ្ញុំ។ ពេលនោះ ជីវិតខ្ញុំកាន់តែកំសត់ទៅៗ ដោយលោកឪពុក អ្នកម្តាយ និងបងៗ បានស្លាប់ចោលអស់គ្មានសល់ ទុកឲ្យខ្ញុំរស់នៅតែម្នាក់ឯងជាមួយភាពសោកសៅ។ ភាពអស់សង្ឃឹម ក្រៀមក្រំ អាឡោះអាល័យ មានជាប់នៅក្នុងខួរក្បាល និងទឹកភ្នែកហូរចេញមក ទាំងអាល័យដល់លោកអ្នកមានគុណជាពន់ពេកណាស់។

ការឈឺចាប់ កាលនៅក្នុងរបបសម័យប្រល័យពូជសាសន៍ បានធ្វើឲ្យជីវិតខ្ញុំជួបនឹងការរំខានជាប្រចាំថ្ងៃ ហើយខ្ញុំមានបញ្ហាផ្លូវចិត្តជាប់រហូតមកដល់បច្ចុប្បន្ននេះ។

ខ្ញុំសង្ឃឹមថា សក្ខីកម្មអំពីរបបប្រល័យពូជសាសន៍នេះ នឹងក្លាយជាឯកសារសិក្សាមួយ សម្រាប់ក្មេងជំនាន់ក្រោយ បានសិក្សារៀនសូត្រនិងដឹងឮអំពីទុក្ខវេទនា ដឹងពីការប្រព្រឹត្តយ៉ាងព្រៃផ្សៃបំផុត មិនធ្លាប់មានកន្លងមកនៅក្នុងប្រទេសកម្ពុជា។ ជាពិសេសកុំយកតម្រាប់តាមក្នុងមាគ៌ាដ៏អាក្រក់ និងឃោរឃៅយង់ឃ្នងនេះឲ្យសោះ។

គ្រប់ជាតិ ខ្ញុំប្រាថ្នាឲ្យលោកឪពុកអ្នកម្តាយ និងបងៗ កើតជាតិណាៗកុំឲ្យជួបព្រឹត្តិការណ៍ដ៏សាហាវនេះជាថ្មីចំពោះពួកគាត់ទៀតឡើយ។

ខ្ញុំមានសំណូមពរដល់តុលាការ អ.វ.ត.ក ឲ្យជួយរកមុខរកជនឧក្រិដ្ឋឲ្យទាល់តែបាន និងកាត់ទោសឲ្យបានធាប់រហ័សក្នុងសំណុំរឿង០០២/០១នេះ។ ទាំង

ការផ្តល់យុត្តិធម៌ដ៏ពិតប្រាកដដល់ជនរងគ្រោះដែលបានស្លាប់ក្នុងសម័យខ្មែរក្រហម ទាំងការដាក់ទារុណកម្មជនជាប់ចោទ សូមផ្អែកលើសុភវិនិច្ឆ័យទាំងស្រុង និងសូមឲ្យមានការចូលរួមជ្រោមជ្រែងពីរដ្ឋាភិបាលកម្ពុជាផងដែរ។

សូមឲ្យលោកឪពុកអ្នកម្តាយ និង បងប្រុសទាំង២ ដែលបានធ្វើមរណៈកាលនៅក្នុងរបបសម័យនោះ សូមឲ្យបែរក្រោយឲ្យពរដល់អ្នកនៅរស់ជីវិតឲ្យទទួលបាននូវយុត្តិធម៌ និងសេចក្តីសុខគ្រប់ៗគ្នា កុំបីអាក់ខានឡើយ។

ខ្ញុំសូមឧទ្ទិសកុសលដល់៖

- លោកឪពុក ម៉ម ស៊ិន
- បងប្រុសទី២ ម៉ម គឹមស្រ៊ិន
- បងប្រុសទី៣ ម៉ម សាត់
- បងប្រុសសាច់ថ្លៃ ឈុន ហួរ
- បងប្អូនជីដូនមួយ៖ ១.ប៉ែន ផុន ២.ប៉ែន ម៉ន និង ៣.ប៉ែន ផន ដែលបានស្លាប់នៅក្នុងរបបសម័យប្រល័យពូជសាសន៍ ខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។
- ម្យ៉ាងទៀតខ្ញុំសូមឧទ្ទិសដល់អ្នកម្តាយ និងបងស្រី ម៉ម ស្រ៊ន ដែលបានលាចាកលោក អស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ។

អ្នកផ្តល់សក្ខីកម្ម៖ អ្នកស្រី ម៉ម សាង

អ្នកផ្តល់ប្រឹក្សា៖ ប៊ុន លឹមហ៊ួរ

ភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៤



ជនរងគ្រោះពីសម័យខ្មែរក្រហមភាគច្រើនលើលលុប មិនត្រឹមតែត្រូវទ្រាំទ្រ និងស៊ូរស់ជីវិតពីការប្រព្រឹត្តិដ៏ឃោរឃៅបំផុត កាលនៅក្នុងដៃខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែពួកគាត់ត្រូវរងការលងបន្លាចផងដែរ ដោយសារការចងចាំអំពើយង់ឃ្នងជាច្រើនទាំងនោះ មានដូចជា ការសម្លាប់ ដែលពួកគាត់បានឃើញផ្ទាល់ភ្នែក។ ស៊ុំ រិទ្ធី មិនខុសពីគេឡើយ៖ «អ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសជាច្រើនទៀតត្រូវកម្មាភិបាលខ្មែរក្រហមកាត់ក្បាលគាត់ពេលគាត់ប្រកែកមិនឆ្លើយសំនួររបស់ពួកគេ។ ខ្ញុំបានឃើញសកម្មភាពនេះផ្ទាល់ភ្នែកមុនគេ ដោយសារខ្ញុំកំពុងធ្វើការងារនៅក្នុងតំបន់នោះ។ ខ្ញុំបានឃើញពួកគេចងអ្នកទោសនោះ រួចកាត់ក្បាលចេញពីដងខ្លួន»។

# ប៊ុត សារ៉េន

## ឈ្មោះហៅក្រៅ«សារ៉េន» អាយុ៥៨ឆ្នាំ ជាស្ត្រីមេម៉ាយ ជាមេផ្ទះ នៅខេត្តព្រៃវែង

**សារ៉េន** ជាកូនទី៣ របស់គ្រួសារមួយដែលមានកូន១៥នាក់។ ឪពុកនាងជាគ្រូបង្រៀន ម្តាយនាងជាមេផ្ទះ។ គ្រួសារនេះរស់នៅក្នុងជីវភាពសប្បាយរីករាយ ហើយកូនៗ គោរពប្រតិបត្តិឪពុកម្តាយណាស់។ ពេលវេលាដ៏ល្អនេះ បានមកដល់ទីបញ្ចប់ភ្លាមៗ នៅឆ្នាំ១៩៧៥ ជាពេលដែលសង្គ្រាមស៊ីវិលផ្ទុះឡើងនៅជនបទ ហើយតាមសំណូមពររដ្ឋាភិបាល ឪពុករបស់សារ៉េនបានស្ម័គ្រចិត្តចូលបំរើក្នុងកងកុម្មង់ដូដែលមានមូលដ្ឋាននៅសាលារៀនឯទីរួមខេត្ត។ មិនយូរប៉ុន្មានថ្ងៃមួយឪពុកសារ៉េនបានស្លាប់ក្នុងទីលានប្រយុទ្ធប្រដាប់អាវុធមួយទៅ។ ម្តាយរបស់សារ៉េនធ្លាក់ខ្លួនក្នុងស្ថានភាពអស់សង្ឃឹមមួយ -- ក្លាយជាស្ត្រីមេម៉ាយ ហើយមានកូន១៥នាក់ ដែលត្រូវចិញ្ចឹមក្នុងបន្ទុក។ ឆ្នាំ១៩៧២ សារ៉េនបានរៀបការជាមួយអ្នកអាជីពសុខាភិបាលម្នាក់ដែលធ្វើការនៅភ្នំពេញ។ នាងមិនអាចចាកចោលម្តាយ និងបងប្អូនឡើយ ដូច្នេះប្តីនាងត្រូវធ្វើដំណើរទៅវិញទៅមកពីភ្នំពេញមកស្រុកកំណើតរបស់ម្តាយ រហូតដល់ពេលខ្មែរក្រហមកាន់កាប់អំណាចទាំងស្រុង។

# សក្ខីកម្មរបស់ខ្ញុំ

ឆ្នាំ១៩៧៥ ថ្ងៃទី១៧ ខែមេសា ខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ និងបណ្ដាខេត្តនានានៃកម្ពុជា។ ខ្ញុំ គ្រួសារខ្ញុំនិងប្រជាជនខ្មែររាប់លាននាក់ត្រូវបានពួកខ្មែរក្រហមបង្ខំជម្លៀសឲ្យចេញពីភូមិស្រុក ផ្ទះសម្បែងទាំងអស់។ ពួកគេបានបែកបាក់ព្រាត់ប្រាស់កូន-ចៅ ប្ដី-ប្រពន្ធ និងសាច់ញាតិ។ ក្នុងក្រុមគ្រួសារឮសូរតែសម្លេងយំស្រែក និងទឹកមុខក្រៀមក្រំយំសោកសង្រេងគ្រប់ៗគ្នា ពីព្រោះពួកគេគិតថាពិតជាខកខានលែងបានជួបមុខគ្នាទៀតហើយ។ ចំណែកប្ដីខ្ញុំ បានមករកខ្ញុំនៅស្រុកកំណើតខាងខ្ញុំ។ ខ្ញុំសប្បាយចិត្តណាស់ព្រោះយើងបានជួបមុខគ្នា។ ទោះជាពួកយើងបានផ្លាស់ប្ដូរការងារអាជីពចាស់ មកមានជីវិតថ្មីក្នុងមុខនាទីជាកសិករធ្វើស្រែ-ប្រវាស់ យើងមានការលំបាកនឿយហត់បន្តិចមែន ប៉ុន្តែយើងក៏អាចទ្រាំបានតាមកាលៈទេសៈឲ្យតែយើងបានជុំគ្នានៅក្នុងគ្រួសារ ប៉ុន្តែអ្វីដែលយើងពិបាកក្នុងការទទួលយកគឺការស្ដាប់ និងគោរពតាមវិន័យរបស់អង្គការ (បក្សកុម្មុនិស្តកម្ពុជា) ឬខ្មែរក្រហម។ អ្នកណាហ៊ានតវ៉ាឬប្រឆាំងគេកំទេចអ្នកនោះភ្លាម។

ពួកគេបានដាក់រហ័សនាមឲ្យយើងថា ពួកភៀសសឹក ឬជនឈ្លើយសឹក ឬជាប្រជាជនថ្មី។ ឯពួកគេជាពួកមូលដ្ឋាន ឬជាប្រជាជនចាស់។ ចំណែកការហូបចុកគេតម្រូវឲ្យដោះស្រាយដោយខ្លួនឯងពួកគេមិនទទួលខុសត្រូវឲ្យទេ ប៉ុន្តែត្រូវតែឲ្យធ្វើការងាររួម និងប្រមូលកសិផលជូនទៅអង្គការជាកំហិតខានមិនបាន។

ឆ្នាំ ១៩៧៦ ថ្ងៃមួយ ពួកឈ្លបភូមិ៣នាក់ បានហៅប្ដីខ្ញុំឲ្យទៅរៀនសូត្រ។ ១សប្ដាហ៍ ទៅដល់១ខែ ហើយនៅតែមិនទាន់ឃើញគាត់ត្រឡប់មកវិញទេ។ ខ្ញុំចាប់ផ្ដើមមានការសង្ស័យ។ ខ្ញុំយំរាល់យប់មិនឲ្យគេដឹង។ ម៉ែចេះតែឃាត់និង

ប្រាប់ខ្ញុំថា«កូន កុំយំ! ពេលនេះកូនត្រូវដាំដើមគពីមុខ ហើយដាំដើមល្ហូពីក្រោយ! មិនត្រូវតវ៉ានិយាយអ្វីឡើយ! ពួកយើង អាចស្លាប់បានគ្រប់ពេលដែលគេចង់ឲ្យយើងស្លាប់!»។ កាលនោះ ខ្ញុំមានផ្ទៃពោះ១ខែរួចទៅហើយ។

២ខែបន្ទាប់មក ខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំ ធ្វើដំណើរដោយថ្មើរជើងទៅកាន់ទីនោះ មានអមដំណើរដោយពួកយោធាខ្មែរក្រហមដែលប្រដាប់ទៅដោយអាវុធកាន់នៅដៃគ្រប់ៗគ្នា។ ចំណែកពួកយើងមានអារម្មណ៍ភ័យខ្លាចតក់ស្លុតរកនិយាយអ្វីមិនត្រូវឡើយ។ ទោះជាងងឹតចាក់ភ្នែកមិនយល់យ៉ាងណាក៏ដោយ ក៏យើងដើរឲ្យទាល់តែដល់គោលដៅដែលពួកគេបានកំណត់ ឬលើកទិសឲ្យយើងទៅធ្វើការងារនិងស្នាក់នៅទីនោះ។

ឆ្នាំ១៩៧៧ ដើមឆ្នាំ ពួកគេហៅឲ្យ ប្រជាជនទាំងអស់ទៅប្រជុំ ហើយប្រាប់ថាមានរថយន្តបិទដំបូលជិតជាច្រើនគ្រឿង និងត្រូវមកដឹកពួកយើងឲ្យចេញពីភូមិបន្តទៅរស់នៅកន្លែងផ្សេងទៀត។ គ្មានការតវ៉ាអ្វីទាំងអស់ ហើយចាំថា ទីណាក៏ជាផ្ទះរបស់យើងដែរពីឆ្នាំ១៩៧៥ ទៅ។ ពួកយើងរៀបចំប្រដាប់ប្រដា ឡើងឡានជាបន្ទាន់។ ដោយសារតែយប់ងងឹតពេក ខ្ញុំមិនបានស្គាល់ ថាជាកន្លែងណា ឬស្រុកណាទេ។ អង្គការខ្មែរក្រហម បានបែងចែកការងារឲ្យអ្នកជម្លៀសធ្វើគ្រប់គ្នា។ គឺមិនទុកឲ្យទំនេរដៃ ឬសំរាកឡើយ។ ម៉ែខ្ញុំទៅដាំបន្លែ មួយថ្ងៃៗត្រូវរែកទឹកស្រោចស្លែ ដោយកំណត់ឲ្យបាន ១០០អំរែក ជាគោល។ គេឲ្យខ្ញុំជំរះស្មៅដាំស្រូវ។ បងប្អូនខ្ញុំទាំងអស់មានការងារធ្វើគ្រប់ៗគ្នា។ ម្នាក់ៗ ពិតជាគ្មានពេលសំរាកទេ។ ទាំងអស់គ្នាហូបចុកមិនគ្រប់គ្រាន់ ការងារធ្ងន់ៗ ឈឺអត់ថ្នាំព្យាបាលគ្មានសិទ្ធិនិយាយស្តី។ មកនៅទីនេះបាន១ខែ ខ្ញុំក៏គ្រប់ខែសំរាលបានកូន ប្រុសកំសត់ម្នាក់គួរជាទីស្រលាញ់ និងអាណិតក្រៃលែង។ បានឃើញកូននឹកដល់ស្វាមីជាទីស្រលាញ់។

ឆ្នាំ១៩៧៨ នារដូវរំហើយ ខ្ញុំយល់សប្តិឃើញស្វាមីខ្ញុំមកប្រាប់ថា «កុំរង់ចាំផ្លូវខ្ញុំអី! ខ្ញុំស្លាប់ហើយ!ខ្ញុំមិនមកជួបឯងទៀតទេ! ចូរឯងថែរក្សាកូនប្រុសយើងឲ្យល្អផង!»។ ២ថ្ងៃបន្ទាប់មក ប្រធានក្រុមខ្មែរក្រហម ម្នាក់បានហៅខ្ញុំទៅប្រាប់ថា «បើឯងអាណិតម៉ែឯង មិនចង់ឲ្យគាត់ទៅរែកទឹកស្រោចបន្លែទៀតទេ ឬមិនចង់ស្លាប់ទាំងពូជទេនោះ ឯងត្រូវតែគោរពវិន័យរបស់បក្ស គឺឯងត្រូវតែរៀបការចាប់ដៃ(ប្តេជ្ញាចិត្ត) ក្រោមទង់ក្រហមបដិវត្តន៍ដែលជាផែនការរបស់បក្ស នោះឯងអាចមានជីវិតដូចគេឯងជារៀងរហូត។ ម៉ែ គាត់ភ័យណាស់ខ្លាចស្លាប់ គាត់ដាច់ចិត្តព្យាយាមលួងលោមអង្វរកខ្ញុំរាល់ថ្ងៃ។ ខ្ញុំមិនពេញចិត្តទេ ប៉ុន្តែខ្ញុំមិនអាចប្រកែកបាន។ ខ្ញុំក៏មិនចង់ឲ្យម៉ែពិបាកទ្រាំជាមួយការងារធ្ងន់ៗដែរ។ ខ្ញុំក៏សម្រេចចិត្តទាំងអារម្មណ៍ក្តុកក្តួល តាមផែនការរបស់បក្សកំណត់ឲ្យ។ ខ្ញុំអាណិតខ្លួនឯងណាស់ ព្រោះបានរៀបការបែបសត្វក្អែក មានតែខោអាវពណ៌ខ្មៅ ហើយរៀបការរហូតទៅដល់៧២គូក្នុងថ្ងៃតែមួយជាមួយគ្នា។ បន្ទាប់ពីបានរៀបការរួចហើយ អង្គការបានបង្គាប់ឲ្យម្នាក់ៗ ត្រឡប់ទៅធ្វើការងារនៅតាមមុខព្រួញ(ទីកន្លែងការងារ)រៀងៗខ្លួនវិញ។

ឆ្នាំ១៩៧៩ ហាក់ដូចជាមានប្រផ្នូលអ្វីម៉្យាងមកប្រាប់ពួកយើងថា ជាការវាយរំដោះប្រទេសជាតិឲ្យរួចពីរបបខ្មែរក្រហមដ៏កាចសាហាវនៃបក្សកុម្មុនិស្តហើយ។ គ្រួសារខ្ញុំបានធ្វើដំណើរដូចគេឯងដែរ គឺបានធ្វើដំណើរវិលមកស្រុកកំណើតវិញទាំងអារម្មណ៍ត្រេកអរ។ ជាអកុសល ខ្ញុំមានជំងឺហើមពេញខ្លួនដើរស្ទើរមិនរួច តែមិនអាចទ្រាំនៅបានទៀតទេ។ ទាំងអស់គ្នាព្យាយាមដើរគេចពីការកៀរឲ្យឡើងភ្នំនិងការកៀរ ឲ្យចូលទៅក្នុងព្រៃកៅស៊ូរបស់ពួកខ្មែរក្រហម។ យើងដើរទាំងយប់ទាំងថ្ងៃ អស់រយៈពេល២សប្តាហ៍ទើបបានមកដល់មាត់«ទន្លេបិត» របស់ខេត្ត(កំពង់ចាម)។ យើងបានសំរាកនៅទីនោះបណ្តោះអាសន្នសិនចាំមានកម្លាំងទើបបន្តដំណើរទៅមុខទៀត។

ម៉ែមានចិត្តធម៌ណាស់ គាត់បានចែករំលែកអាហារដែលមានតិចបំផុតជូនទៅបុរសមានវ័យជរាម្នាក់ ស្បែកជ្រីវជ្រួញ ស្លៀកខោអត់ពាក់អាវ។ បុរសនោះគាត់បានទទួលអាហារពីម៉ែបរិភោគយ៉ាងឆ្ងាញ់ រួចគាត់បានទស្សន៍ទាយឲ្យម៉ែថា «ចាប់ពីពេលនេះទៅអ្នកឯងមានគេជួយហើយ! ឆ្លងទឹករួច អ្នកឯងនឹងបានធ្វើដំណើរតាមផ្លូវរអិលរហូតដល់ស្រុកកំណើត! កុំព្រួយអី!»។ មិនគួរឲ្យជឿ! ចំណែកស្វាមីខ្ញុំគាត់មានទឹកមុខក្រៀមក្រំ ទំនងជាមានការនឿយហត់ខ្លាំងពេក។ គាត់សម្លឹងមើលមុខខ្ញុំហើយនិយាយប្រាប់ថា គាត់សុំបែកផ្លូវពីខ្ញុំហើយ ពីព្រោះគាត់បែកឪពុកម្តាយបងប្អូនយូរហើយ គាត់ចង់ទៅស្រុកកំណើតរបស់គាត់។ ខ្ញុំខកចិត្តណាស់ អស់សង្ឃឹមយ៉ាងខ្លាំង ប៉ុន្តែត្រូវសំរេចតាមបំណងរបស់គាត់។

មិនដឹងជាកុសល ឬជាវាសនាល្អ ពេលបងស្រីខ្ញុំរត់មកប្រាប់ថា ពួកយើងអាចធ្វើដំណើរទៅស្រុកបានតាមរថយន្តរបស់កងទាហ៊ានខ្មែរ។ ខ្ញុំនឹកឃើញដល់ការទស្សទាយ៍របស់លោកតាជរាម្នាក់នោះ។ ខ្ញុំបានគិតថាគាត់ពិតជាទេវតាមកប្រាប់យើង ព្រោះគាត់ឃើញទុក្ខលំបាកយើង។ ខ្ញុំរីករាយណាស់មានអារម្មណ៍ថាហាក់បានឡើងដល់ឋានសួគ៌ដែលខ្ញុំមិនធ្លាប់ស្គាល់។ ពាក់កណ្តាលយប់ទំនងជាម៉ោង១២អាធ្រាត យើងបានទៅដល់ស្រុកកំណើតដោយសុវត្ថិភាព។ ក្រោកឡើង! យើងត្រូវតែតស៊ូផ្តើមចាប់យកមុខរបរផ្សេងពីគ្នាដើម្បីរកចិញ្ចឹមជីវិត!»។ ចាប់ពីពេលនោះមក គ្រួសារយើងមានហូបចុក ក្មេងៗទៅសាលារៀន។ កូនប្រុសដ៏កំសត់របស់ខ្ញុំ ក៏អាចរស់នៅបានដូចជាក្មេងដ៏ទៃឯទៀតដែរ។

ឆ្នាំ១៩៨២ ស្វាមីដែលសុំបែកផ្លូវបានវិលមកវិញ ហើយរស់នៅជាមួយគ្នា។ ឆ្នាំ១៩៨៣ ខ្ញុំបានសំរាលកូនប្រុសម្នាក់ទៀតដ៏គួរឲ្យស្រលាញ់ខ្លាំងណាស់ អាយុបាន៥ខែ ស្វាមីរបស់ខ្ញុំបានសុំទៅបំពេញភារៈកិច្ចជាយោធារបស់ឃុំសង្កាត់។ ខ្ញុំជូនដំណើរគាត់ទាំងពេញចិត្ត។ ជួបហើយព្រាត់ ព្រាត់ហើយជួប រួចក៏ព្រាត់វិញ។ ខ្ញុំត្រូវរស់នៅថែទាំកូនទាំងពីរតែម្នាក់ឯង រហូតមកដល់ឥឡូវនេះ កូនខ្ញុំពេញវ័យមានក្រុមគ្រួសាររៀងៗខ្លួនអស់ហើយ។ ខ្ញុំមានចៅជាទីស្រលាញ់ចំនួន៣នាក់។

ខ្ញុំបានដាក់ពាក្យបណ្តឹង សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងមានការទទួលស្គាល់ពី អវតក ឬហៅថាសាលាក្តីខ្មែរក្រហម។ ខ្ញុំតែងមានការរំពឹងទុកថា៖

- សាលាក្តីខ្មែរក្រហមនឹងរកយុត្តិធម៌ពិតៗ ១០០ភាគរយ ដល់អ្នកស្លាប់ទាំងឡាយក្នុងប្រទេសកម្ពុជាក្រោមស្នាដៃសាហាវរបស់ពួកខ្មែរក្រហមចាប់ពីឆ្នាំ១៩៧០-១៩៧៩ ។
- ចង់ឲ្យពិភពលោកបានដឹងឮនូវអំពើកាចសាហាវរបស់ពួកខ្មែរក្រហម។
- ចង់ឲ្យមនុស្សជំនាន់ក្រោយ កុំយកតំរាប់តាមពួកខ្មែរក្រហម ។
- សុំឲ្យតុលាការខ្មែរក្រហមជួយពន្លឿនការកាត់ទោសឲ្យបានឆាប់រហ័សពីព្រោះជនជាប់ចោទកាន់តែមានវ័យជរាអស់ហើយ។
- ខ្ញុំចង់បានសំណងរួមមួយគឺជាស្តូបអានុស្សាវរីយ៍ស្តីពីការស្លាប់របស់ប្រជាជនកម្ពុជាក្នុងសម័យខ្មែរក្រហមកាន់កាប់អំណាចដ៏លីលានោះ។

ជារៀងរាល់ពិធីសាសនាព្រះពុទ្ធយើងខ្ញុំតែងតែ ប្រារព្ធបុណ្យទាននិង តែងតែរំលឹកឧទ្ទិសដល់ឈ្មោះ ៖

- លោកពុក កែន មុត
- អ្នកម៉ែ ហឹម យុម
- ស្វាមី ខូវ ងួន
- ប្អូនស្រី ប៊ុត សារូ និង ប៊ុតសារួន
- ក្មួយកែវ ក្មួយទ្រី ក្មួយទី

និងសាច់ញាតិជិតឆ្ងាយ ក៏ដូចជាប្រជាជនខ្មែរឯទៀត ដែលបានចែក ឋានក្នុងរបបខ្មែរក្រហមក្តី និងក្នុងពេលបច្ចុប្បន្នក្តី សូមមកទទួលយក នូវអត្តមនុញ្ញផលនិងការឧទ្ទិសកុសលទាំងឡាយទទួលយកទៅកាន់ សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ហើយសូមបែរក្រោយឲ្យពរជ័យដល់ កូនចៅដែលរស់នៅឲ្យបានជួបតែសេចក្តីសុខ មានបាន និងអាយុ យឺនយូរអង្វែងតទៅ។

អ្នកផ្តល់សក្ខីកម្ម៖ អ្នកស្រី ប៊ុត សារ៉ែន
អ្នកផ្តល់ប្រឹក្សា៖ អ្នកស្រី ឆាយ មារីជែត
ភ្នំពេញ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤



ការចាត់បង្ខំឲ្យប្រជាជនធ្វើការងារធ្ងន់ គឺជាសញ្ញាសំគាល់មួយ ក្នុងចំណោមសញ្ញាសំគាល់ជាច្រើនទៀតរបស់របបខ្មែរក្រហម។ ស៊ុំ រិទ្ធី រំឮកបទពិសោធន៍របស់ខ្លួន ជាអ្នកទោស៖ «កម្មាភិបាលខ្មែរក្រហម បានបង្ខំយើងឲ្យធ្វើការនៅក្រៅពន្ធនាគារ ផលិតបំពង់ត្រងទឹកត្នោត»។

# លី លន់

អាយុ៦៤ឆ្នាំ រៀបការរួច មានកូនចំនួន៦នាក់។ គាត់ជាកសិករ រស់នៅខេត្តពោធិ៍សាត់។

**លន់** គឺជាកូនពៅ ក្នុងចំណោមកូនទាំងអស់៥នាក់។ គាត់គោរពស្រឡាញ់ម្ដាយគាត់ ដែលគាត់តែងតែរៀបរាប់ថាជា«ម្ដាយគំរូ»មួយរូប។ ឪពុករបស់គាត់ជាសមាជិកដែលអ្នកផងគោរពរាប់អានម្នាក់ នៅក្នុងសហគមន៍ដែលគាត់រស់នៅ។ កាលនៅអាយុ១៤ឆ្នាំ គាត់បានបួសជាសង្ឃ ដើម្បីជួយឪពុកម្ដាយឲ្យជាសះស្បើយ ពីជំងឺម្យ៉ាងដែលបានកើតលើគាត់ហើយគំរាមកំហែងដល់អាយុជីវិត។ នៅឆ្នាំ១៩៧១ ប្រទេសបានស្ថិតក្នុងភាពវឹកវរ។ ខ្មែរក្រហម និងក្រុមខាងរដ្ឋាភិបាលបានធ្វើសង្គ្រាមនឹងគ្នា។ គាត់រៀបរាប់អំពីរបៀបដែលខ្មែរក្រហមនាំព្រះសង្ឃចេញពីវត្ត កាលពីច្រើនឆ្នាំមុនពួកគេមកកាន់អំណាច។

# សក្ខីកម្មរបស់ខ្ញុំ

សង្គ្រាមបានផ្ទុះឡើងរវាងកងទ័ពខ្មែរក្រហមជាមួយនិងកងទ័ពរបស់រដ្ឋាភិបាល។ ការផ្ទុះគ្រាប់កាំភ្លើង ការប្លោងគ្រាប់ចូល បានឆេះកុដិព្រះសង្ឃនិងកន្លែងគោរពសក្ការៈបូជាស្ទើរតែគ្រប់កន្លែងជារៀងរាល់ថ្ងៃ មិនថាពេលយប់ឬពេលថ្ងៃនោះទេ។ ខ្ញុំ និងព្រះសង្ឃទាំងអស់នៅក្នុងវត្តភិតភ័យ ខ្លបខ្លាច និង រន្ធត់ញាប់ញ័រគ្មានព្រលឹងក្នុងខ្លួនឡើយ។ ពេលដេកក៏ដេកមិនលក់ស្រួល។ ព្រោះម្នាក់ៗត្រៀមចាំតែសម្លេងគ្រាប់កាំភ្លើង នឹងអាលនាំគ្នារត់រកកន្លែងសុវត្ថិភាព ឬ គេចចេញពីគ្រាប់ប្លោងរបស់ទាហ៊ានខ្មែរក្រហម។ ខ្មែរក្រហមបានវាយសម្រុកកាន់តែខ្លាំង។ ប្រហែលជាកន្លះខែក្រោយមក ពួកខ្មែរក្រហម បានវាយចូលដល់ក្នុងវត្ត រួចបានជម្លៀសព្រះសង្ឃចេញពីវត្តភ្លាមៗដែរ។ ព្រះសង្ឃត្រូវសឹកទាំងអស់ រួចឲ្យទៅរស់នៅតំបន់រំដោះដែលពួកខ្មែរក្រហមបានកាន់កាប់។

នៅឆ្នាំ១៩៧៣ សង្គ្រាមរវាងទ័ពគាំទ្រដោយសហរដ្ឋអាមេរិក និងទាហ៊ានរបស់ពួកខ្មែរក្រហមកើនកាន់តែខ្លាំងឡើងៗ។ ខ្ញុំ និងប្រជាជននៅក្នុងភូមិរស់នៅទាំងភិតភ័យ ឆ្វេឆ្វាស្លន់ស្លោ ច្របូកច្របល់ ជាលំដាប់។ អ្នកខ្លះយំទ្រហឹងអ៊ឹងកងក្មេងៗយំភ័យខ្លាចបាត់ម្តាយ។ ម្នាក់ៗរត់ប្រាសអាយុតែរៀងៗខ្លួន។ ប្រជាជននាំគ្នាជីករណ្ដៅ(ត្រង់សេ)កាប់ដី កាច់មែកឈើប្រក់ជាដំបូលគ្របពីលើរណ្តៅដើម្បីសុវត្ថិភាព ពេលមានគ្រាប់ផ្លោង និងគ្រាប់ទម្លាក់ពីយន្តហោះ។ ខ្ញុំឃើញភ្លើងឆេះយ៉ាងសន្ធោសន្ធៅ។ ផ្ទះសម្បែងគ្មានអ្នកនៅ។ មនុស្ស និងសត្វស្លាប់ជាហូរហែរ។ មានមនុស្សរងរបួសធ្ងន់ជាច្រើននាក់។ អ្នកខ្លះ ដាច់ដៃ ដាច់ជើងហូរឈាម ស្រោចស្រពពាសពេញដី។ អ្នកខ្លះទៀតមានសាច់ញាតិនាំយកទៅព្យាបាលនៅមន្ទីរពេទ្យឯទីរួមខេត្តពោធិ៍សាត់។ មានពេលមួយ ខ្ញុំរត់ចូលទៅក្នុង

លេណដ្ឋាន។ នៅក្នុងឆ្នាំនេះដដែល ស្ថានភាពហាក់បីដូចជាស្ងាត់បន្តិច ឪពុកម្តាយខ្ញុំ បានព្រមព្រៀងគ្នារៀបចំជាមង្គលការឲ្យខ្ញុំ។ នៅសល់តែ២ថ្ងៃទៀតប៉ុណ្ណោះនឹងដល់ថ្ងៃរៀបការ ជាអកុសលស្រាប់តែពួកកងទ័ពលោកសេនាប្រមុខលន់ ណុល បានវាយពួកខ្មែរក្រហម។ ក្រុមគ្រួសារខ្ញុំ និងប្រជាជនក្នុងភូមិជាច្រើននាក់ទៀតបានរត់គេចខ្លួនទាំងភ័យខ្លាច។ ម្នាក់ៗមានទឹកមុខភ័យតក់ស្លុតយ៉ាងខ្លាំងក្រៃលែង។

ឆ្នាំ១៩៧៣ អ្នកភូមិបានវិលមកផ្ទះវិញ ហើយរៀបចំទុកដាក់ផ្ទះសម្បែងឡើងវិញរៀងៗខ្លួន។ លោកឪពុក អ្នកម្តាយ ក៏បានរៀបចំថ្ងៃរៀបការសារជាថ្មី ហើយអញ្ជើញអ្នកភូមិមកចូលរួមមង្គលការ។ ខ្ញុំ និងប្រពន្ធ រស់នៅស្រលាញ់គ្នាបានយ៉ាងសុខសាន្តសុខដុម។ ២ខែក្រោយមក ស្ថានការណ៍កាន់តែខ្លាំងឡើង។ កងទ័ពរដ្ឋាភិបាលបានបង្ខំឲ្យខ្ញុំចូលធ្វើជាទាហ៊ានដើម្បីប្រយុទ្ធជាមួយពួកខ្មែរក្រហម តែខ្ញុំបានបដិសេធមិនព្រមធ្វើ។ បើទោះជាខ្ញុំមិនយល់ព្រមយ៉ាងណាក៏ដោយ ក៏ខ្ញុំបានក្លាយជាកងកម្មង់ដូ យាមការពារនៅបុស្តិ៍ដើម្បីជានាសុវត្ថិភាព និងតទល់ជាមួយពួកទាហ៊ានខ្មែរក្រហមកុំឲ្យវាយចូលបន្ទាយបាន។ ខ្ញុំធ្វើការនៅបន្ទាយនោះបានតែ២ខែប៉ុណ្ណោះ ក៏នាំគ្នាភៀសខ្លួនបន្តទៅរស់នៅខេត្តបាត់ដំបង ស្រុករតនៈមណ្ឌល។ កាលនោះប្រពន្ធរបស់ខ្ញុំមានផ្ទៃពោះ៦ខែទៅហើយ។

នៅឆ្នាំ១៩៧៤ ប្រពន្ធខ្ញុំសម្រាលបានកូនប្រុស១នាក់។ យើងបានរស់នៅស្រុករតនៈមណ្ឌលបានត្រឹមតែមួយឆ្នាំប៉ុណ្ណោះ។ ពេលនោះ សង្គ្រាមកើតមានឡើងនៅស្រុករតនៈមណ្ឌលស្ទើរតែគ្រប់ទិសទី។ ភាពភ័យខ្លាចចាប់ផ្តើមមានចំពោះរូបខ្ញុំ និងក្រុមគ្រួសារម្តងទៀត។ នៅពេលនោះ ប្រពន្ធខ្ញុំកំពុងតែពពោះកូនទី២នៅឡើយ។ ខ្ញុំអាណិតនាងណាស់ រត់ផង លូនផង ពួនក្រាប រាល់ពេលមានផ្ទុះគ្រាប់កាំភ្លើងម្តងៗ។ ខ្ញុំនិងប្រពន្ធពួនសម្ងំលាក់ខ្លួនក្នុងត្រង់សេ។ ខ្ញុំនិងប្រពន្ធបានធ្វើដំណើរចេញពីស្រុករតនៈមណ្ឌល ទៅរកស៊ីនៅស្រុកប៉ោយប៉ែត។ ទៅដល់ស្រុក«ប៉ោយប៉ែត»ភ្លាម ខ្ញុំធ្វើការជាកម្មករអ្នកលីស្ករស ដែលដឹកមកពី

ស្រុកថៃ។ ខ្ញុំនៅទីនោះបានត្រឹមតែ២ខែប៉ុណ្ណោះ ដោយសារខ្ញុំនឹកឪពុកម្តាយ ព្រោះអីពួកគាត់មានសុខភាពមិនសូវល្អនោះឡើយ ហើយចាស់ៗទៀត។ ខ្ញុំស៊ូទ្រាំរស់នៅទីនោះមិនបាន ក៏សម្រេចចិត្តវិលត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំបានធ្វើដំណើរទៅដល់ខេត្តបាត់ដំបង ហើយបានរស់នៅជាមួយអ៊ុំប្រុសម្នាក់។

នៅខែធ្នូ ឆ្នាំ១៩៧៤ ពួកយើងបានបន្តដំណើរត្រឡប់ទៅស្រុកកំណើតនៅខេត្តពោធិ៍សាត់។ ផ្ទះ សម្បែងខ្ញុំ បានឆេះខ្ទេចខ្ទីគ្មានសល់។ នៅមានសល់តែស្លឹកត្នោត និងក្តារ ២ ឬ៣បន្ទះ ប៉ុណ្ណោះ ប្រើធ្វើជាជម្រកបណ្តោះអាសន្ន។ ការរស់នៅរបស់ក្រុមគ្រួសារខ្ញុំបានជួបការលំបាកណាស់ សូម្បីតែការហូបចុក និងទឹកប្រើប្រាស់ក៏គ្មានដែរ។

នៅថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ ពួកខ្មែរក្រហម បានជម្លៀសក្រុមគ្រួសារខ្ញុំនិងអ្នកភូមិឲ្យទៅរស់នៅភូមិមួយផ្សេងទៀត។ ពួកខ្មែរក្រហមបានកំណត់យ៉ាងតឹងរឹងចំពោះអ្នកដែលពួកគេរំដោះបានមកនោះ គឺមិនអនុញ្ញាតិឲ្យទៅរស់នៅឡូកឡំជាមួយនិងប្រជាជនមូលដ្ឋានចាស់ឡើយ។ ខណៈនោះ ខ្ញុំបានជួបបងប្អូនសាច់ញាតិខាងប្រពន្ធ។ ខ្ញុំត្រេកអរ រីករាយណាស់ កាលបើបានជួបជុំគ្នាវិញដូច្នេះ។ ប៉ុន្តែការរំពឹងទុករបស់ខ្ញុំនោះ មិនដូចបំណងដែលបានគិតនោះឡើយ។ ពួកអង្គការខ្មែរក្រហម មិនអនុញ្ញាតិឲ្យយើងទាំងអស់គ្នាទាក់ទងគ្នាឡើយ សូម្បីតែសាច់ញាតិណាម្នាក់ដែលយើងធ្លាប់បានស្គាល់នោះក៏ដោយ។ បើសិនមានអ្នកណាម្នាក់ក្បត់អង្គការរបស់បក្ស ហ៊ានបំពានលើគោលការណ៍ដែលបានកំណត់ គេនឹងកោះហៅអ្នកនោះទៅប្រជុំជីវភាព រួចយកទៅកសាងអប់រំ។ គ្រប់គ្នាឮដូច្នេះ បារម្ភខ្លាច មិនហ៊ាននិយាយរកគ្នានោះឡើយ។ ពេលនោះម្នាក់ៗលែងហ៊ានមាត់ក លែងហ៊ានទៅបង្កើតទំនាក់ទំនងជាមួយប្រជាជនមូលដ្ឋានចាស់ទៀតផង។

នៅខែមិថុនា ឆ្នាំ១៩៧៥ ប្រពន្ធខ្ញុំសម្រាលបានកូនស្រីម្នាក់ទៀត ដែលកើតបានតែ១ខែគត់ ក៏ស្លាប់ទៅវិញ។ ១ខែក្រោយមក ម្ដាយមីងខាងប្រពន្ធបានផ្ដាំខ្ញុំឲ្យទៅជួបនៅឃ្លាំងអង្ករ។ គាត់បានឲ្យអង្ករមកខ្ញុំចំនួន៣កំប៉ុងទុកដាំបាយហូប។ ខ្ញុំមិនបានសំណេះសំណាលជាមួយគាត់យូរឡើយ ព្រោះខ្លាចពួកកម្មាភិបាលខ្មែរក្រហមតាមទាន់។ ប្រហែលជាម៉ោង៧យប់ ទើបបានត្រឡប់មកដល់ផ្ទះ (សហករណ៍)វិញ។ មកដល់ផ្ទះភ្លាម ប្រពន្ធខ្ញុំបានស្ទុះមកឱបខ្ញុំយំខ្សឹកខ្សួលទាំងអារម្មណ៍ភ័យញ័រចំប្រប់ ទាំងបេះដូងលោតដុកដាក់ៗ។ ប្រពន្ធខ្ញុំបានខ្សឹបប្រាប់ថា «ពេលឯងមិននៅ ពួកកម្មាភិបាលបានកោះហៅប្រជាជនមកប្រជុំជីវភាព ហើយបានកំណត់ឈ្មោះអ្នកទាំងឡាយណាដែលមិនអនុវត្តតាមគោលការណ៍របស់បក្ស ដើម្បីយកទៅកំទេចចោល ព្រោះជាខ្មាំង»។ ខ្ញុំយំលាគ្នាជាមួយប្រពន្ធទាំងអាល័យ ទាំងដឹងថាគ្មានអ្នកណាម្នាក់នឹងអាចជួយយើងបាននោះទេ ព្រោះថ្ងៃបញ្ចប់ជីវិតជិតមកដល់រូបខ្ញុំហើយ។ ស្អែកឡើងម៉ោងប្រហែល៦ល្ងាច ប្រពន្ធខ្ញុំបានចេញទៅធ្វើការបាត់។ ពួកឈ្លប២នាក់ ប្រដាប់ដោយអាវុធ «អាកា» ដើរសំដៅមករករូបខ្ញុំ។ ពួកគេស្រែកហៅខ្ញុំឲ្យចេញពីផ្ទះ រួចបណ្ដើរចេញទៅ។ កម្មាភិបាលខ្មែរក្រហម បានបណ្ដើរពួកយើងឲ្យធ្វើដំណើរដោយថ្មើជើងទាំងយប់ទាំងថ្ងៃ ឆ្ពោះទៅតំបន់ព្រៃភ្នំ«ដំណាក់ឈើក្រម»។ នៅពេលទៅដល់ទីនោះភ្លាម ខ្ញុំឃើញអ្នកទោសចំរុះជាតិសាសន៍ ដូចជា ចាម យួន ចិន ខ្មែរជាដើម។

ម៉ោង៧យប់ ពួកកម្មាភិបាលខ្មែរក្រហមបានកោះហៅអ្នកទោសនៅក្នុងគុកទៅប្រជុំ ហើយនិយាយថា «ឥឡូវនេះ អង្គការបក្សត្រូវការអនុវត្តផែនការបក្សជាបន្ទាន់ គឺត្រូវឲ្យជីកប្រឡាយ មានបណ្ដោយប្រហែល១២ម៉ែត្រ ទទឹង១ម៉ែត្រ និងជំរៅ៣ម៉ែត្រ ដាក់ហិតដាច់ខាត»។ បើក្នុងចំណោមអ្នកទោសណាម្នាក់ធ្វើមិនបានសម្រេចទៅតាមគម្រោងផែនការទេនោះ នឹងត្រូវមានទោស ឬយកទៅកសាង។ ពួកកម្មាភិបាលខ្មែរក្រហមបានកំណត់ម៉ោងឲ្យអ្នកទោសទាំងអស់

ត្រៀមធ្វើការឲ្យបានសម្រេចផែនការរបស់បក្ស។ អ្នកទោសទាំងអស់នៅក្នុងគុក ត្រូវក្រោកពីព្រលឹមរាល់ម៉ោង៤ទៀបភ្លឺ ដល់ម៉ោង១១ព្រឹក ឲ្យហូបបាយរួចហើយ បន្តការងារទៀត រហូតដល់ម៉ោង១០យប់ទើបឲ្យសម្រាក។ អ្នកទោសទាំងអស់ មានចំនួន៤០នាក់ រស់នៅរង់ចាំតែសេចក្តីស្លាប់ និងការដាក់ទោសទណ្ឌពីពួក កម្មាភិបាលខ្មែរក្រហមតែប៉ុណ្ណោះ។ នៅពេលនោះ សូម្បីតែការហូបចុកមិនគ្រប់ គ្រាន់ទាល់តែសោះ។ ម្នាក់ៗគ្មានកំលាំងកំហែងធ្វើការទេ។ ខ្ញុំនិងអ្នកទោសទាំង អស់ខិតខំធ្វើការមិនដែលរាថយ ឬហ៊ានខ្ជិលច្រអូសនឹងការងារនោះឡើយ។ ពេលកំពុងធ្វើការ ពួកគេបានដើរស៊ើបសួរអ្នកទោសថា «តើមានអ្នកណាម្នាក់ ធ្លាប់ធ្វើជាទាហ៊ាន ឬធ្វើជាមន្ត្រីរាជការរបស់សម្តេចនរោត្តមសីហនុ ឬទេ?» នៅពេលនោះ គ្មានអ្នកណាម្នាក់ហ៊ានឆ្លើយឡើយ ព្រោះខ្លាចគេយកទៅស្លាប់។ មិនយូរប៉ុន្មានមេកម្មាភិបាលបានកោះហៅអ្នកទោសដែលកំពុងធ្វើការ ឲ្យឡើងភ្នំ ដើម្បីយកម្ហូបអាហារ។ តាំងពីពេលនោះមក បាត់ស្រមោលអ្នកទាំងនោះសូន្យ ឈឹង មិនឃើញត្រឡប់មកវិញឡើយ។ ខ្ញុំមិនហ៊ានវិលទៅជួបប្រពន្ធខ្ញុំឡើយ ព្រោះខ្លាចអង្គការបក្សចាប់បញ្ជូនទៅវិញម្តងទៀត។ ខ្ញុំសម្រេចចិត្តទៅជួបលោក ឪពុកអ្នកម្តាយ។ អ្នកម្តាយខ្ញុំមានរូបរាងស្គមស្គាំងណាស់។ គាត់មានសុខភាព ទន់ខ្សោយ ធ្វើការមិនកើតនោះទេ។ ស្របពេលជាមួយនោះដែរ ប្រពន្ធខ្ញុំបានមក សួរសុខទុក្ខម្តាយខ្ញុំ។ នាងឃើញខ្ញុំ ក៏ស្ទុះមកឱបខ្ញុំយ៉ាងណែន យំផង សួរផង ថា«ឯងមកនៅទីនេះយូរប៉ុណ្ណាហើយ? ហើយមកដោយរបៀបណា?» ខ្ញុំនិយាយទាំងអួលណែនដើមក «ពិបាកណាស់ វេទនាណាស់ គេធ្វើបាបឲ្យខ្ញុំ រស់ដូចជាស្លាប់ បិទសិទ្ធិមិនឲ្យយើងរស់ដោយសេរីឡើយ»។

ខែកក្កដា ឆ្នាំ១៩៧៦ កូនប្រុសទី១ ស្លាប់ដោយសារជម្ងឺគ្រុនចាញ់ គ្មានថ្នាំ ព្យាបាល។ ថ្ងៃមួយទំនងជាគាត់ឃ្លាន ម្តាយខ្ញុំបានគប់ចំមាន់មួយងាប់ភ្លាមមួយ កន្លែង។ ភ្លាមនោះ មេកងកម្មាភិបាលដែលបានឃើញផ្ទាល់ភ្នែកបានគំរាមម្តាយ ខ្ញុំថា «មិត្តឯងក្បត់អង្គការ ដូច្នេះត្រូវបង្អត់អាហារចាប់ពីពេលថ្ងៃនេះទៅ!»។

លុះក្រោយមក នៅខែ៨ ឆ្នាំ១៩៧៦ បងស្រីទី៤ បានប្រាប់ខ្ញុំដោយស្ងាត់ៗថា «អ្នកម្ដាយរបស់យើង ស្លាប់ដោយសារការបង្អត់អាហារ រួមនិងមានជម្ងឺឈឺចុកចាប់ក្នុងពោះខ្លាំង»។ ពីរនាក់បងប្អូននិយាយបណ្ដើរ យំខ្សឹកខ្សួលបណ្ដើរ ជាមួយអារម្មណ៍អួលណែនតឹងដើមទ្រូងពេកណាស់។ មិនយូរប៉ុន្មាន លោកឪពុកខ្ញុំបានធ្លាក់ខ្លួនឈឺ រួចខ្សោយទៅៗ ស៊ូទ្រាំការងារលែងបាន។ ខ្ញុំឃើញលោកឪពុកដេកស្លាប់នៅលើរទេះគោដោយសារធ្វើការហួសកម្លាំង រួចគ្មានអាហារហូបគ្រប់គ្រាន់។

បីខែក្រោយមក ប្រពន្ធខ្ញុំបានឈឺដេកស្លាប់ ដោយសារធ្វើការធ្ងន់ ទាស់សរសៃខ្ទី។ នាងមានជម្ងឺគ្រុនចាញ់ផង ធ្វើការហួសកម្លាំងផង និងគ្មានថ្នាំព្យាបាលទៀត។ លុះក្រោយមក គេចាប់បងស្រីទី៤ខ្ញុំយកទៅសម្លាប់ទៀត ដោយចោទថាគាត់លួចល្ពៅរបស់អង្គការបក្ស។

នៅឆ្នាំ១៩៧៧ ជាពេលវេលា ដែលខ្លួនខ្ញុំផ្ទាល់បានជួបការលំបាក ព្រោះសុខភាពចាប់ផ្ដើមថយចុះ ហើយកាន់តែធ្លាក់ទឹកចិត្ត ដោយសារបងប្អូន ឪពុក ម្ដាយ ប្រពន្ធ និងកូន បានស្លាប់ចោលខ្ញុំទាំងវេទនា ទុកឲ្យខ្ញុំរស់នៅតែម្នាក់ឯងគ្មានគោលដៅ។ រាល់យប់ ខ្ញុំតែងតែសុបិន្តឃើញលោកឪពុក អ្នកម្ដាយមកប្រាប់ថា «ចាប់ពីពេលនេះទៅកូនរស់បានសុខហើយ កុំព្រួយបារម្ភអី!»។ ពេលនោះខ្ញុំយល់ថា អ្នកម្ដាយលោកឪពុកបានមករស់ក្បែរៗខ្ញុំ តាមថែរក្សាខ្ញុំគ្រប់ពេលវេលា។ ខ្ញុំបានជួបការលំបាកខ្លាំង ស៊ូទ្រាំនិងការងារលែងសូវបាន។ កម្លាំងចុះខ្សោយទៅៗ ។ មានតែម្នាក់ឯង ខ្ញុំរស់នៅគ្មានទិសដៅអ្វីទាល់តែសោះ។ គ្រាមួយនោះពេលពួកឈ្លបបានប្រទះឃើញខ្ញុំនិងអ្នកផ្សេងទៀតអត់ធ្វើការ គេបានចោទថាពួកខ្ញុំខ្ជិល ស្ពឹកស្រពន់ សម្រេចផែនការជូនអង្គការបក្សមិនបាន។ ខ្មែរក្រហមបានវាយខ្ញុំនិងគល់ខ្សែរទេះគោ និងធ្វើទារុណកម្ម ៣០នាក់ផ្សេងទៀត ដូចខ្ញុំដែរ។ បន្ទាប់មកកម្មាភិបាលទាំងអស់នោះបានព្រមាន និងដាក់ផែនការឲ្យខ្ញុំទៅទឹមគោធ្វើស្រែនៅក្រុមដំណាក់ផ្អិត។ ខ្ញុំនិងអ្នកទោសទាំងអស់បានដើរដោយជើង

រយៈពេល១យប់ ១ថ្ងៃ អត់បាយអត់ទឹក មុនពេលទៅដល់សហករណ៍នោះ។ ពួកមេកម្មាភិបាលបានឲ្យអ្នកទោសក្រោកធ្វើការ ចាប់ពីម៉ោង៣ទាបភ្លឺរហូតដល់ម៉ោង១១ថ្ងៃត្រង់ ហូបបាយរួចហើយធ្វើការបន្តរហូតដល់ម៉ោង១០យប់ ទើបបានសម្រាក។

នៅថ្ងៃធ្វើការដំបូង ខ្ញុំក្រោកមិនទាន់ម៉ោងធ្វើការ។ ពួកកម្មាភិបាលបានចាប់ខ្ញុំធ្វើទារុណកម្ម វាយខ្ញុំដោយប្រើខ្សែតី។ រំលងបាន៥ថ្ងៃខ្ញុំដេកជ្រុលទៀត ពួកឈ្លបបានវាយខ្ញុំ ដែលកំពុងតែដេក។ បន្ទាប់មក ពួកកម្មាភិបាលបញ្ជូនខ្ញុំទៅធ្វើស្រែចំការនៅសហករណ៍វិញ។

ឆ្នាំ១៩៧៨ អង្គការបក្សខ្មែរក្រហម បានរៀបចំចាប់យុទ្ធជនមកផ្ទឹមរៀបការជាក្រុម។ ខ្ញុំត្រូវជាមួយមិត្តនារីម្នាក់ឈ្មោះ«ចន្ថា»ដែលយើងទាំងពីរមិនពេញចិត្តនឹងគ្នាសោះ។ គេបានរៀបចំជាបបរស្ករ រួចឲ្យខ្ញុំទាំងពីរនាក់ប្ដេជ្ញាចិត្តចំពោះអង្គការ គោរពតាមគោលការណ៍ និងទិសផែនការរបស់បក្សជាដាច់ខាត ហើយត្រូវខិតខំធ្វើការដោយមិនរួញរា ឬគេចវេស ខ្ជិលមិនអនុវត្តតាមផែនការដែលបក្សបានកំណត់ឡើយ។ នៅជាមួយគ្នាបាន១យប់ គេបំបែកឲ្យទៅធ្វើការកន្លែងផ្សេងៗគ្នា។

នៅខែមេសា ឆ្នាំ១៩៧៩ ខ្ញុំនិងប្រពន្ធ បានមកជួបគ្នាម្ដងទៀត។ ពេលនោះប្រពន្ធការនៅសម័យខ្មែរក្រហមរបស់ខ្ញុំ បានសុំខ្ញុំទៅស្រុកកំណើតគាត់វិញនៅភ្នំពេញ។ យើងទាំងពីរនាក់ក៏បែកគ្នា ខ្ញុំក៏បានសម្រេចចិត្តមករស់នៅជិតផ្សារត្រពាំងជង។ នៅទីនោះមានសុវត្ថិភាពជាងនៅស្រុកកំណើត។

ឆ្នាំ១៩៨០ខ្ញុំរៀបការជាមួយស្ត្រីម្នាក់ឈ្មោះ«ជួង ផេង»ហើយរួមរស់នៅជាមួយគ្នាបានយ៉ាងសុខសាន្ត។

ឆ្នាំ១៩៨១ ប្រពន្ធខ្ញុំកើតបានកូនប្រុសម្នាក់។ ដល់ឆ្នាំ១៩៨២ មានកូនប្រុសម្នាក់ទៀត។ ដល់ខែ៨ ឆ្នាំ១៩៨៥ មានកូនប្រុសម្នាក់ទៀត។ ១៩៨៧ មានកូន

ស្រីម្នាក់។ មកដល់ឆ្នាំ១៩៩០ ខ្ញុំមានកូនប្រុសមួយទៀត។ និងមកដល់ឆ្នាំ ១៩៩៣ មានកូនស្រីពៅម្នាក់ទៀត ។

នៅឆ្នាំ១៩៨៤ សង្គ្រាមរវាងកងទ័ពរដ្ឋកម្ពុជាជាមួយពួកខ្មែរក្រហមបានកើតឡើងក្នុងភូមិខ្ញុំ។ ពួកគេបាញ់ផ្លោងចូលក្នុងភូមិ។ ខ្ញុំភ័យស្លន់ស្លោ បីកូនប្រុសដែលទើបតែមានអាយុ៤ឆ្នាំ លោតចូលក្នុងរណ្ដៅត្រង់សេ (លេណដ្ឋាន) ធ្វើឲ្យកូនខ្ញុំ ប៉ះក្បាលទៅនឹងជញ្ជាំងដីត្រង់សេ។ មួយខែក្រោយមក កូនខ្ញុំក៏បានស្លាប់ចាកចេញពីជីវិតខ្ញុំមួយទៀតទៅ ។

នៅឆ្នាំ១៩៩៣ ខ្ញុំនិងក្រុមគ្រួសារបានជួបគ្រោះថ្នាក់មួយយ៉ាងរន្ធត់គំរាមដល់អាយុជីវិតម្ដងទៀត។ ពួកចោរប្រដាប់អាវុធមួយក្រុមបានភ្ជង់កាំភ្លើងខ្ញុំ រួចចាប់ខ្ញុំចង។ ក្រោយបន្តិចមកពួកវាបានបាញ់ចំពីក្រោយចង្កេះ ធ្លាយមកខាងមុខភ្លៅ។ តាំងពីពេលនោះមក ខ្ញុំសម្គាល់ខ្លួនឯងឃើញមានអាការៈប្រែប្រួលច្រើន។ រាល់ពេលខ្ញុំឃើញមនុស្សមានឯកសណ្ឋានជាទាហ៊ាន ខ្ញុំមានភ័យខ្លាច ញ័រតក់ស្លុត មិនហ៊ានងើយមើលមុខគេឡើយ។ ជងខ្លួនខ្ញុំញ័រចំប្រ៉ប់។ បេះដូងខ្ញុំលោតខុសចង្វាក់ ធ្វើឲ្យខ្ញុំមិនហ៊ានដើរផ្សារឡើយ។

តាំងពី១៩៩៤ មកដល់ឆ្នាំ២០១៣ ក្រុមគ្រួសាររស់នៅបានសេចក្ដីសុខក្សេមក្សាន្ត និងរៀបចំការកូនបាន៤នាក់។

ទាំងអស់នោះហើយ បានជំរុញខ្ញុំឲ្យដាក់ពាក្យបណ្ដឹងទៅតុលាការសាលាក្ដីខ្មែរក្រហមហៅ អ.វ.ត.ក ចាប់ នៅឆ្នាំ២០០៩ ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីសំណុំរឿង០០២/០១ ដើម្បីស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះដែលបានស្លាប់ទៅ ជាពិសេសយុត្តិធម៌សំរាប់រូបខ្ញុំផ្ទាល់ ដែលបានឆ្លងកាត់របបប្រល័យពូជសាសន៍ខ្មែរក្រហមនេះយ៉ាងវេទនាបំផុត។

សម្រាប់ផែនការទៅថ្ងៃអនាគត់ខ្ញុំប្រាថ្នាចង់ឲ្យពីភពលោកបានទទួលស្គាល់នូវព្រឹត្តិការណ៍៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ដែលគ្រប់គ្រងដោយខ្មែរក្រហមសាហាវ

យង់ឃ្នងនេះ ហើយឲ្យតុលាការ អ.វ.ត.ក. ដាក់ទោសអ្នកទទួលខុសត្រូវ នាពេលដ៏ខ្លីខាងមុខនេះ។ ខ្ញុំពេញចិត្តឲ្យឯកសាររឿងរ៉ាវខ្ញុំនេះ បានដឹងដល់យុវជនជំនាន់ក្រោយសំរាប់អានសិក្សារៀនសូត្រ ដើម្បីជៀសឲ្យឆ្ងាយពីការដឹកនាំដ៏ខ្មៅងងឹតបំផុតដូចនេះ។ ខ្ញុំតែងតែបន់ស្រន់ដល់វត្ថុស័ក្តិសិទ្ធក្នុងលោក ជួយញ៉ាំងឲ្យខ្ញុំ បានជួបលោកឪពុកអ្នកម្តាយ ប្រពន្ធកូនរបស់ខ្ញុំគ្រប់ៗជាតិ និងបើបានជួបហើយសូមកុំឲ្យព្រាត់គ្នាដូចជាតិនេះទៀត។

ថ្ងៃនេះពិតជាមានតម្លៃវិសេសវិសាលណាស់ ដែលខ្ញុំមិនធ្លាប់មាន ព្រោះបានចំណាយពេល និយាយរៀបរាប់អំពីសាច់រឿងផ្ទាល់ខ្លួន ដែលលាក់ទុកអស់រយៈពេលជាយូរយារមកនេះ។ ដោយសារសេក្តីកម្មនេះ ខ្ញុំមានអារម្មណ៍ថាធូរស្រាល។

ខ្ញុំសូមឧទ្ទិសកុសលដល់៖

- លោកឪពុក គឹម លី
- អ្នកម្តាយ ច័ន្ទ ស៊ឹម
- បងស្រី ច័ន្ទ សយ   លី សាយ   ច័ន្ទ សុទ្ធ   ច័ន្ទ សឿន
- ប្រពន្ធខ្ញុំ ចាប សូរិយា
- កូនប្រុស លី ចន្ទ្រា
- ក្មួយប្រុស លី ចក់   ក្មួយស្រី លី សុភាព
- ឪពុកក្មេក ចាប យ៉េន
- បងថ្លៃ ចាប ករិត   ប្អូនថ្លៃ ចាប សៅយុទ្ធ
- និងកូនស្រី ច័ន្ទ ទូច  ដែលអ្នកទាំងអស់នេះបានស្លាប់ នៅក្នុងរបបសម័យប្រល័យពូជសាន៍យ៉ាងសាហាវ យង់ឃ្នងបំផុត រួម
- និងកូន លី ង៉ែវ បានស្លាប់នៅឆ្នាំ១៩៨៤ ពេលមានសង្គ្រាមរវាងកងទ័ពរដ្ឋកម្ពុជា និងខ្មែរក្រហម។

អ្នកផ្តល់សក្ខីកម្ម៖ លោក លី លន់
អ្នកផ្តល់ប្រឹក្សា៖ លោក ប៊ុន លឹមហ៊្សរ
ភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤



ប្រជាជនជាច្រើនត្រូវខ្មែរក្រហមបង្អត់អាហារ។ ការធ្វើបាបឲ្យអត់ឃ្លាន បាននាំឲ្យមនុស្សស្វែងរកអាហារដោយខ្លួនឯង – នោះគឺជាឧក្រិដ្ឋកម្មមិនអាចអត់ឱនបាននៅក្នុងភ្នែករបស់ខ្មែរក្រហម ជារឿយៗ ត្រូវទទួលទណ្ឌកម្មដល់ស្លាប់។ ស៊ុំ រិទ្ធី ផ្តល់សក្ខីកម្មថា ៖ «ប្អូនប្រុសខ្ញុំ ស៊ុំ ណារ៉េត ត្រូវកម្មាភិបាលខ្មែរក្រហមចាប់ខ្លួននិងសម្លាប់ដោយសារគាត់លួចល្ពុង១ផ្លែ។ ខ្មែរក្រហម អារបំពង់កគាត់ពីរលើកមុនពេលគាត់ស្លាប់។ នោះគឺអ្វីដែលអ្នកឃើញក្នុងរូបគំនូរដោយខ្មៅដៃនោះ»។

# ស៊ឹម វ៉ាន់

## អាយុ ៥៩ឆ្នាំ មេម៉ាយ មានកូន ៥នាក់
## រស់នៅខេត្តសៀមរាប

**វ៉ាន់** គឺជាកូនបន្ទាប់ពៅ នៃកូនទាំង៨នាក់។ ម្ដាយរបស់គាត់បានស្លាប់ពេលគាត់ទើបមានអាយុ៥ឆ្នាំ។ ឪពុកគាត់ ជាទាហានម្នាក់របស់ពួកលន់ ណុល។ កាលនោះ ជីវិតជួបការលំបាក ហើយក្រុមគ្រួសារត្រូវធ្វើការងារធ្ងន់ៗ ដើម្បីរស់នៅបានជុំគ្នា វ៉ាន់រីករាយនឹងការរស់នៅជុំគ្នា ហើយបានជួយគាំទ្រគ្នាទៅវិញទៅមក។ នៅឆ្នាំ១៩៧៣ វ៉ាន់បានឈប់រៀនមុនកំណត់ ដោយសារក្ដីបារម្ភនានាអំពីសុវត្ថិភាព។ ចាប់តាំងពីឆ្នាំ១៩៧៤មក ប្រទេសបានធ្លាក់ចុះក្នុងភាពជ្រួលច្របល់កាន់តែខ្លាំង ហើយខ្មែរក្រហមបានជ្រាតចូលដល់ខេត្តសៀមរាប។ បងប្រុសរបស់វ៉ាន់ ឈ្មោះ សេង និងសៀប ក៏ដូចជាឪពុកនាងដែរ ពួកគាត់បានចូលបំរើក្នុងកងទ័ពប្រឆាំងខ្មែរក្រហម។ សំរាប់វ៉ាន់វិញ នេះគឺជាចំនុចចាប់ផ្ដើមទំព័រខ្មៅងងឹតដ៏វែងឆ្ងាយមួយនៃភាពភ័យរន្ធត់ ព្រួយបារម្ភ ការជម្លៀសពីលំនៅដ្ឋាន ការព្រាត់ប្រាស់ ការងារធ្ងន់ធ្ងរ ការគំរាមកំហែង មានជម្ងឺរងទារុណកម្ម ដាក់គុគ ការបង្ខំឲ្យរៀបការ ព្រមទាំងការបាត់បង់មនុស្សជាទីស្រឡាញ់ទាំងឡាយ ដែលទាំងអស់នេះ បានបន្សល់ទុកស្លាកស្នាមរហូតដល់បច្ចុប្បន្ន។

# សក្ខីកម្មរបស់ខ្ញុំ

១៩៧៤ ជីវិតរបស់ខ្ញុំបានចាប់ផ្តើមជួបប្រទះនូវភាពភ័យខ្លាច។ ក្រុមខ្មែរក្រហមតែងតែវាយលុក និងបាញ់ផ្លោងគ្រាប់ចូលមកក្នុងតំបន់ដែលខ្ញុំរស់នៅជាញឹកញាប់ ហើយខ្ញុំនិងបងៗនាំគ្នារត់ចូលត្រង់សេដើម្បីសុវត្ថិភាពស្ទើររៀងរាល់ថ្ងៃ។ ពេលនោះ ខ្ញុំដេកទាំងភាពភ័យខ្លាចរាល់យប់។ ខ្ញុំតែងតែទៅមើលកន្លែងដែលគេទទួលអ្នករបួសដើម្បីនូវចាំមើលបងប្រុស និងឪពុកខ្ញុំ។ នៅកន្លែងនោះ ខ្ញុំបានមើលឃើញទាហ៊ានយ៉ាងច្រើនបានដេកស្លាប់ និងរបួសធ្ងន់ធ្ងរ អ្នកខ្លះដាច់ដៃដាច់ជើងស្រែកយំយ៉ាងអណោចអាធ័ម។ ហេតុការណ៍នោះ បានធ្វើឲ្យខ្ញុំមានអារម្មណ៍តក់ស្លុត ភ័យខ្លាច ញ័រន្ទត់ នឹងព្រួយបារម្ភយ៉ាងខ្លាំងពីសុវត្ថិភាពរបស់ពួកគាត់ ព្រោះខ្ញុំមិនចង់រស់នៅកំព្រាឪពុកម្តាយ និងបងប្អូនឡើយ។

គ្រួសាររបស់ខ្ញុំ និងអ្នកដទៃទៀត ត្រូវបានខ្មែរក្រហមជម្លៀសទាំងបង្ខំពីស្រុកកំណើតទៅកាន់តំបន់ស្វាយលើ។ ពួកខ្ញុំបានធ្វើដំណើរដោយជើងទទេអស់រយៈពេល៣យប់ ៣ថ្ងៃ ដោយគ្មានបាយហូបនោះទេ។ ពេលធ្វើដំណើរតាមផ្លូវ បងស្រី ដា ឈឺគ្រុនចាញ់ធ្ងន់ណាស់ តែគ្មានថ្នាំ ព្យាបាលនោះទេ។ សំណាងល្អមានអ្នកភូមិបានយកថ្នាំខ្មែរមកឲ្យផឹកទើបបានជាសះស្បើយ ហើយពួកខ្ញុំក៏ចេះតែបន្តដំណើរទៅមុខទៀត។ ថ្ងៃមួយ ពេលកំពុងធ្វើដំណើរនៅតាមផ្លូវប្រហែលម៉ោង១២ថ្ងៃត្រង់ ខ្ញុំបានប្រទះឃើញសាកសពមនុស្សយ៉ាងច្រើន ជាពិសេសក្មេងតូចៗ បានដេកស្លាប់ដោយសារខ្វះចំណីអាហារ។ ពេលឃើញហេតុការណ៍ទាំងនោះ ខ្ញុំមានអារម្មណ៍អាណិតអាសូរ និងស្លុតចិត្តណាស់ មិនគួរណាពួកគេមកស្លាប់បែបនេះឡើយ។ កន្លះខែក្រោយមក ពួកខ្ញុំបានធ្វើដំណើរមកដល់តំបន់គោលដៅក្នុងស្រុកស្វាយលើ ជាកន្លែងដែលងាយកើតជម្ងឺគ្រុនចាញ់ណាស់។ ពេលទៅដល់ទីនោះបាន៧ថ្ងៃ ខ្មែរក្រហមបានរៀបចំស្លន់បញ្ចុកឲ្យអ្នកចំណូលថ្មី

ហូប។ បន្ទាប់ពីហូបនំបញ្ចុករួចក៏ចាប់ផ្តើមមានមនុស្សជាច្រើនបានស្លាប់ និង គ្រុនឈឺ រួមទាំងខ្លួនខ្ញុំផងដែរ។

ក្រោយមកខ្ញុំលួចស្តាប់លឺអ្នកក្នុងសហករចាស់និយាយថា មេខ្មែរក្រហមបានបញ្ជាគេឲ្យធ្វើនំបញ្ចុកសម្រាប់អ្នកចំណូលថ្មីហូបដើម្បីឲ្យមានប្រតិកម្ម នឹងអាចបណ្តាលឲ្យស្លាប់បាន ដោយមិនចាំបាច់សម្លាប់នឹងគ្រាប់កាំភ្លើងឡើយ។ គ្រាន់តែស្តាប់លឺរឿងនេះភ្លាម ខ្ញុំមានអារម្មណ៍ភិតភ័យ និងតក់ស្លុត។ បងប្អូនខ្ញុំត្រូវគេប្រើឲ្យទៅវែកដីលើកទំនប់យ៉ាងឆ្ងាយពីកន្លែងស្នាក់នៅ រីឯឪពុកខ្ញុំ ត្រូវខ្មែរក្រហមប្រើឲ្យទៅកាប់ឬស្សីក្នុងព្រៃជ្រៅដែលងាយនឹងកើតមានជម្ងឺគ្រុនចាញ់ខ្លាំងណាស់។ ក្រោយពេលឪពុកខ្ញុំត្រលប់មកដល់សហករវិញ គាត់មានជម្ងឺគ្រុនចាញ់ យ៉ាងធ្ងន់ធ្ងរ រួចបានបាត់បង់ជីវិតទៅ។ បង សៀប បង សេង និងបង ឈុំ មិនបានដឹងពីដំណឹងនេះទេ។ ខ្ញុំខឹងនឹងពួកខ្មែរក្រហមខ្លាំងណាស់តែមិនដឹងជាត្រូវធ្វើយ៉ាងណា។ ថ្ងៃមួយក្នុងរដូវវស្សារប្រហែលម៉ោង១១ថ្ងៃត្រង់ សមមិត្តក្នុងក្រុមខ្ញុំម្នាក់ឈ្មោះ សន  មានអាយុប្រហែល១៧ ឆ្នាំបានលួចរត់គេចមិនធ្វើការ។ ឈ្លប ខ្មែរក្រហមក៏បានចាប់ពួកខ្ញុំដែលជាសមាជិកក្រុម និងអ្នកចំណូលថ្មីដាក់ខ្នោះជើងនៅក្នុងជង្រុកស្រូវមួយ ហើយចោទថាពួកខ្ញុំជាអ្នកផ្សំគំនិតឲ្យសមមិត្ត សន លួចរត់។ ខ្មែរក្រហមបង្អត់អាហារ ដេរប្រមាថជីវិត និងវាយដំពួកខ្ញុំ ដោយប្រើរំព័ទ្ធផ្តៅយ៉ាងធ្ងន់ធ្ងរទៀតផង។ ខ្មែរក្រហមបានចាប់វាយធ្វើបាប និងសួរចម្លើយពួកខ្ញុំអស់រយៈពេល១៥ខែ ទើបដោះលែងឲ្យធ្វើការងារវិញ។ ខ្ញុំមានការឈឺចាប់ណាស់។ ជើង ខ្នងត្រូវហើមដោយសារ ខ្នោះ និងស្នាមរំពាត់។

១៩៧៧-១៩៧៨ ខ្មែរក្រហមបានបញ្ជូនពួកខ្ញុំមកតំបន់ត្នោតពង ហើយត្រូវធ្វើដំណើរដោយជើងទទេអស់ រយៈពេល២យប់ ៣ថ្ងៃទើបទៅដល់ ខ្ញុំបានគិតថាជីវិតនឹងស្លាប់នៅទីនេះពិតប្រាកដហើយ។ ថ្ងៃមួយ ម៉ោងប្រហែល៨ព្រឹក អ្នកភូមិរត់មកប្រាប់ខ្ញុំថា បង សេង ត្រូវបានឡានជាងដូង ( ឡានសំរាប់ដឹកខ្មាំងយកទៅសម្លាប់ ) របស់ខ្មែរក្រហមចាប់ចងស្លាបសេកទម្លាក់ចូលក្នុងទ្រុងឡានបាត់ទៅ

ហើយដោយគេចោទគាត់ថា ជានារសារ ឬមានជាប់ខ្សែស្រឡាយជាទាហ៊ាន។ ដំណឹងនេះធ្វើឲ្យ ខ្ញុំភ័យតក់ស្លុតខ្លាំងណាស់ស្ទើតែគាំងបេះដូង។ ខ្ញុំប្រញាប់រត់ទៅមើលយ៉ាងលឿន តែឡាននោះបានចេញផុតបាត់ មិនដឹងជាទៅទីណានោះទេ។ រំលងបាន១៥ ថ្ងៃក្រោយមក ខ្មែរក្រហមបានហៅខ្ញុំឲ្យទៅចូលរួមប្រជុំ រួចប្រាប់ថាគេនឹងរៀបចំគូស្រករឲ្យអ្នកដែលនៅទំនេរ ។ ខ្មែរក្រហមមានបំណងផ្គូផ្គង ខ្ញុំជាមួយនឹងយោធាពិការជើងនិងភ្នែកម្នាក់ តែពេលនោះខ្ញុំមិនព្រម។ ពួកគេក៏បានឲ្យខ្ញុំវិលត្រលប់មកវិញ។ ៣ថ្ងៃក្រោយមក នាយប់មួយ ម៉ោងប្រហែល ១០យប់ បងធម៌ខ្ញុំ សុខ ក្រឹម បានលួចរត់មកប្រាប់ខ្ញុំថា ឈ្លប ខ្មែរក្រហមមានគម្រោងចង់យកបងប្អូនខ្ញុំទាំង៥នាក់ទៅសម្លាប់ ព្រោះខ្ញុំបានជំទាស់នឹងការរៀបការនោះ។ ឮដូច្នេះ ពួកខ្ញុំភ័យខ្លាចណាស់ ហើយបង សុខ ក៏បានជួយឲ្យបងប្អូនខ្ញុំរត់ចេញពីទីនោះ។

៣ខែក្រោយមក ខ្មែរក្រហមបានចាប់បងប្រុស ឈុំ ចងស្លាបសេក និងវាយធ្វើបាបយ៉ាងធ្ងន់ធ្ងរ រួចអូសយកចេញទៅ។ ក្នុងពេលនោះ ខ្ញុំមានអារម្មណ៍តក់ស្លុត ភ័យខ្លាចណាស់ ខ្លួនខ្ញុំប្រែជាញ័រ ព្រោះគិតថា ថ្ងៃនេះគេចាប់បង ឈុំ ស្អែកប្រាកដជាដល់វេនខ្ញុំម្តងវិញហើយ។ រំលងបាន២ខែ ស្រាប់តែខ្មែរក្រហមបានស្នើឲ្យខ្ញុំរៀបការជាមួយនិងប្រជាជនមូលដ្ឋានក្នុងតំបន់នោះ។ ខ្ញុំមិនចង់រៀបកាតាមការបញ្ជារបស់ខ្មែរ ក្រហមនោះទេ តែបងស្រី ដា គាត់បានប្រាប់ខ្ញុំថា ប្រសិនបើមិនព្រមរៀបការទេ ខ្មែរក្រហមនឹងចាប់បងប្អូនខ្ញុំទាំងអស់ទៅសម្លាប់ចោល។ ថ្ងៃមួយនាចុងឆ្នាំ១៩៧៨ ប្រហែលជាម៉ោង២រសៀល ក្នុងវត្តរុណ ខ្មែរក្រហមបានរៀបចំឲ្យខ្ញុំនិងអ្នកដទៃទៀតបានរៀបការ ដែលមានគ្នាសរុប ៣០គូ។ ក្នុងពេលនោះ ខ្មែរក្រហមបានឲ្យខ្ញុំឡើងប្តេជ្ញាចិត្តថា រស់នៅជាមួយគ្នា និងបម្រើស្មោះស្ម័គ្រចំពោះអង្គការ។ ក្រោយមកខ្ញុំ និងស្វាមីបានចាប់ផ្តើមរួមរស់នៅជាមួយគ្នា ដោយមិនមានជម្លោះអ្វីឡើយ តែខ្ញុំត្រូវគេបង្ខំឲ្យធ្វើការលើសែងធ្ងន់ៗទោះបីជាមានផ្ទៃពោះក៏ដោយ។

ខ្ញុំសម្រាលកូនបានមួយអាទិត្យទាហ៊ានវៀតណាមបានចូលមករំដោះ។ ក្រោយពេលវៀតណាមរំដោះបាន បងប្អូនខ្ញុំនៅមានជីវិតរស់តែ៣នាក់ប៉ុណ្ណោះ គឺ ខ្ញុំ បងស្រី ដា និងបងស្រី ធី។ ចាប់តាំងពីនោះមកខ្ញុំមិនដែលជួបកាលំបាកដោយការធ្វើបាប ឬធ្វើការហួសកម្លាំងទៀតទេ តែខ្ញុំនូវតែមានអារម្មណ៍ភ័យខ្លាចញ័រន្ទត់ និងព្រួយបារម្ភដោយ មិនដឹងមូលហេតុជាប់ខ្លួនជានិច្ច។

ក្រោយមក ស្វាមីខ្ញុំបានស្លាប់បាត់បង់ជីវិតដោយសារគ្រុំគ្រារាងកាយពីការងារហួសកម្លាំងក្នុងសម័យខ្មែរក្រហម។ ពេលនោះ ខ្ញុំពិតជាលំបាកចិត្តខ្លាំងណាស់ គិតថាគ្មានអ្នកណាអាចពឹងផ្អែកបានទៀតទេ ហើយមានអារម្មណ៍សោត់អណ្តែតឯកោ មិនមានលំនឹងច្បាស់លាស់ប្រៀបដូចជាទឹកមួយដំណក់នៅលើស្លឹកឈូកអញ្ចឹង។

ខ្ញុំបានសម្រេចចិត្តដាក់ពាក្យដាក់ពាក្យបណ្តឹងទៅសាលាក្តីខ្មែរក្រហមក្នុងឆ្នាំ២០០៧។ ខ្ញុំខឹង និងចង់សងសឹកមេដឹកនាំខ្មែរក្រហមទាំងនេះណាស់។ ដូចនេះ ខ្ញុំចង់សុំឲ្យតុលាការជួយទាមទារកយុត្តិធម៌ដល់ជនរងគ្រោះ។ ខ្ញុំរំពឹងទុកថា នឹងទទួលបានយុត្តិធម៌។ យុត្តិធម៌នោះគឺ ខ្ញុំចង់សុំឲ្យតុលាការស្វែងរកការពិតពីមេដឹកនាំខ្មែរក្រហម គឺជាកាពិតដែលពួកគាត់ហ៊ានទទួលស្គាល់ និងសារភាពថាពិតជាបានធ្វើអំពើអាក្រក់លើប្រជាជន និងមូលហេតុនៃការសំលាប់។ លើសពីនេះ ខ្ញុំចង់ឃើញតុលាការដាក់ទោសជនជាប់ចោទឲ្យអស់មួយជីវិត ដើម្បីសមនឹងទោសកំហុសរបស់ពួកគេដែលបានធ្វើបាបប្រជាពលរដ្ឋ។ ខ្ញុំចង់ទាមទារឲ្យមានជាសំណងដល់ជនរងគ្រោះ។ សំណងរបស់ខ្ញុំគឺការផ្សះផ្សាផ្លូវចិត្តដើម្បីឲ្យអារម្មណ៍បានធូរស្បើយ បំបាត់នូវភាពឈឺចាប់ រួមនិងសំណងសមូហភាព ដូចជា ស្តូប ឬចេតីយ៍សម្រាប់ដាក់អដ្ឋិធាតុរបស់ជនរងគ្រោះដែលបានស្លាប់ទៅក្នុងរបបខ្មែរក្រហម និងដើម្បីរំលឹកដល់វិញ្ញាណខ័ន្ធឲ្យពួកគេបានស្ងប់ចិត្ត។

ខ្ញុំសូមឧទ្ទិសដល់បងប្អូនសាច់ញាតិដែលបានបាត់បង់ជីវិតដែលរួម មាន ឪពុកម្តាយ និងបងប្រុសខ្ញុំទាំង៤នាក់ ដែលមានឈ្មោះដូចខាង ក្រោម៖

- លោកឪពុក ដុក ស៊ឹង
- អ្នកម្តាយ សយ ថន
- បងប្រុស សៀប
- បងប្រុស សេង
- បងប្រុស ឈុំ
- បងប្រុស ម៉ុន

ព្រមទាំងជនរងគ្រោះដទៃទៀតដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ទាំងអស់។

អ្នកផ្តល់សក្ខីកម្ម៖ ស៊ឹង វ៉ាន់
អ្នកប្រឹក្សាផ្លូវចិត្ត៖ ផាន់ រដ្ឋា
ភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤




ជនរងគ្រោះពីសម័យខ្មែរក្រហមជាច្រើន ចងចាំគ្រប់គ្នា ការបានឃើញខ្មែរក្រហមដឹកអ្នកផ្សេងទៀតចេញទៅ តាមរថយន្តធំៗ ប៉ុន្តែមិនដែលបានឃើញ ឬក៏ឮត្រឡប់ មកវិញឡើយ។ ស៊ុំ រិទ្ធី ក៏បានឃើញរឿងនេះដោយផ្ទាល់ ភ្នែកដែរ៖ «កម្មាភិបាលខ្មែរក្រហម ធ្លាប់បានដឹកអ្នក ទោសជាច្រើន តាមរថយន្តធំៗឆ្ពោះទៅកន្លែងពិឃាដ។ រថយន្តធំមួយ ដឹកអ្នកទោសបានប្រមាណ៥០នាក់ ហើយមានប្រហែល៥ ទៅ៨ឡានក្នុងមួយថ្ងៃ»។

## យោបល់ និងព័ត៌មានត្រឡប់

សៀវភៅនេះ មានបំណង ផ្តល់សម្លេងឲ្យជនរងគ្រោះពីសម័យខ្មែរក្រហម ដើម្បីបំបែកវដ្តនៃការស្ងៀមស្ងាត់អំពីការឈឺចាប់របស់ខ្លួន ហើយនិងបញ្ចប់ការបន្ទុះពារដើម្បីឲ្យអស់ចិត្តពីអតីតកាល។ សក្ខីកម្មដែលជនរងគ្រោះបានចែករំលែកទាំងនេះ អាចយកទៅប្រើជាកំណត់ត្រាប្រវត្តិសាស្ត្រ អំពីអ្វីដែលបានកើតឡើងក្នុងសម័យខ្មែរក្រហម ហើយទុកសម្រាប់ជាឧបករណ៍សិក្សាអប់រំសម្រាប់ក្មេងជំនាន់ក្រោយនៅកម្ពុជា។ សារៈសំខាន់ជាចុងក្រោយ ការផ្សព្វផ្សាយនេះអាចផ្តួចផ្តើមឲ្យមានការពិភាក្សាគ្នា អំពីសម័យខ្មែរក្រហមនិងសេចក្តីត្រូវការនូវការជាសះស្បើយនិងផ្សះផ្សា រួមនិងវិធីទាំងឡាយដែលសេចក្តីត្រូវការទាំងនេះអាចសម្រេចបាន។

យោបល់ឬព័ត៌មានត្រឡប់ អំពីសៀវភៅនេះ អាចផ្ញើទៅ អង្គការធីភីអូកម្ពុជា៖

**អគារលេខ ២និង៤ ផ្លូវឧកញ៉ាវាំង(១៩៥២)** សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ

ប្រអប់សំបុត្រលេខ ១១២៤ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ៖ +855 (0) 23 63 66 992

អ៊ីម៉ែល៖ admin@tpocambodia.org

## ចូលរួមជាមួយយើងខ្ញុំបន្តទៀត

សំរាប់ព័ត៌មានថ្មីៗ អំពីអង្គការធីភីអូកម្ពុជា សូមចូលអាសយដ្ឋាន www.facebook/com/tpocambodia ឬចុះបញ្ជីក្នុងព្រឹត្តិបត្ររបស់យើងខ្ញុំតាមរយៈអ៊ីម៉ែល admin@tpocambodia.org ។

## ការគាំទ្រ

បើខ្លួនអ្នក ឬអ្នកណាម្នាក់ដែលអ្នកស្គាល់ កំពុងជួបការតឹងចិត្ត ថប់បារម្ភ ធ្លាក់ទឹកចិត្ត ឬ វិបត្តិផ្លូវចិត្តផ្សេងៗទៀត សូមកុំស្ទាក់ស្ទើរ ទាក់ទងមកអង្គការធីភីអូកម្ពុជា ដើម្បីបានជំបូន្មានសម្ងាត់និងការគាំទ្រ។ ក្រុមការងាររបស់យើងមានអ្នកប្រឹក្សាផ្លូវចិត្តមានបទពិសោធន៍ អ្នកជំនាញចិត្តវិទ្យា និងវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យាជាច្រើននាក់នៅទីនេះចាំជួយអ្នក។

## មជ្ឈមណ្ឌលព្យាបាលអង្គការធីភីអូកម្ពុជា

(សូមមើលអាសយដ្ឋានខាងលើ)

ម៉ោងធ្វើការ៖ ច័ន្ទ-សុក្រ   ម៉ោង ៨ព្រឹក – ៤ល្ងាច

លេខទូរស័ព្ទ៖ +855 (0) 23 63 66 991

អង្គការចិត្តសង្គមអន្តរវប្បធម៌(ធីភីអូ)កម្ពុជា ដែលបានបង្កើតឡើងនៅឆ្នាំ១៩៩៥ គឺជាអង្គការមិនមែនរដ្ឋាភិបាលមួយ នាំមុខគេក្នុងវិស័យថែទាំសុខភាពផ្លូវចិត្ត និងគាំទ្រចិត្តសង្គម នៅកម្ពុជា។ ធីភីអូ គឺជាអង្គការតែមួយគត់នៅកម្ពុជា ដែលបានចូលរួមក្នុងសកម្មភាពនានានៃយុត្តិធម៌អន្តរកាល ក្នុងបរិបទនៃអង្គជុំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា(អវតក)។ តាំងពីឆ្នាំ២០០៧មក ផ្អែកលើអនុស្សារណៈយោគយល់គ្នា ជាមួយ អវតក អង្គការធីភីអូ បាននិងកំពុងផ្តល់សេវាកម្មចិត្តសង្គមយ៉ាងទូលំទូលាយដល់ដើមបណ្តឹងរដ្ឋប្បវេណីនៃ អវតក។ សេវាកម្មទាំងនោះ រួមមានតាំងពី ការផ្តល់ការគាំទ្រចិត្តសង្គមដល់ទីកន្លែងក្នុងបន្ទប់សវនាការ ការព្យាបាលការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរទៅតាមវប្បធម៌ខ្មែរ ការព្យាបាលតាមវិធីជួយខ្លួនឯងជាក្រុម រហូតដល់សកម្មភាពថ្លែងការពិតនានា រួមនិង ការស្រាវជ្រាវ ទៀតផង។ អង្គការធីភីអូកម្ពុជា មានបទពិសោធន៍ច្រើនឆ្នាំ ក្នុងការតាក់តែង និងអនុវត្តកម្មវិធីផ្អែកលើសហគមន៍ជាច្រើន សំដៅ ប្រយុទ្ធនិងបង្ការ អំពើហិង្សាផ្អែកលើយេនឌ័រ ក្នុងប្រទេសកម្ពុជា។ អង្គការធីភីអូកម្ពុជា មានមណ្ឌលព្យាបាល និងមណ្ឌលបណ្តុះបណ្តាលនៅរាជធានីភ្នំពេញ និងមានការិយាល័យតំណាងនៅតាមបណ្តាខេត្តជាច្រើន។

អង្គការចិត្តសង្គម អន្តរវប្បធម៌
Transcultural Psychosocial Organization
Community Mental Health Programme

## ទស្សនៈវិស័យរបស់អង្គការធីភីអូកម្ពុជា

ប្រជាជនកម្ពុជារស់នៅប្រកបដោយសុខភាពផ្លូវចិត្តល្អ
និងមានការពេញចិត្តក្នុងជីវិតរបស់ខ្លួន

## បេសកកម្មរបស់អង្គការធីភីអូកម្ពុជា

លើកកំពស់សុខមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាដែលមានបញ្ហាចិត្តសង្គម និង
បញ្ហាផ្លូវចិត្ត ដើម្បីអោយពួកគាត់អាចបង្កើនសមត្ថភាពបំពេញតួនាទី
ប្រកបដោយប្រសិទ្ធិភាព ក្នុងការងារ ក្នុងគ្រួសារ និងក្នុងសហគមន៍។

## គុណតម្លៃរបស់អង្គការធីភីអូកម្ពុជា

យើងជា**អ្នកប្រកបកិច្ចការងារតាមជំនាញវិជ្ជាជីវៈ**
**មានការប្តេជ្ញាចិត្តខ្ពស់**
និង តែងតែ**ខិតខំដើម្បីគុណភាព**។
យើងជាអ្នកដែល**ចូលចិត្តរៀនសូត្រ**
និង**ធ្វើការងារជាក្រុម**។
យើងជាមនុស្ស **គួរអោយទុកចិត្ត**
**ស្មោះត្រង់**
តែងតែបង្ហាញនូវ
**ការគោរព** និង **ចេះយល់ចិត្ត**
ព្រមទាំង **អោយតំលៃចំពោះគំនិតយោបល់របស់បុគ្គលគ្រប់រូប**។

ការបោះពុម្ពនេះបានឧបត្ថម្ភដោយ៖

Australian Aid
giz

ទាំងនេះគឺជាប្រវត្តិរឿងផ្ទាល់ខ្លួនរបស់ជនរងគ្រោះពីសម័យ ខ្មែរក្រហម ដ៏ក្លាហាន អត់ធន់ មិនគួរឲ្យជឿទាំង១០នាក់ ដែល ជាចុងក្រោយ កំពុងស្ថិតលើវិថីឆ្ពោះទៅរកការជាសះស្បើយ ប៉ុន្តែ ដែលចង់បានការពិតត្រូវគេដឹងឮ ហើយនិងបានទទួល យុត្តិធម៌ជាងអ្វីៗផ្សេងទៀត។

ISBN: 978-99963-97-03-5

9 789996 397035